## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

*Universite Royale de droit et des Sciences Economiques*

*Royal University of Law and Economics*

## សារណាបញ្ចប់ការសិក្សា

# ការឃាត់ខ្លួន និងការឃុំខ្លួន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **រតនា ពិសេស**

លោក **ឡឿន ស៊ីណា**

អ្នកគ្រូសាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

ឆ្នាំសិក្សា ២០២០-២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **រតនា ពិសេស** និង **នឿន ស៊ីណា** ជានិសិត្សថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី២៥ ឆ្នាំសិក្សា២០១៧-២០១៨។ សូមថ្លែងអំណរគុណនិងដឹងគុណយ៉ាងជ្រាជ្រៅចំពោះ ៖

អ្នកមានគុណទាំងពីរ របស់ពួកយើង ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំ ព្រមទាំងផ្តល់នូវក្តីស្រលាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយ ព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និង លើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ មិនតែប៉ុណ្ណោះតែងតែផ្តល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈសិក្សា និងខាងស្មារតី រហូតខ្ញុំបាទបានបន្តការសិក្សា ការអប់រំកម្រិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្ររហូតឈានទៅដល់ការសរសេរសារណា។

រាជរដ្ឋាភិបាល ក្រសួងអប់រំ និងឯឧត្តមសាកលវិទ្យាធិការ ឯឧត្តមសាកល វិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យគ្រប់ៗរូប នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំពង្រឹងវិស័យអប់រំ និងបង្ហាត់បង្រៀនដោយស្មោះអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្តល់និងផ្ទេរនូវពុទ្ធិដើម្បីឲខ្ញុំបាទបានក្រេបយកនូវចំណេះដឹងទាំងនេះ។

លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រចារ្យដឹកនាំការស្រាវជ្រាវ និងបង្ហាត់បង្ហាញ នៃរបៀបសរសេរ និងរៀបចំសារណានេះ ឲចេញជារូបរាង ជាពិសេស ចំពោះការខិតខំប្រឹងប្រែង ជួយពន្យល់ណែនាំយ៉ាងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ដល់ខ្ញុំបាទដោយផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។

ជាចុងបញ្ចប់ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដល់ បងៗ ដែលជាម្ចាស់គណនីចែករំលែកនូវចំណេះដឹងផ្នែកច្បាប់ ដែលបានជួយខ្ញុំបាទ តាមរយៈការផ្តល់ជាឯកសារជាជំនួយសម្រាប់សារណា ព្រមទាំងផ្តល់ពេលវេលាសម្រាប់ការឆ្លើយតប នូវរាល់សំណួរដែលខ្ញុំបាទមានចម្ងល់អំពីការស្រាវជ្រាវអំពីប្រធានបទមួយនេះផងដែរ។

ដល់សាស្ត្រាចារ្យផ្នែកច្បាប់ និងរដ្ឋបាលទាំងអស់ ដែលតែងតែស្រាយនូវចម្ងល់ និងផ្តល់ជាមតិយោបល់រិះគន់ដើម្បីស្ថាបនារហូតដល់សារណានេះបញ្ចប់ដោយមានន័យនឹងខ្លឹមសារ។

យើងខ្ញុំ សូមគោរពជូនដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម សាស្ត្រាចារ្យ សិស្សច្បង មិត្តភ្កិនិងបងប្អូនប្រុសស្រី ទាំងអស់ឲជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

កិច្ចការស្រាវជ្រាវនេះ គឺជាជំនួយផ្នែកស្មារតីដល់បណ្ដាអ្នកច្បាប់ដូចជា មេធាវី ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី សារការី អាជ្ញាសាលា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអនុវត្តច្បាប់ និងគ្រប់និសិត្សច្បាប់។

ការរៀបរៀងនេះ និងចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ក៏ដូចជាលើកស្ទួយវិស័យមួយសំខាន់ក្នុងប្រព័ន្ធយុត្តិធម៌គឺនីតិវិធីព្រហ្មទណ្ឌ តាមរយៈខ្លឹមសារនៃប្រធានបទ ដែលបង្ហាញជូនអ្នកច្បាប់ និងសាធារណៈជនទូទៅ អំពីគោលបំណង ឧត្តមគតិ និងការប្ដេជ្ញាចិត្តរបស់អ្នករៀបរៀងក្នុងការពុះពារ បម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញឲ្យច្បាស់អំពីការយល់ឃើញទាក់ទងទៅនឹងនីតិវិធីព្រហ្មទណ្ឌ ដើម្បីបន្តកសាង ស្ដា និងការពារនីតិរដ្ឋឲ្យឆ្ពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ ស្របតាមឆន្ទះនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរដែរតែងតែស្រែករកយុត្តិធម៌។

ក្នុងស្មារតីនេះ ក្នុងនាមខ្ញុំជានិសិត្សនឹងព្យាយាមធ្វើឲ្យប្រធានបទមួយនេះ ផ្ដល់ជាអត្ថប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេស មន្ត្រីនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថដែលទទួលបាននូវសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាមន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដទៃដែលមាននីតិសម្បទាពិសេសសំរាប់ពិនិត្យបទល្មើសមួយចំនួនដែរ ។

យើងខ្ញុំសូមសម្ដែងនូវសេចក្ដីគោរព និង ការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ស្រទាប់ដែលបានផ្ដល់ជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។ ដោយផ្អែកលើការគាំទ្រនេះហើយ ទើបក្នុងនាមខ្ញុំជានិសិត្ស និងខិតខំសិក្សារៀនសូត្របន្ថែម និងខិតខំរៀបរៀងដោយចំណាយនូវកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងប្រាជ្ញា ដែលមានពីការសិក្សាស្រាវជ្រាវមកធ្វើការរៀបរៀង ចងក្រង ដើម្បីពន្យល់បកស្រាយឲ្យបានលំអិតលើប្រធានបទស្ដីពី " **ការឃាត់ខ្លួន និង ការឃុំខ្លួន** " ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**.......................................................................................១

**ជំពូកទី១**

**ការឃាត់ខ្លួន**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការឃាត់ខ្លួន** ......................................................២

**កថាខណ្ឌ១-និយមន័យនៃការឃាត់ខ្លួន**...........................................................២

**កថាខណ្ឌ២-មូលហេតុនៃការឃាត់ខ្លួន**...........................................................២

២.១.រក្សាទុកជនសង្ស័យឬជនជាប់សង្ស័យ.......................................................៣

២.២.រក្សាទុកភស្តុតាងឬព័ត៌មាន.....................................................................៣

**កថាខណ្ឌ៣-លក្ខខណ្ឌនៃការឃាត់ខ្លួន**...........................................................៤

៣.១.ការឃាត់ខ្លួនក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈឹមជាក់ស្តែង ..................................៤

៣.២.ការឃាត់ខ្លួនក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈឹមមិនជាក់ស្តែង ..............................៧

**កថាខណ្ឌ៤-នីតិវិធីនៃការឃាត់ខ្លួន**...............................................................៧

៤.១.ការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង ...........................................................៧

៤.២.ការឃាត់ខ្លួនក្នុងបទល្មើសមិនជាក់ស្តែង .......................................................៩

**ផ្នែកទី២៖ កំណត់ហេតុក្នុងពេលឃាត់ខ្លួន** ......................................................១០

**កថាខណ្ឌ១-កំណត់ហេតុស្តីពីការឃាត់ខ្លួន**......................................................១០

១.១. មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីមូលហេតុនៃការឃាត់ខ្លួន..........................១០

១.២. មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីសិទ្ធិដែលជននោះមានក្នុងពេលឃាត់ខ្លួន..........១១

១.៣. ចំណុចត្រូវសរសេរក្នុងកំណត់ហេតុស្តីពីការឃាត់ខ្លួន .......................................១២

**កថាខណ្ឌ២-បញ្ជីនៃការឃាត់ខ្លួន** ..................................................................១២

២.១. ជនដែលត្រូវឃាត់ត្រូវមានក្នុងបញ្ជីនៃការឃាត់ខ្លួន .........................................១២

២.២. ចំណុចដែលត្រូវសរសេរនៅពេលចុះក្នុងបញ្ជី ...................................................១៣

**កថាខណ្ឌ៣-កំណត់ហេតុសរុបនៃការឃាត់ខ្លួន**....................................................១៣

៣.១.គ្រប់ការឃាត់ខ្លួនត្រូវមានកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួន ..............................១៣

៣.២.ចំណុចដែលត្រូវសរសេរក្នុងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ...............................១៤

## ជំពូកទី២

## ការចោទប្រកាន់និងការឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ


**ផ្នែកទី១៖នីតិវិធីនៃការចោទប្រកាន់** ........ ១៥

**កថាខណ្ឌ១-សញ្ញាណទូទៅនៃការចោទប្រកាន់** ........ ១៥

១.១.អត្ថន័យនៃការចោទប្រកាន់ ........ ១៥

១.២.អាជ្ញាធរដែលទទួលបន្ទុកក្នុងការចោទប្រកាន់ ........ ១៥

១.៣.ប្រភេទនៃការចោទប្រកាន់ ........ ១៥

**កថាខណ្ឌ២-ការបើកការស៊ើបសួរ** ........ ១៦

២.១.គោលបំណងនៃការស៊ើបសួរ ........ ១៦

២.២.យុត្តាធិកានៃការស៊ើបសួរ ........ ១៦

២.៣.លក្ខខណ្ឌនៃការបើកការស៊ើបសួរ ........ ១៧

២.៤.នីតិវិធីនៃការបើកការស៊ើបសួរ ........ ១៨

**កថាខណ្ឌ៣-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់** ........ ១៩

៣.១.លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ១៩

៣.២.នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២០

**ផ្នែកទី២៖ការឃុំខ្លួនបណ្ដោះអាសន្ន** ........ ២១

**កថាខណ្ឌ១-មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ ២១

១.១.ដើម្បីបញ្ចប់បទល្មើសឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ........ ២២

១.២.ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមាន ការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត ........ ២២

១.៣.ដើម្បីរក្សាភស្តុតាងឬតម្រុយជាសម្ភារៈ ........ ២៣

១.៤.ដើម្បីធានារក្សាជនត្រូវចោទទុនជូនតុលាការចាត់ការតាមនីតិវិធី ........ ២៣

១.៥.ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ ........ ២៣

១.៦.ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ........ ២៤

**កថាខណ្ឌ២-នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ ២៤

២.១.ការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ........ ២៤

២.១.១.ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន ........ ២៤

២.១.២.ការឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ទាល់ខ្លួនបន្ទាប់ពីស្នើយោបល់ពីព្រះរាជអាជ្ញា.២៥

២.១.៣.ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា ........ ២៦

២.១.៤.ការឃុំខ្លួនក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ....................................................២៨
២.២.សៀវភៅឃុំខ្លួនបណ្ដោះអាសន្ន .....................................................................៣០
២.២.១.កំណត់ហេតុស្ដីពីបញ្ជីជនជាប់ឃុំខ្លួនបណ្ដោះអាសន្ន ........................................៣១
២.២.២.ទំរង់ពិស្ដារស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន ......................................................៣១
២.៣.រយះពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមុនពេលសវនាការ .......................................៣២
២.៣.១.ការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជនករណីបទឧក្រិដ្ឋឬបទមជ្ឈឹម....................៣២
២.៣.២.ការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនករណីបទឧក្រិដ្ឋឬបទមជ្ឈឹម.................៣៣
២.៣.៣.ឧប្បទេវហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន .....................................................៣៤
២.៤.សិទ្ធិមានមេធាវីសង្គ្រោះផ្នែកច្បាប់បន្ទាប់ពីការឃុំខ្លួន ..........................................៣៥
២.៤.១.សិទ្ធិវិជ្ជាជីវះរបស់មេធាវី ...............................................................................៣៧
២.៤.២.សិទ្ធិមានមេធាវីក្រោយការសម្រេចលើការឃុំការខ្លួន ...........................................៣៧
២.៤.៣.សិទ្ធិមានមេធាវីចំពោះអនីតិជនលើការឃុំខ្លួន .................................................៣៨
**ផ្នែកទី៣៖នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមស៊ើបសួរ** ...............................៤០
**កថាខណ្ឌ១-ការសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន**...................................................៤០
១.១.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម .............................................................................. ៤០
១.២.នីតិវិធីមុនអង្គសេចក្ដី ........................................................................................ ៤១
១.៣.នីតិវិធីក្នុងអង្គសេចក្ដី ........................................................................................ ៤១
**កថាខណ្ឌ២-ការប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** .........................៤៤
២.១.ជនដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍...........................................................................៤៥
២.២.សិទ្ធិប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា .....................................................................៤៦
២.៣.អំណាចរបស់សាលាឧទ្ធរណ៍ ...............................................................................៤៦
២.៤.ការឃុំខ្លួនជនជាប់ចោទក្នុងពេលជាប់បណ្ដឹងឧទ្ធរណ៍ ..............................................៤៧
**សេចក្ដីសន្និដ្ឋាន** .................................................................................................. ៤៩
**អនុសាសន៍** ........................................................................................................៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ស្ថិតក្នុងបរិបទសង្គមមួយដែលប្រទេសកម្ពុជាប្រកាន់ភ្ជាប់នូវគោលការណ៍នីតិរដ្ឋ ដែរធ្វើឲ្យប្រទេសកម្ពុជាមានការប្រែប្រួល និងមានភាពរីកចម្រើនយ៉ាងខ្លាំងក្លាទាំងវិស័យច្បាប់ និងវិស័យយុត្តិធម៌ ដូច្នេះការប្រើប្រាស់ច្បាប់ ឬយុត្តិសាស្ត្រតុលាការ គឺជារឿងមួយដ៏ចាំបាច់ក្នុងការបំពេញតម្រូវការប្រជាជនដើម្បីស្វែងរកនូវយុត្តិធម៌មួយដ៏ពិតប្រាកដជូនពួកគាត់ ពោលគឺយុត្តិធម៌ដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌពេលវេលាមានន័យថាយុត្តិធម៌គឺជារឿងមួយដ៏សំខាន់ប៉ុន្តែប្រសិនបើនីតិវិធី នៃការស្វែងរកយុត្តិធម៌នោះត្រូវបានអូសបន្លាយថេរវេលាយូនោះ យុត្តិធម៌នោះគឺមិនត្រូវបានចាត់ទុកជាយុត្តិធម៌ពិតប្រាកដទេ។ ម្យ៉ាងវិញទៀតក៏ដូចជានីតិវិធីនៃការឃាត់ និងការឃុំខ្លួនផងដែរ ដែលជានីតិវិធីស្របច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដ៏មានសារៈសំខាន់ និងចាំបាច់ក្នុងករណីបទល្មើសកំរិតមធ្យមឡើងទៅដើម្បីស្វែងរកពិរុទ្ធភាពរបស់ជនល្មើស ឬរកមុខជនសង្ស័យណាម្នាក់ឬ ច្រើនហើយក៏ជាការស្វែងរកសំណងនៃការខូចខាត់ផ្សេងៗដល់ជនរងគ្រោះផងដែរ។ ការឃាត់ខ្លួន និងការឃុំខ្លួនបានរួមចំណែកយ៉ាងសកម្មក្នុងការស្វែងរកយុត្តិធម៌ពិតប្រាកដជូនប្រជាពលរដ្ឋខ្មែរក៏ដូចជាផ្តត់គំនិតនៃនីតិវិធីព្រហ្មទណ្ឌផងដែរក្នុងការយល់ដឹង ដើម្បីទប់ស្កាត់ការអនុវត្តខុសនីតិវិធីដែលមានចែងក្នុងការច្បាប់ ព្រោះវាអាចបង្កឡើងជាភាពអយុត្តិធម៌តាមរយៈរូបភាពណាមួយ មិនត្រឹមតែប៉ុណ្ណោះជួយឲ្យមន្ត្រីនគរបាលយុត្តិធម៌មានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីឲ្យវាសមស្របនឹងបរិបទនីតិរដ្ឋនៃការរីកចម្រើនរបស់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ។

ស្របតាមការរីកចម្រើន និងការវិវត្តរបស់សង្គមជាតិ យើងជាអ្នកសិក្សាផ្នែកច្បាប់ត្រូវតែយល់ដឹងអំពីស្ថាប័ននីមួយៗរបស់រដ្ឋដែលទាក់ទងទៅនឹងវិស័យព្រហ្មទណ្ឌ ឲ្យបានច្បាស់លាស់ថាតើស្ថាប័នណាខ្លះដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌ? ហើយស្ថាប័ននោះមានមុខងារធ្វើអ្វីខ្លះ? ហើយស្ថាប័ននោះបង្កើតឡើងយ៉ាងដូចម្តេចដែរ? តើបានកើតឡើងតាំងពីពេលណា? ហើយមានការវិវត្តនិងមានសារៈប្រយោជន៍អ្វីខ្លះ?

ក្នុងគោលបំណងនៃការជ្រើសរើសប្រធានបទនេះ គឺដើម្បីចូលរួមជំរុញឲ្យសង្គមមានការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អក្នុងរឿងព្រហ្មទណ្ឌ មានយុត្តិធម៌ក្នុងសង្គមជាតិ និងបង្កលក្ខណៈងាយស្រួលជាងមុន ក្នុងការគ្រប់គ្រងទៅលើបទល្មើសផ្សេងៗ សំដៅធ្វើយ៉ាងណាឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានសុខសន្តិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ ជាងនេះទៅទៀតគឺផ្តល់ផលប្រយោជន៍ដល់យើងជាអ្នកសិក្សា ដើម្បីធ្វើការប្រៀបធៀបការកើតឡើងនៃនីតិវិធីព្រហ្មទណ្ឌព្រមទាំងភាពជោគជ័យ និងភាពអន់ថយតើបានកើតឡើងយ៉ាងដូចម្តេចខ្លះ? ដើម្បីធ្វើជាបទពិសោធក្នុងការយល់ដឹង និងការអនុវត្តរាល់សកម្មភាពផ្សេងៗទៀតក្នុងវិស័យព្រហ្មទណ្ឌឲ្យមានការវិវត្តទៅរកភាពរីកចម្រើនជឿនលឿនទៅថ្ងៃអនាគត។

# ជំពូកទី១
# ការឃាត់ខ្លួន
## ផ្នែកទី១៖សញ្ញាណទូទៅនៃការឃាត់ខ្លួន

ជាទូទៅការឃាត់ខ្លួនគឺមានរូបភាពដូចជាការបង្អាក ការបញ្ឈប់ ការឃាត់ទុក ឬជាសកម្មភាពផ្សេងៗទៀតដែលរិតត្បិតសិទ្ធិសេរីភាពមួយចំនួនដោយអាណត្តិតាមរយៈបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់សិទ្ធិអំណាចមួយចំនួនឲ្យក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។

**កថាខណ្ឌ១-និយមន័យនៃការឃាត់ខ្លួន**

ការឃាត់ខ្លួនក្នុងន័យនេះគឺមានន័យថាជាការបញ្ជាពីតុលាការ ដែលបង្គាប់ឲ្យឃាត់ខ្លួនជនណាម្នាក់ដែលតុលាការសង្ស័យថាមានជាប់ពិរុទ្ធភាព ឬអាចឲ្យនិយមន័យម្យ៉ាងទៀតថាជាការមិនអនុញ្ញាតឲ្យជនដែលត្រូវឃាត់នោះមានសេរីក្នុងការដើរហើរក្នុងអំឡុងពេលមិនលើស ៤៨ ម៉ោង ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីសាធារណៈដទៃទៀត ដែលច្បាប់ពិសេសផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ហើយត្រូវមានហេតុផលត្រឹមត្រូវក្នុងការឃាត់ផងដែរដោយយោងទៅតាមមាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧។

យ៉ាងណាមិញ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំបានធ្វើការបកស្រាយនូវនិយមន័យនៃពាក្យថា "ឃាត់ខ្លួន" ប៉ុន្តែយើងតែងតែជួបប្រទះឃើញនូវហេតុការណ៍នេះជារឿយៗនៅក្នុងសង្គមបច្ចុប្បន្ន ដូចនេះយើងអាចសន្និដ្ឋានបានថាការឃាត់ខ្លួនគឺជាសកម្មភាពដែលធ្វើឡើងដោយមន្ត្រីដែលមានសមត្ថកិច្ច ឬកាលបើស្ថិតនៅក្នុងករណីជាក់ស្តែងសាធារណៈជនក៏អាចមានសិទ្ធិ ក្នុងការឃាត់ជននោះបានដែរ កាលបើស្ថិតក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ សូមបញ្ជាក់ផងដែរថានីតិវិធីនៃការឃាត់ខ្លួនជនសង្ស័យ ឬជនល្មើសត្រូវគោរពទៅតាមគោលការណ៍សិទ្ធិមនុស្សមានន័យថាមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីសិទ្ធិមួយចំនួនដែលជននោះមានក្នុងស្ថានភាពនោះ។

**កថាខណ្ឌ២-មូលហេតុនៃការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែមានមូលហេតុត្រឹមត្រូវក្នុងការឃាត់ខ្លួនជនណាដោយស្របទៅតាមក្រមនេះ។ រាល់ការស្វែងរក ការខិតខំរបស់មន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវរងការប្តឹងមោឃៈកាលបើការឃាត់ខ្លួននោះមិនគោរពទៅតាមអ្វីដែលបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧។

**២.១.រក្សាទុកជនសង្ស័យឬជនជាប់សង្ស័យ**

ជាទូទៅនៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌមន្ត្រីនគរបាលយុត្តិធម៌ គឺចាំបាច់ក្នុងការរក្សាទុកជនដែលខ្លួនសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬបានបង្កសកម្មភាពណាមួយដែលផ្ទុយពីច្បាប់ ក្នុងគោលបំណងបង្ការកុំឲ្យជននោះទៅប្រព្រឹត្តបទល្មើសជាបន្តបន្ទាប់ ឬក្នុងករណីរក្សាទុកជននោះកុំឲ្យទៅលុបបំផ្លាញដានដែលខ្លួនបានប្រព្រឹត្ត ឬជៀសវាងជននោះទៅកំរាមកំហែង សំលុត ឬវាយប្រហារតាមរយៈផ្លូវចិត្តឬដោយផ្ទាល់ទៅលើសាក្សីក្នុងការឆ្លើយនូវចម្លើយណាមួយដែលខ្លួនបានប្រព្រឹត្ត។ ជាធម្មតាមនុស្សមិនសប្បាយចិត្តទេពេលចាញ់ក្តី ឬពេលមានតតិយជនចូលមកជួយភាគីដែលកំពុងតតាំងនឹងខ្លួនព្រោះវាជាបន្ទុកមួយបន្ថែមមកលើខ្លួន ដូចនេះទើបច្បាប់ចែងក្នុងការទប់ស្កាត់សកម្មភាពនេះជាមុន មិនតែប៉ុណ្ណោះច្បាប់ក៏បានប្រគល់នូវសិទ្ធិអំណាចជាច្រើនឲ្យទៅមន្ត្រីមានសមត្ថកិច្ចក្នុងការចាត់ការហេតុការណ៍ទាំងនេះផងដែរ។ ដូចនេះការរក្សាទុកជនណាម្នាក់គឺមានសារៈសំខាន់ណាស់នៅក្នុងកិច្ចនីតិវិធីស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធំ ក្នុងការស្វែងរកតម្រុយបន្តបន្ទាប់ក្នុងការផ្តន្ទាទោសជនដែលបានរំលោភបំពានសិទ្ធិប្រជាពលរដ្ឋស្លូតត្រង់។

**២.២.ការរក្សាទុកភស្តុតាងឬព័ត៌មាន**

ការរក្សាទុកជនសង្ស័យ ឬជនល្មើសគឺពិតជាសំខាន់ណាស់ ប៉ុន្តែត្រង់ចំណុចនេះមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចធំទូលាយណាស់ ក្នុងការធ្វើការឃាត់ខ្លួនផងដែរទៅលើជនដែលខ្លួនគិតថាមានសារៈសំខាន់ដែលអាចផ្តល់នូវចម្លើយចាំបាច់ណាមួយ ឬជនដែលបានឃើញអង្គហេតុហើយអាចបង្ហាញពីសកម្មភាពត្រាបតាមជនល្មើស ឬអាចជននោះអាចចង្អុលប្រាប់ផ្ទាល់ថាតើនរណាជាអ្នកប្រព្រឹត្តបទល្មើសប្រសិនបើគាត់បដិសេធក្នុងការផ្តល់នូវចម្លើយណាមួយ ដូចនេះមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនទៅលើបុគ្គលរូបនោះបាន។ កាលដែលច្បាប់ប្រគល់សិទ្ធិអំណាចមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការឃាត់ខ្លួនជនណាម្នាក់គឺដោយសារតែដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋស្លូតត្រង់ តាមរយៈការប្រើប្រាសសិទ្ធិនេះក្នុងការបំពេញបេសកម្មរបស់ខ្លួន កុំឲ្យជនល្មើសអាចបន្តធ្វើសកម្មភាពនោះបន្តទៀត ឬកាលបើសក្សី ឬអ្នកដែលនគរបាលយុត្តិធម៌សង្ស័យថាអាចផ្តល់ព័ត៌មានតែនៅតែបដិសេធមិនផ្តល់ព័ត៌មាន។ ដូចនេះការឃាត់ខ្លួនជនដែលនគរបាលសង្ស័យថាអាចផ្តល់ជាព័ត៌មាន ជាសាក្សី ជាភស្តុតាង និងជាអ្វីៗផ្សេងៗទៀតដែលអាចផ្តល់ផលប្រយោជន៍ ឬតម្រុយក្នុងការស៊ើបអង្កេតពិតជាសកម្មភាពចាំបាច់ហើយមានសារៈសំខាន់បំផុតដើម្បីក្តោបក្តាបសំណុំរឿងឲ្យបានមូលដូចនេះវានឹងបង្កភាពងាយស្រួលមួយកំរិតទៀតក្នុងការស៊ើបអង្កេត។

សូមបញ្ជាក់ថារាល់នីតិវិធីដែលត្រូវធ្វើឡើងខាងលើនេះ ដូចជាការឃាត់ខ្លួនជនល្មើសឬជនដែលសង្ស័យថាអាចផ្តល់នូវព័ត៌មាន ឬហេតុការណ៍ផ្សេងៗ ត្រូវគោរពឲ្យបានខ្ជាប់ខ្ជួនបំផុតនូវគោលការណ៍ដែល

ច្បាប់បានកំណត់។ ដើម្បីអនុវត្តតាមគោលការណ៍នេះបានមន្ត្រីនគរបាលយុត្តិធម៌ដំបូងបំផុតត្រូវដឹងឲ្យច្បាស់ថា «តើបទល្មើសនោះជាបទល្មើសជាក់ស្តែងឬជាបទល្មើសមិនជាក់ស្តែង?» ព្រោះនៅក្នុងបទល្មើសនីមួយៗមានគោលការណ៍ក្នុងការគ្រប់គ្រង់ខុសគ្នាបន្តិចបន្តួចដែលវាធ្វើឲ្យ មន្ត្រីនគរបាលយុត្តិធម៌ភាគច្រើនមានការយល់ច្រលំទៅលើគោលការណ៍ទាំងនោះ។

ដូចនេះយើងឃើញថានីតិវិធីនៃការឃាត់ខ្លួនជនណាម្នាក់ ត្រូវគោរពគោលការណ៍មួយចំនួនដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ត្រង់មាត្រា៩៦ ដល់ ១០២ (ចំពោះបទឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែង) និងត្រង់មាត្រា១១៦ (បទឧក្រិដ្ឋ ឬមជ្ឈឹមមិនជាក់ស្តែង)។ កាលបើមន្ត្រីនគរបាលយុត្តិធម៌ចុះអនុវត្តខុសនីតិវិធីដែលច្បាប់បានចែង នោះរាល់ភស្តុតាង វត្ថុតាង ព័ត៌មាន ឬតម្រុយផ្សេងៗទៀតនឹងក្លាយជាកម្មវត្ថុដែលនឹងត្រូវបានប្តឹងមោឃភាព មានន័យថារាល់ការឃាត់បាន ឬយកបានទាំងប៉ុន្មាននឹងគិតទុកដូចជាអស្សាបង់ ហើយមន្ត្រីនគរបាលយុត្តិធម៌មិនអាចយកវត្ថុទាំងនោះទៅដាក់នៅកន្លែងដើមបានទៀតនោះទេ។ ផ្ទុយទៅវិញមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំព្រះរាជអាជ្ញាក្នុងការបើកការស៊ើបអង្កេតសារជាថ្មីបាន ប៉ុន្តែជាទូទៅមិនអាចរកឃើញពីតម្រុយក្នុងការចោទប្រកាន់ជននោះបានទេ ព្រោះការស៊ើបអង្កេតលើកទី១បានចាប់យកអស់ទៅហើយ។

## **កថាខណ្ឌ៣-លក្ខខណ្ឌនៃការឃាត់ខ្លួន**

### **៣.១.ការឃាត់ខ្លួនក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈឹមជាក់ស្តែង**

យោងទៅតាមមាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់ថាគ្រប់នីតិវិធីនៃការឃាត់ខ្លួនក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈឹមជាក់ស្តែងត្រូវគោរពទៅតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ។

ដូចដែលបានបញ្ជាក់ខាងលើរួចមកហើយថា ដើម្បីធ្វើការឃាត់ខ្លួនជនណាម្នាក់ត្រូវគោរពនូវលក្ខខណ្ឌដែលច្បាប់បានកំណត់ ហើយត្រូវដឹងឲ្យច្បាស់ទាក់ទងទៅនឹងប្រភេទនៃបទល្មើសថាតើជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង។បើយោងតាមមាត្រា៨៦បានកំណត់យ៉ាងច្បាស់នូវនិយមន័យនៃបទល្មើសជាក់ស្តែងថាជា៖

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលប្រព្រឹត្តរួចភ្លាមនឹងត្រូវចាត់ទុកជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែងដែរកាលណាក្រោយពេលមានបទល្មើសរួចបន្តិចមក

- ជនដែលគេសង្ស័យត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកីង

- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាក់ស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងៗទៀតដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស

ជារឿយៗមានបងប្អូនប្រជាជន ឬបងប្អូនជាមន្ត្រីនគរបាលយុត្តិធម៌ជាច្រើននៅមានការស្រពិចស្រពិល និងពិបាកក្នុងការកំណត់ថាជាបទល្មើសប្រភេទជាក់ស្តែង ឬមិនជាក់ស្តែងព្រោះបទល្មើសទាំងនេះអាចនាំមកនូវភាពស្មុកស្មាញនឹងពិបាកក្នុងការវែកញែកផងដែរសម្រាប់ប្រជាពលរដ្ឋធម្មតានិងមន្ត្រីអនុវត្ត។ ដូចនេះដើម្បីដោះស្រាយចម្ងល់ សូមបងប្អូនចង់ចាំថាដើម្បីកំណត់បទល្មើសនោះជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែងយើងត្រូវផ្តោតសំខាន់លើតួអង្គមន្ត្រីនគរបាលយុត្តិធម៌តាមរយៈទទួលយកសំណុំរឿងពីជនរងគ្រោះ ។ សំរាប់ជនរងគ្រោះផ្ទាល់គឺគាត់តែងគិតថាជាបទល្មើសដែលកើតឡើងនៅចំពោះមុខគាត់នោះជាបទល្មើសជាក់ស្តែង ព្រោះក្នុងរយះពេល ៣ ទៅ ៤ ថ្ងៃបន្ទាប់ពីគាត់ស្វែងរកវត្ថុដែលខ្លួនបានបាត់មិនឃើញក៏ដោយ ក៏គាត់គិតថាជាក់ស្តែង តែតាមពិតមិនមែននោះទេ។ ដូចនេះត្រូវរាប់ចាប់ពីកិច្ចនីតិវិធីមន្ត្រីនគរបាលយុត្តិធម៌ទទួលសំណុំ ហើយមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់នោះជាដំបូងត្រូវកសាងសំណុំរឿងនឹងកំណត់ប្រភេទនៃរឿងហេតុរួចបញ្ជូនទៅឲ្យតំណាងអយ្យការ។

ជាទូទៅការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តធម៌មានសិទ្ធិអំណាចធំទូលាយក្នុងការបំពេញបេសកម្មរបស់ខ្លួន ដើម្បីរក្សាសន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ។ ជាក់ស្តែងក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែង មិនមែនមានតែនគរបាលយុត្តិធម៌ទេដែលអាចធ្វើការឃាត់ខ្លួនជនសង្ស័យ ឬជនដែលប្រព្រឹត្តបទល្មើស។ ផ្ទុយទៅវិញប្រជាពលរដ្ឋទូទៅទាំងអស់ដែលនៅតាមបណ្តោយកន្លែងកើតហេតុ ឬបានប្រទះឃើញរឿងហេតុនោះកំពុងកើតឡើង អាចធ្វើការឃាត់ខ្លួនជននោះបានដែលមិនប្រកាន់ការងារមុខរបរអ្វីនោះទេ ព្រោះក្នុងករណីចាំបាច់មានតែប្រជាពលរដ្ឋដែលរស់នៅតាមមូលដ្ឋាននោះទេដែលអាចជាសាក្សីផង នឹងជាអ្នកដើរតួនាទីមន្ត្រីនគរបាលផង។ ប៉ុន្តែសូមបញ្ជាក់ថាប្រជាពលរដ្ឋទូទៅដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌បន្ទាប់ពីធ្វើការឃាត់ខ្លួនជនណាម្នាក់ដែលខ្លួនសង្ស័យ ក្រោយឃាត់បានភ្លាមត្រូវបញ្ជូនខ្លួនជននោះ និងរាយការណ៍ភ្លាមទៅការិយាល័យមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតខ្លួនបំផុត។ ដូចជានៅក្នុងករណីលោក A វាយលោក B នឹងដំបងក្នុងគោលបំណងចង់បានម៉ូតូរបស់លោក B ស្រាប់តែនៅពេលនោះមានមនុស្សមួយក្រុមបានប្រទះឃើញហេតុការណ៍នេះ ក្នុងករណីនេះមនុស្សមួយក្រុមនោះមានសិទ្ធិយ៉ាងពេញលេញក្នុងការចូលរួមជួយអន្តាគមន៍ ឬជួយចាប់ជនល្មើស ព្រោះសកម្មភាពនោះគឺជាបទល្មើសមជ្ឈឹមជាក់ស្តែងដើម្បីបញ្ជូនខ្លួនជននោះទៅកសាងសំណុំរឿងតាមនីតិវិធីបន្ត។ ចំណែកនៅក្នុងករណីមួយទៀតដែលមានមនុស្សភាគច្រើននៅមិនទាន់យល់បានច្បាស់គឺករណីលោក ក ត្រូវបានលោក ខ ចូលទៅលួចកង់នៅក្នុងផ្ទះរបស់លោក ក ស្រាប់តែស្អែកឡើងលោក ក បានដឹងភ្លាមក៏ចេញទៅតាមរកកង់របស់ខ្លួនភ្លាម។ រកបាន ៣ ទៅ ៤ ថ្ងៃនៅតែរកមិនឃើញក៏គាត់សំរេចចិត្តទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ក្នុងសង្កាត់របស់គាត់ផ្ទាល់។ នៅ

ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ក្រោយពីទទួលបានពាក្យបណ្តឹងពីជនរងគ្រោះ គាត់នឹងកសាងសំណុំរឿង ហើយបញ្ជូនទៅព្រះរាជអាជ្ញាភ្លាម។ ក្នុងករណីខាងលើយើងឃើញថាចំពោះជនរងគ្រោះគឺបានតាមរកវត្ថុដែលបាត់នោះប្រកៀកតែម្តងតែរកមិនឃើញទើបមកដាក់ពាក្យបណ្តឹង ដូចនេះសំរាប់ជនរងគ្រោះគាត់អាចនឹងគិតថាករណីខាងលើជាបទល្មើសជាក់ស្តែង។ ផ្ទុយទៅវិញករណីខាងលើនេះគឺជាបទល្មើសមិនជាក់ស្តែងទេ ព្រោះរឿងហេតុកើតឡើងបាន ៣ ទៅ ៤ ថ្ងៃមកហើយទើបមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹងពីជនរងគ្រោះឬទើបតែដឹងជាដើម។

យោងទៅតាមមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ យើងឃើញថាមានករណីពិសេសមួយដែលអាចចាត់ទុកថាជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែង បើទោះបីមិនស្ថិតក្នុងលក្ខខណ្ឌនៃមាត្រា ៨៦ ក៏ដោយក៏អំពើនោះត្រូវចាត់ទុកដូចបទឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែងដែរ កាលបើអំពើនោះបានប្រព្រឹត្តនៅក្នុងទីកន្លែងមួយដែលអ្នកកាន់កាប់ទីកន្លែងនោះបានសុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ដែលនៅតាមមូលដ្ឋានទីកន្លែងនោះ អនុញ្ញាតឲ្យចុះទៅពិនិត្យ និងកសាងកំណត់ហេតុជាដើម។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវដឹកនាំដោយព្រះរាជអាជ្ញាមួយរូប អាចបើកការស៊ើបអង្កេតក្នុងករណីជាក់ស្តែងបានព្រោះច្បាប់យល់ឃើញថាពេលដែលអំពើល្មើសបានប្រព្រឹត្ត ម្ចាស់នៃទ្រព្យពុំមានវត្តមាននៅទីនោះទេ ដូចនេះហើយទើបច្បាប់ចាត់ចូលជាករណីពិសេស។ ឧទាហរណ៍ដូចករណីសិក្សាមួយដែលលោក ក ត្រូវជាម្ចាស់នៃអចលនទ្រព្យមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញគឺផ្ទះមួយល្វែង នៅថ្ងៃមួយពេលយប់ត្រូវបានចោរចូលទៅកាប់គាស់លួចបានវត្ថុ និងចលវត្ថុមួយចំនួន ហើយការលួចនោះមិនមានការដឹងឮពីសំណាក់អ្នកជិតខាងទេព្រោះអ្នកជិតខាងបានសំរាក់អស់។ លុះដល់ថ្ងៃមួយបន្ទាប់ពីលោក ក បានមកដល់ផ្ទះរបស់គាត់ទើបដឹងថាត្រូវបានចោរចូលលួច នឹកឃើញដូចនេះលោក ក ក៏អញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតខ្លួន ឲ្យមកពិនិត្យកន្លែងកើតហេតុ និងកសាងសំណុំរឿង។ ក្នុងករណីសិក្សាខាងលើឃើញថាពេលសកម្មភាពល្មើសកំពុងប្រព្រឹត្ត ម្ចាស់នៃអចលនទ្រព្យពុំមានវត្តមានោះទេដូចនេះសបញ្ជាក់ឲ្យឃើញថា បើទោះបីមិនចូលក្នុងលក្ខខណ្ឌនៃមាត្រា៨៦ក៏ដោយក៏សកម្មភាពនេះអាចចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ។

សរុបមកការកំណត់ជាមុនទៅលើប្រភេទនៃបទលល្មើសមុននឹងចាត់វិធានការអ្វីមួយទៅលើរឿងហេតុណាមួយគឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីការពារពីការប្តឹងមោឃៈភាពទៅលើរាល់វត្ថុតាង និងព័ត៌មានផ្សេងៗដែលរកបាន។ ច្រើនជាងនេះទៅទៀតវិធានការដែលត្រូវអនុវត្តរវាងបទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែងនេះមានភាពប្រហាក់ប្រហែលគ្នានិងខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ ហើយបន្ទាប់ពីនេះយើងនឹងក្រឡេចទៅមើលលក្ខខណ្ឌនៃបទល្មើសមិនជាក់ស្តែងវិញម្តង។

**៣.២.ការឃាត់ខ្លួនក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈឹមមិនជាក់ស្តែង**

ជាទូទៅយើងឃើញថានៅក្នុងបទល្មើសមិនជាក់ស្តែងសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានបង្រួមតូចជាងមុនដោយសារករណីរឿងហេតុនោះបានកើតឡើងរួចជាស្រេចហើយ មិនអាចអនុវត្តដោយបង្ខំ ឬប្រញាប់ប្រញាលបានទេពោលគឺ ត្រូវអនុវត្តទៅតាមវិធានដែលមានចែងក្នុងមាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បើយើងក្រឡេកមើលក្រមនីតិវិធីព្រហ្មទណ្ឌពុំបានឲ្យនិយមន័យនៃបទល្មើសមិនជាក់ស្តែងគ្រប់គ្រាន់នៅឡើង តែយើងអាចដឹងពីនិយមន័យរបស់វាតាមការឲ្យនិយមន័យបញ្ច្រាសពីនិយមន័យនៃមាត្រា ៨៦ បាន។ បទល្មើសមិនជាក់ស្តែងគឺជាបទល្មើសទាំងឡាយណាដែលការប្រព្រឹត្ត បានចប់សព្វគ្រប់ទៅហើយ ដូចជាគេប្រទះឃើញសាកសពបណ្តែកទឹកតាមទន្លេមក,គេប្រទះឃើញសាកសពមួយស្លាប់ស្ងួកនៅលើវាលស្មៅជាដើម។

បទល្មើសមិនជាក់ស្តែងនេះត្រូវបានគេបែកចែកជា២ប្រភេទទៀតគឺ៖

**១.<u>ស្គាល់សាវតាជនល្មើស</u>**: មានន័យថាបន្ទាប់ពីបទល្មើសបានប្រព្រឹត្តចប់សព្វគ្រប់ មន្ត្រីនគរបាលយុត្តិធម៌បានចុះទៅដល់ទីកន្លែងកើតហេតុ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ស្គាល់ឬចំណាំអត្តសញ្ញាណជនល្មើស ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុជុំវិញកន្លែងកើតហេតុប្រមូលវត្ថុតាងហើយអនុវត្តនីតិវិធីផ្លូវច្បាប់បន្ត។

**២.<u>មិនស្គាល់សាវតាជនល្មើស</u>** : បានសេចក្តីថាក្រោយពីមានបទល្មើសកើតឡើងព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្រាវជ្រាវរក ជនល្មើសដោយស៊ើបសួរប្រជាពលរដ្ឋដែលនៅជុំវិញនោះ ប្រសិនបើនៅតែរកមិនឃើញទៀតពេលនោះព្រះរាជអាជ្ញាត្រូវបង្អង់បណ្តឹងអាជ្ញាដើម្បីកុំឲ្យអាជ្ញាយុកាលនៃបទល្មើសផុតរលត់។

**<u>ចំណាំ</u>** : ព្រះរាជអាជ្ញាអាចបង្អង់បណ្តឹងអាជ្ញាបាន លុះត្រាតែដំណើរការនៃនីតិវិធីចាប់ផ្តើមហើយហើយនៅតែរកជនល្មើសមិនឃើញទៀត។[1]

## កថាខណ្ឌ៤-នីតិវិធីនៃការឃាត់ខ្លួន

**៤.១.ការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង**

ជាទូទៅការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែងគឺមិនមានដីកានោះទេ ព្រោះរឿងហេតុកើតឡើងភ្លាមៗ បើសិនជាចាំដល់មានដីកានោះជនល្មើសអាចនឹងគេចវេស ឬភៀសខ្លួនទៅកន្លែងផ្សេងបាត់។ ករណីចាំបាច់បែបនេះមន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញាគឺគ្រប់គ្រាន់

[1] សៀវភៅ «នីតិព្រហ្មទណ្ឌទូទៅ» រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង,ទំព័រទី ៥០

ហើយក្នុងការឃាត់ខ្លួនជននោះ។ ច្រើនជាងនេះទៅទៀតនៅក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែង ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិអំណាចដល់មនុស្សគ្រប់រូបក្នុងការចាប់ ឬឃាត់ខ្លួនជនល្មើសដែលកំពុងរត់គេចបានយ៉ាងពេញលេញ។ [2]ម្យ៉ាងវិញទៀតការឃាត់ខ្លួនគឺត្រូវធ្វើមិនឲ្យលើសពី ៤៨ ម៉ោងគិតចាប់ពីពេលដែលជនសង្ស័យ ឬជនល្មើសទៅដល់ការិយាល័យរដ្ឋបាលដែលជិតបំផុត ឬអង្គភាពនគរបាល ហើយចំពោះតែនីតិជនប៉ុណ្ណោះ ប្រសិនបើករណីបទឧក្រិដ្ឋដែលព្រះរាជអាជ្ញាគិតថាភស្តុតាងមិនទាន់ប្រមូលបានសព្វគ្រប់មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្នើសុំ២៤ ម៉ោងថែមទៀត។ រីឯចំពោះអនីតិជនវិញ បើយោងក្រមព្រហ្មទណ្ឌមាត្រា៩៦ កថាខណ្ឌទី ៣ចែងថាការពន្យាមិនអាចត្រូវយល់ព្រមបានទេប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវឃាត់ខ្លួនហួសរយះពេល៣៦ម៉ោងឡើយ។

ចំពោះបទមជ្ឈឹម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំមិនអាចត្រូវឃាត់ខ្លួនហួសរយះពេល២៤ម៉ោងឡើយ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវឃាត់ខ្លួនហួសរយះពេល៤៨ម៉ោងឡើយ។

ចំពោះបទមជ្ឈឹម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំមិនអាចត្រូវឃាត់ខ្លួនហួសរយះពេល៣៦ម៉ោងឡើយ។

ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។

បន្ទាប់ពីឃាត់ខ្លួនរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួននោះដែលកំណត់ហេតុនេះគឺមានសារៈសំខាន់ណាស់ក្នុងការកំណត់ជនណាម្នាក់ថាមានតម្រុយពិរុទ្ធភាព ហើយក៏មានអត្ថប្រយោជន៍ដែរចំពោះជនសង្ស័យក្នុងការដឹងថាតើខ្លួនត្រូវឃាត់ដោយមូលហេតុអ្វី ហើយប្រសិនបើកំណត់ហេតុនោះមានវិការៈត្រង់ចំណុចណាមួយ ជនសង្ស័យអាចប្តឹងមោឃៈបាន។ ម្យ៉ាងវិញទៀតកាលបើមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនជនសង្ស័យ ឬជនល្មើសលើសពី៤៨ ម៉ោង (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧) នឹងត្រូវផ្តន្ទាទោសតាមមាត្រា៦៤, មាត្រា៦៥, មាត្រា៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូចនេះបន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនខ្លួនជននោះទៅដល់អង្គភាពនគរបាលភ្លាម មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីមូលហេតុដែលសម្រេចធ្វើការឃាត់ខ្លួនទៅលើជននោះ ហើយប្រាប់អំពីសិទ្ធិមួយចំនួន

[2] មាត្រា ៨៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជាឆ្នាំ ២០០៧

ដែលជនសង្ស័យមានផងដែរដូចជាសិទ្ធិមានមេធាវីក្នុងអំឡុងពេលឃាត់ខ្លួន (មាត្រា៩៨) សិទ្ធិជំនួយពីគ្រូពេទ្យក្នុងអំឡុងពេលឃាត់ខ្លួន (មាត្រា៩៩) និងសិទ្ធិមានអ្នកបកប្រែជាដើម (មាត្រា៩៧វាក្យខណ្ឌទី២)។

បន្ទាប់ពីធ្វើកំណត់ហេតុរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុនោះឲ្យជនដែលត្រូវឃាត់ស្តាប់បើជននោះមិនចេះអក្សរ តែបើចេះត្រូវឲ្យជននោះអានដោយខ្លួនឯងដើម្បីឲ្យជននោះផ្តិតមេដៃ ឬចុះហត្ថលេខា។ ក្នុងករណីដែលជននោះបដិសេធមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែធ្វើនិទ្ទេសដោយបញ្ជាក់ថាជននោះបដិសេធ ឬមិនព្រមចុះហត្ថលេខារួចជាស្រេច។

សំរាប់អនិតិជនវិញ យើងឃើញថាមន្ត្រីនគរបាលយុត្តិធម៌ជាដំបូងក្រោយពីឃាត់ខ្លួនរួចត្រូវឲ្យដំណឹងតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ អាណាព្យាបាល អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជននោះភ្លាម (មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ យើងត្រូវចងចាំផងដែរថារាល់ទីកន្លែងនីមួយៗរបស់នគរបាល ឬកងរាជអាវុធហត្ថគឺមានបញ្ជីស្តីពីការឃាត់ខ្លួនសំរាប់ពិនិត្យថាតើជនណានឹងត្រូវឃាត់ខ្លួន ហើយជនណាដែលត្រូវបានឃាត់ខ្លួន (មាត្រា ១០១) ។ បញ្ជីស្តីពីការឃាត់ខ្លួននេះមានសារៈសំខាន់ណាស់ក្នុងការធានាថារាល់រូបវន្តបុគ្គលទាំងអស់ដែលត្រូវបានឃាត់នោះគឺត្រូវបានអនុវត្តវិធានស្តីពីការឃាត់តែនេះគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ។ ចំណែកឯកំណត់ហេតុសរុបនៃការឃាត់ខ្លួន ក៏មានអត្ថប្រយោជន៍ខ្លាំងដែរព្រោះវាជាកំណត់ហេតុដែលកត់ត្រារាល់សកម្មភាពដែលកើតឡើងជុំវិញការឃាត់ខ្លួននោះ (មាត្រា១០២)។ ដូចនេះរាល់រូបវន្តបុគ្គលទាំងអស់អាចសួររកឯកសារទាំងនេះបាន ប្រសិនបើខ្លួនត្រូវបានឃាត់ខ្លួនពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ដើម្បីបញ្ជាក់ថាខ្លួនពិតជាត្រូវបានឃាត់ខ្លួនដោយអនុវត្តស្របទៅតាមវិធាននៃការឃាត់ខ្លួន។

### ៤.២.ការឃាត់ខ្លួនក្នុងបទល្មើសមិនជាក់ស្តែង

ជាទូទៅការឃាត់ខ្លួននៅក្នុងបទល្មើសមិនជាក់ស្តែង គឺមានសកម្មភាពប្រហាក់ប្រហែលទៅនឹងការឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែងដែរ ដោយយោងទៅតាមមាត្រា១១៦ (ការឃាត់ខ្លួនជនជាប់សង្ស័យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅពេលមន្ត្រីនគរបាលយុត្តិធម៌ចុះបំពេញបេសកម្មរបស់ខ្លួនក្នុងការបើកការឆែកឆេរទីកន្លែងណាមួយមន្ត្រីនគរបាលយុត្តិធម៌គឺមានសិទ្ធិអំណាចពេញលេញក្នុងការឃាត់ខ្លួនជនណាមួយដែលនៅក្នុងទីកន្លែងឆែកឆេរនោះ ឬអ្នកដែលនៅក្បែរៗនោះ ដោយសង្ស័យថាអាចផ្តល់នូវចម្លើយ ឬព័ត៌មានណាមួយដែលអាចជាតម្រុយក្នុងការស៊ើបអង្កេតបន្ត ហើយនៅតែបដិសេធមិនព្រមផ្តល់ចម្លើយ។ សូមបញ្ជាក់ថារាល់ការឃាត់ខ្លួនទៅលើរូបវន្តបុគ្គលណាមួយត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ដើម្បីជៀសវាងនូវការប្តឹងមោឃៈភាពពីភាគីណាមួយក្នុងសំណុំរឿង។ ចំពោះលក្ខខណ្ឌពេលវេលាវិញក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់រួចជាស្រេចហើយដែរ គឺដូចគ្នាទៅនឹងបទល្មើសជាក់ស្តែងដែរពោលគឺអនីតិជនដែលមានអាយុ

ក្រោម១៨ឆ្នាំមិនត្រូវបានធ្វើការឃាត់ខ្លួនឡើយ។

ជាធម្មតានៅក្នុងករណីស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌តែងតែត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាភ្ជាប់នៅជាមួយដីការបស់ប្រធានសាលាដំបូងក្នុងការចុះបំពេញបេសកម្មរបស់ខ្លួនក្នុងការចាប់យកវត្ថុតាង ឬឃាត់ខ្លួនជនណាម្នាក់ដែលស្ថិតនៅក្នុងបរិវេនទីកន្លែងដែលជាកម្មវត្ថុនៃការឆែកឆេរនោះ។ នៅក្នុងករណីបទល្មើសមិនជាក់ស្តែងហើយមន្ត្រីនគរបាលយុត្តិធម៌ពុំបានស្គាល់សាវតាជនល្មើស ពេលនោះហើយដែលសាក្សី និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះគឺពិតជាសំខាន់ណាស់ក្នុងការរែកមុខស្វែករកជននោះមកផ្តន្ទាទោសតាមច្បាប់។ ជាក់ស្តែងបច្ចុប្បន្ននេះ យើងឃើញថាប្រជាពលរដ្ឋមានការយល់ដឹងបានច្រើនអំពីវិធានការក្នុងការការពារទ្រព្យសម្បត្តិ ឬវត្ថុរបស់ខ្លួនដោយដាក់ជាកាម៉ារ៉ាសុវត្ថិភាព ដែលវាក៏ជួយដល់កិច្ចនីតិវិធីនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាផងដែរក្នុងការរែកមុខជនល្មើសតាមរយះមធ្យោបាយណាមួយ។

## ផ្នែកទី២៖កំណត់ហេតុក្នុងពេលឃាត់ខ្លួន

## កថាខណ្ឌ១-កំណត់ហេតុស្តីពីការឃាត់ខ្លួន

នៅក្នុងដំណាក់កាលនៃការឃាត់ខ្លួនជនណាម្នាក់ កំណត់ហេតុគឺមានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់ថាជននោះគឺពិតជាត្រូវបានឃាត់ដោយគោរពវិធាននៃការឃាត់ខ្លួនពិតប្រាកដមែន ពីព្រោះសព្វថ្ងៃនេះមានប្រជាពលរដ្ឋជាច្រើន មានការព្រួយបារម្ភថាខ្លាចមន្ត្រីនគរបាលយុត្តិធម៌រំលោភលើសិទ្ធិរបស់ខ្លួនតាមរយៈការឃាត់ខ្លួននេះ។ ជាក់ស្តែងនៅក្នុងក្រមព្រហ្មទណ្ឌមានស្មារតីថាការឃាត់ខ្លួនមិនត្រូវបង្កអំពើហឹង្សាណាមួយដូចជាការវាយដំ ទាត់ធាកជាដើមក្នុងការធ្វើកំណត់ហេតុ ឬប្រមូលយកចម្លើយណាមួយពីជនដែលត្រូវបានឃាត់នោះ កំណត់ហេតុនោះនឹងមិនមានសុពលភាពនោះទេព្រោះជនដែលត្រូវបានឃាត់នោះអាចនឹងផ្តល់នូវចម្លើយមិនពិតដូចជាបង្ខំចិត្តសារភាពជាដើម ព្រោះចម្លើយនោះបានមកពីការប្រើអំពើហឹង្សា នោះកំណត់ហេតុនឹងរងនៅការប្តឹងមោឃៈភាព ហើយមន្ត្រីនគរបាលយុត្តិធម៌នោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យផងដែរតាមមាត្រា ៦៤, មាត្រា ៦៥ និងមាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

### ១.១.មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីមូលហេតុនៃការឃាត់ខ្លួន

ដូចដែលបានបញ្ជាក់ខាងដើមរួចមកហើយថា កិច្ចដំបូងដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ មុននឹងធ្វើការឃាត់ខ្លួនលើបុគ្គលណាមួយ គឺត្រូវប្រាប់ជននោះអំពីហេតុផលដែលនាំឲ្យឈានទៅដល់ការអនុវត្តការឃាត់ខ្លួននេះឡើង។ ត្រង់ចំណុចនេះ គឺវាមានភាពទាក់ទងគ្នាជាមួយនឹងសិទ្ធិមនុស្សជាខ្លាំងដែលមនុស្សម្នាក់ៗ តែងចង់បានហើយទទួលបាននូវសិទ្ធិស្មើរៗគ្នាលើគ្រប់ទិដ្ឋភាព មិនថាទិដ្ឋភាពសង្គម សេដ្ឋកិច្ច នយោបាយ ឬប្រព័ន្ធយុត្តាធិការទេនោះទេ។ បើយោងទៅតាមមូលដ្ឋានគ្រឹះនៃសិទ្ធិយើងឃើញថា ក្នុងចំណោមសិទ្ធិធំៗ

ទាំង ៣០ ក្នុងនោះក៏មានសិទ្ធិផ្លូវច្បាប់ផងមានន័យថាមនុស្សម្នាក់ៗមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់នេះបើយោងតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សផ្សព្វផ្សាយដោយអង្គការសហប្រជាជាតិ។ សិទ្ធិផ្លូវច្បាប់នេះមានគោលបំណងធំមួយក្នុងការបញ្ជាក់ថារាល់បុគ្គលទាំងអស់ដោយមិនគិតពីអាយុ ពណ៌ សម្បុរ សាសនា ឬភេទនោះទេ គឺត្រូវជានាថាមានសិទ្ធិស្មើរៗគ្នាចំពោះមុខច្បាប់។ ជារួមរាល់បុគ្គលទាំងអស់មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលទេ ត្រូវទទួលបាននូវសិទ្ធិស្មើរៗគ្នាចំពោះមុខច្បាប់ ដូចនេះក្នុងអំឡុងពេលនៃការឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ដាច់ខាតត្រូវផ្តល់នូវគោលបំណង និងមូលហេតុសមស្របណាមួយនៃការឃាត់ខ្លួននោះ។

**១.២.មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អំពីសិទ្ធិដែលជននោះមានក្នុងពេលឃាត់ខ្លួន**

យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ថាជនសង្ស័យ ឬជនល្មើសឬ រូបវន្តបុគ្គលណាផ្សេងទៀតក៏ដោយគឺមិនត្រូវកំណត់ថាមានទោសទេ កាលបើមិនទាន់ទទួលបានសាលក្រម ឬសាលដីកាជាស្ថាពរពីតុលាការ។ ដូច្នេះហើយទើបជនល្មើស ឬជនសង្ស័យនូវតែមានសិទ្ធិមួយចំនួនហើយអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ក្នុងអំឡុងពេលនៃការឃាត់ខ្លួននោះផងដែរ។ កត្តានេះហើយទើបមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានកើននូវកាតព្វកិច្ចមួយទៀតគឺត្រូវប្រាប់សិទ្ធិដែលជននោះមានក្នុងអំឡុងពេលនៃការឃាត់ខ្លួននោះ។ ជនល្មើស ឬជនសង្ស័យមានសិទ្ធិក្នុងការមានមេធាវី (បើមាន) បន្ទាប់ពីត្រូវបានឃាត់ខ្លួនបាន ២៤ ម៉ោងរាប់គិតពីជននោះទៅដល់អង្គភាពនគរបាល ឬការិយាល័យរដ្ឋបាលប៉ុស្តិ៍ណាមួយ។ ប្រសិនបើជននោះមិនមានមេធាវីប្រចាំខ្លួននោះទេ គាត់អាចស្នើរសុំជួបអ្នកចំនួនទៀតដូចជា ឪពុកម្តាយ អាណាព្យាល បងប្អូន ឬមិត្តភ័ក្តជិតស្និតណាមួយ ប៉ុន្តែជនទាំងឡាយនោះត្រូវកំណត់ឲ្យច្បាស់ថាមិនមានពាក់ព័ន្ធទៅនឹងបទល្មើសនោះទេ។ ចំពោះករណីដែលជននោះក្រីក្រវិញ អង្គការអំណាចទាំងបីរួមមាននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ជាអ្នកទទួលបន្ទុកក្នុងការស្វែងរកមេធាវីសម្រាប់ការពារជននោះ ឬជាតួនាទីរបស់នាយកដ្ឋានការពារក្តីជូនជនក្រីក្របើសិនជាចូលទៅក្នុងលក្ខខណ្ឌណាមួយ។

ក្រោយពីបានពិភាក្សាជាមួយអ្នកតំណាងដោយច្បាប់បានកំណត់ ឬមេធាវីការពារក្តីរបស់ខ្លួនរួចជនដែលត្រូវបានឃាត់នោះ ក៏អាចមានសិទ្ធិក្នុងការជួបគ្រូពេទ្យបានដែរប្រសិនបើស្ថិតក្នុងករណីចាំបាច់ណាមួយ។ ក្នុងករណីចាំបាច់ណាមួយក្រុមគ្រូពេទ្យអាចស្នើរឲ្យនាំខ្លួនជននោះទៅបន្តពិនិត្យសុខភាពនៅមន្ទីរពេទ្យបាន ដោយគ្រាន់តែចេញនូវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពដែលត្រូវភ្ជាប់ជាមួយនឹងសំណុំរឿងគឺរួចជាស្រេច។ ម្យ៉ាងវិញទៀតនៅពេលកសាងសំណុំរឿង កាលបើជនដែលត្រូវឃាត់ខ្លួននោះមានសញ្ជាតិខុសពីខ្មែរហើយមិនអាចធ្វើការប្រាស្រ័យទាក់ទងគ្នាបាន នោះមន្ត្រីនគរបាលយុត្តិធម៌អាចស្នើឲ្យជនដែលត្រូវបានឃាត់នោះរកអ្នក

បកប្រែម្នាក់ ឬបើជននោះមិនអាចរកបាន មន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់នោះត្រូវស្វែងរកអ្នកបកប្រែសម្រាប់ជននោះ។

**១.៣.ចំណុចត្រូវសរសេរក្នុងកំណត់ហេតុស្តីពីការឃាត់ខ្លួន**

នៅក្នុងកិច្ចនីតិវិធីនៃការឃាត់ខ្លួនជនណាម្នាក់ យើងតែងឃើញមានមន្ត្រីនគរបាលយុត្តិធម៌ដែលជាតួអង្គសំខាន់នៅក្នុងទីកន្លែងកើតហេតុនោះ។ ជារឿយៗបន្ទាប់ពីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនជនដែលបានសង្ស័យថាប្រព្រឹត្តបទល្មើស ឬជនដែលអាចផ្តល់ពត៌មានណាមួយ នគរបាលយុត្តិធម៌តែងកសាងនូវកំណត់ហេតុភ្លាម ដើម្បីជាការកំណត់សម្គាល់អ្វីៗដែលទាក់ទងទៅនឹងបទល្មើស។ នៅក្នុងតំណាក់កាលនគរបាលយុត្តិធម៌យើងឃើញមានកំណត់ហេតុពីរដែលមានសារៈសំខាន់ណាស់ក្នុងការជំរុញឲ្យមានការប្រព្រឹត្តទៅដោយរលូននៃកិច្ចស៊ើបអង្កេត ហើយកំណត់ហេតុទាំងពីរនោះរួមមាន កំណត់ហេតុស្តីពីការឃាត់ខ្លួន(មាត្រា៩៧) និងកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួន(មាត្រា១០២)។

កំណត់ហេតុស្តីពីការឃាត់ខ្លួននេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះសេចក្តីដូចខាងក្រោម៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវបានឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ
- ជាយថាហេតុឈ្មោះរបស់អ្នកបកប្រែ។

បន្ទាប់ពីកសាងកំណត់ហេតុរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុនោះឲ្យជនដែលត្រូវបានឃាត់ខ្លួនបានស្តាប់ តែបើក្នុងករណីដែលជននោះចេះអក្សរ ឬអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យជននោះអានដោយខ្លួនឯង។ ម្យ៉ាងវិញទៀតបន្ទាប់ពីអានរួចជនដែលត្រូវឃាត់ខ្លួនត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃទៅលើកំណតហេតុនោះ ប៉ុន្តែក្នុងករណីដែលជននោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃ មន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែចុះនូវនិទ្ទេសអំពីមូលហេតុដែលនាំឲ្យជននោះមិនព្រមផ្តិតមេដៃរួចជាស្រេច។

## កថាខណ្ឌ២-បញ្ជីនៃការឃាត់ខ្លួន

**២.១.ជនដែលត្រូវឃាត់ត្រូវមានក្នុងបញ្ជីនៃការឃាត់ខ្លួន**

ជារឿយៗមានបងប្អូនប្រជាពលរដ្ឋមួយចំនួនធំដែលមិនសូវបានចាប់អារម្មណ៍ទៅនឹងបញ្ជីនៃការឃាត់ខ្លួន។ បញ្ជីនៃការឃាត់ខ្លួននេះក៏ជាកត្តាដែលជំរុញទៅរកភាពយុត្តិធម៌ផងដែរតាមរយៈកត់ត្រាកំណត់ហេតុស្តី

ពីការឃាត់ខ្លួនក្នុងការបញ្ជាក់ថា ជាក់ស្តែងនៅក្នុងហេតុការណ៍មួយចំនួនដែលតែងតែកើតមានឡើងនៅក្នុងសង្គមបច្ចុប្បន្ន គឺសកម្មភាពជនទុច្ចរិតដែលបន្លំខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តអំពើផ្សេងៗ ដែលមិនគប្បីក្នុងគោលបំណងគេងយកផលប្រយោជន៍ណាមួយ ហើយវាក៏បានធ្វើឲ្យបណ្តាមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់បាត់បង់នូវកត្តិយសឬ មុខមាត់ជាដើម។ ជារួមជនដែលត្រូវបានឃាត់ខ្លួនត្រូវបញ្ជាក់ថាគាត់ត្រូវបានកត់ចូលទៅក្នុងបញ្ជីនៃការឃាត់ខ្លួន បើមិនដូចនេះទេកិច្ចនីតិវិធីនោះអាចនឹងផ្ទុយទៅនឹងវិធានដែលបានចែងហើយអាចនឹងរងនូវការប្តឹងមោឃៈភាពថែមទៀតផង។ ដូចនេះយើងទាំងអស់គ្នាគប្បីតាមដាននូវសកម្មភាពទាំងអស់របស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងគោលបំណងស្វែងរកយុត្តិធម៌ពិតប្រាកដ និងជាក់លាក់មួយ។

### ២.២.ចំណុចដែលត្រូវសរសេរនៅពេលចុះក្នុងបញ្ជី

គ្រប់ការឃាត់ខ្លួនទាំងអស់ត្រូវមានចុះក្នុងបញ្ជីនៃការឃាត់ខ្លួនក្នុងទទួលជននោះ ហើយនៅក្នុងបញ្ជីនៃការឃាត់ខ្លួននេះត្រូវមានចុះដូចខាងក្រោមៈ

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលត្រូវបានឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួននិងបញ្ចប់ការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួនជាយថាហេតុ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់នៃការឃាត់ខ្លួន។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំ ឬរក្សាទុកឲ្យបានត្រឹមត្រូវជៀសវាងមានហេតុការណ៍ណាមួយជាយថាហេតុដែលបណ្តាលឲ្យបាត់បង់ ឬខូចសណ្ឋានជាដើម ដែលវាបង្កនូវភាពជម្រងជម្រាស់គ្នាដល់ស្ថាប័នតុលាការក្នុងការតាមដានរឿងក្តីណាមួយ។ បញ្ជីនៃការឃាត់ខ្លួននេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវដាក់ជូនស្ថាប័នតុលាការទៅតាមតម្រូវការរបស់តុលាការក្នុងការស្វែករកយុត្តិធម៌ពិតប្រាកដមួយ។

## កថាខណ្ឌ៣-កំណត់ហេតុសរុបនៃការឃាត់ខ្លួន

### ៣.១.គ្រប់ការឃាត់ខ្លួនត្រូវមានកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួន

កំណត់ហេតុសរុបនេះ គឺជាការស្រង់ឡើងវិញចាប់តាំងនីតិវិធីដំបូងនៃការឃាត់ខ្លួនរហូតដល់ដំណាក់កាលចុងក្រោយនៃការឃាត់ខ្លួនពោលគឺត្រូវដកស្រង់រាល់សកម្មភាព ឬបទបញ្ញត្តិនានាដែលកើតមានក្នុងអំឡុងពេលនោះដូចជាសកម្មភាពជជែកជាមួយមេធាវី គ្រូពេទ្យ ឬការសុំពន្យាពេលនៃការឃាត់ខ្លួនជាដើម។ ម្យ៉ាងវិញទៀតកំណត់ហេតុសរុបនៃការឃាត់ខ្លួន គឺមានអត្ថប្រយោជន៍ណាស់ដល់គូភាគីទាំងសងខាងក្នុងការ

ស្វែងរកនូវយុត្តិធម៌មួយដ៏ត្រឹមត្រូវ។ ដូចនេះគ្រប់ការឃាត់ខ្លួនទាំងអស់ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយនៃការឃាត់ខ្លួនហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវយកមកចុះក្នុងកំណត់ហេតុសរុបនៃការឃាត់ខ្លួននេះ។

**៣.២.ចំណុចដែលត្រូវសរសេរក្នុងកំណត់ហេតុសរុបនៃការឃាត់ខ្លួន**

កំណត់ហេតុសរុបនៃការឃាត់ខ្លួននេះត្រូវមានចុះនិទ្ទេសដូចតទៅៈ

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន
- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ
- ឈ្មោះគ្រូពេទ្យដែលត្រូវបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួននោះ)នៃក្រមនេះ។
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន
- ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅក្នុងចន្លោះការស្តាប់ចម្លើយនីមួយៗ
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅតុលាការនៅពេលបញ្ចប់នៃការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។ កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយនឹងសំណុំរឿង។

# ជំពូកទី២

# ការចោទប្រកាន់និងការឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖នីតិវិធីនៃការចោទប្រកាន់

នីតិវិធីនៃការចោទប្រកាន់ គឺជារបៀបរបប ឬ មធ្យោបាយមួយក្នុងចំណោមនីតិវិធីមួយចំនួនទៀតក្នុងរឿងក្ដីព្រហ្មទណ្ឌ។ បន្ទាប់ពីជនល្មើស ឬជនសង្ស័យត្រូវបានបញ្ជូនខ្លួន រួមទាំងភស្តុតាងនានាមកដល់តុលាការ ឬមកដល់ការិល័យរបស់ព្រះរាជអាជ្ញា នៅពេលនោះព្រះរាជអាជ្ញានឹងធ្វើការពិនិត្យមើលទៅមើលកំណត់ហេតុទាំងអស់ រួចសន្មត់ថាចោទប្រកាន់ ឬមិនចោទប្រកាន់ ដោយយោងទៅតាមករណីជាក់ស្ដែង បើជននោះមាន ឬគ្មានតម្រុយជាដើម។

### កថាខណ្ឌ១-សញ្ញាណទូទៅនៃការចោទប្រកាន់

#### ១.១.និយមន័យនៃការចោទប្រកាន់

ការចោទប្រកាន់ គឺសំដៅដល់ការចង្អុលបង្ហាញរកមុខជនល្មើសដែលពាក់ព័ន្ធឬត្រូវបានសង្ស័យទៅនឹងបទល្មើសព្រហ្មទណ្ឌ ដើម្បីបង្ហាញឲ្យឃើញពិរុទ្ធភាព នឹងបញ្ជូនខ្លួនជននោះមកអនុវត្តនីតិវិធីតាមផ្លូវច្បាប់។ ការចោទប្រកាន់នៅក្នុងរឿងព្រហ្មទណ្ឌ យើងអាចហៅម៉្យាងទៀតបានគឺបណ្ដឹងអាជ្ញាដែលបណ្ដឹងនេះមានគោលបំណងក្នុងការចោទប្រកាន់រាល់ជនល្មើសដែលល្មើសនឹងច្បាប់។ បណ្ដឹងអាជ្ញា គឺជាបណ្ដឹងមួយប្រភេទដែលស្វែករកសុខសន្តិភាព ភាពត្រឹមត្រូវ ភាពយុត្តិធម៌ជូនសណ្ដាប់ធ្នាប់សាធារណៈដែលជាប្រយោជន៍សង្គមជាតិទាំងមូល។

#### ១.២.អាជ្ញាធរដែលទទួលបន្ទុកក្នុងការចោទប្រកាន់

ការចោទប្រកាន់ជារឿងៗយើងឃើញថាមានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដែលសកម្មក្នុងការចោទប្រកាន់ទៅលើគ្រប់បទល្មើស។ បើយោងតាមមាត្រា១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា" និងបើយោងតាមមាត្រា៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ" សរុបមកយើងអាចសនិដ្ឋានបានថាមានតែអង្គការអយ្យការតែប៉ុណ្ណោះដែលមានសិទ្ធិអំណាចក្នុងការបើកការចោទប្រកាន់លើបុគ្គលណាមួយ។

#### ១.៣.ប្រភេទនៃការចោទប្រកាន់

ប្រភេទនៃការចោទប្រកាន់ គឺមានច្រើនរបៀបរបបទៅតាមស្ថានភាពជាក់ស្ដែងឬហេតុការដែលកើតឡើងភ្លាមៗនោះ។ បណ្ដឹងអាជ្ញាអាចដំណើរការដោយព្រះរាជអាជ្ញាផ្ទាល់បានកាលបើព្រះរាជអាជ្ញាបានដឹងច្បាស់អំពីហេតុការដែលបានកើតឡើងនោះ ដូចជាបានដឹងតាមរយៈព័ត៌មាន កាសែត ទូរទស្សន៍ ឬតាម

បណ្ដាញសង្គមផ្សេងៗទៀត។ ប៉ុន្តែជាធម្មតានៅក្នុងសង្គមយើងបច្ចុប្បន្នឃើញថាបណ្ដឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនាដោយជនរងគ្រោះ ព្រោះជនរងគ្រោះគឺជាបុគ្គលដែលស្ថិតក្នុងហេតុការណ៍ផ្ទាល់ ឬបានទទួលរងនូវការខូចខាត់ជាសម្ភារៈឬផ្លូវចិត្តជាដើម។ ដូចជាលោក ក បានធ្វើការវាយដំទៅលើលោក ខ ដោយប្រើដុំថ្មបន្ទាប់មកគេរកឃើញថាលោក ខ បានបែកក្បាលយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះសាច់ញាតិរបស់លោក ខ បានដាក់ពាក្យបណ្ដឹងទៅព្រះរាជអាជ្ញាពីបទ "ហឹង្សាដោយចេតនាដោយស្ថានទំងន់ទោស" ក្នុងករណីនេះបណ្ដឹងអាជ្ញានឹងមានចលនាតាមរយៈពាក្យបណ្ដឹងរបស់សាច់ញាតិនៃជនរងគ្រោះដែលបានដាក់មកអង្គការអយ្យការ។ ច្រើនជាងនេះទៅទៀត យោងទៅតាមមាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ទៅតុលាការដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កាលបើក្នុងសំណុំរឿងនោះមានពាក់ព័ន្ធទៅនឹងបទល្មើសព្រហ្មទណ្ឌ ជាទូទៅចៅក្រមស៊ើបសួរនឹងបញ្ជូនពាក្យបណ្ដឹងនោះទៅព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីឲ្យព្រះរាជ្ញាចាត់ការតាមនីតិវិធីផ្លូវច្បាប់។ ម្យ៉ាងវិញទៀតបើយោងតាមមាត្រា១១ បណ្ដឹងអាជ្ញាអាចនឹងមានចលនាបានដោយសារកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រោះច្បាប់បានផ្ដល់សិទ្ធិមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីដែលពួកគាត់បានដឹងអំពីបទល្មើសនោះដោយឯកឯង ឬតាមរយៈពាក្យបណ្ដឹងរបស់ជនរងគ្រោះដែលបានដាក់មកមន្ត្រីនគរបាលយុត្តិធម៌។

## កថាខណ្ឌ២-ការបើកការស៊ើបសួរ

### ២.១.គោលបំណងនៃការស៊ើបសួរ

ការស៊ើបសួរមានគោលបំណងក្នុងការស្វែងរកនូវធាតុចាំបាច់សំរាប់ធានាដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រោះថាព្រះរាជអាជ្ញាមិនអាចចេះតែចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាស់លាស់នោះទេដែលវាអាចធ្វើឲ្យប្រព័ន្ធយុត្តិធម៌មានការធ្លាក់ចុះ និងបាត់បង់ជំនឿទុកចិត្តពីប្រជាពលរដ្ឋផងដែរ។ ច្រើនជាងនេះទៅទៀតចៅក្រមស៊ើបសួរស្វែងរកភស្តុតាង និងពិរុទ្ធភាពសំរាប់អង្គហេតុចោទប្រកាន់ និងធានាសំរាប់ដំណើរការកាត់សេចក្ដី (នីរន្តរភាពនីតិវិធីព្រហ្មទណ្ឌ)។ មានន័យថាចៅក្រមស៊ើបសួរមិនមែនស្វែងរកតែភស្តុតាងដាក់បន្ទុកនោះទេ តែក៏ស្វែងរកនូវព័ត៌មានផ្សេងៗទៀតដែលជួយដល់ភាគីម្ខាងទៀតផងដែរ ទើបពេលសម្រេចសេចក្ដីពុំមានភាគីណាមួយមិនសុខចិត្តនេះបើយោងតាមមាត្រា១២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.២.យុត្តាធិការនៃការស៊ើបសួរ

នៅក្នុងដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌយុត្តាធិការនៃការស៊ើបសួរគឺមាន២ដូចជា៖

ក.ចៅក្រមស៊ើបសួរ:ជាអ្នកដើរតួនាទីបំពេញកិច្ចស៊ើបសួរនៅតុលាការថ្នាក់ទាប

ខ.សភាស៊ើបសួរ : ជាអ្នកដើរតួនាទីបំពេញកិច្ចស៊ើបសួរបន្តពីចៅក្រមស៊ើបសួរ និងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើរាល់កិច្ចការរបស់ចៅក្រមស៊ើបសួរ។

មាត្រា ១២១ នៃក្រមនេះបានចែងថា ការស៊ើបសួរត្រូវធ្វើជាសម្ងាត់។ មានតែព្រះរាជអាជ្ញាទេ ដែលអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដើម្បីកែតម្រូវព័ត៌មានមិនពិត។ចំណែកចៅក្រមស៊ើបសួរព្រះរាជអាជ្ញារងមិនអាចធ្វើបានទេ។

**២.៣.លក្ខខណ្ឌនៃការបើកការស៊ើបសួរ**

យោងមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានកំណត់យ៉ាងច្បាស់ថារាល់បទល្មើសឧក្រិដ្ឋទាំងអស់គឺត្រូវតែឆ្លងកាត់នូវការស៊ើបសួររបស់ចៅក្រមស៊ើបសួរដើម្បីស្វែងរកនូវយុត្តិធម៌ពិតប្រាកដមួយដោយជឿជាក់បានពីប្រជាពលរដ្ឋ និងអនុវត្តឲ្យបានឆាប់រហ័សបំផុតព្រោះបទល្មើសឧក្រិដ្ឋងាយបង្កឲ្យមានស្ថានភាពអាណាធិបតេយ្យ និងអសន្តិសុខហើយពាក់ព័ន្ធទៅនឹងអាយុជីវិតមនុស្សថែមទៀតផង។ ឧទាហរណ៍បទល្មើសមួយចំនួនដូចជា បទល្មើសរំលោភសេពសន្ថវៈ បទល្មើសមនុស្សឃាតជាដើមដែលជាប្រភេទនៃបទល្មើសឧក្រិដ្ឋ ដូចនេះគឺត្រូវឆ្លងកាត់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរដើម្បីរកយុត្តិធម៌មួយដ៏ពិតប្រាកដសម្រាប់គូភាគីមិនថាភាគីជនរងគ្រោះ ឬភាគីជនល្មើសទេគឺត្រូវច្បាស់ថាភាគីអាចទទួលយកនូវលទ្ធផលមួយដែលពិតប្រាកដ។ ប៉ុន្តែក្រមនេះក៏បានបញ្ជាក់ផងដែរថាចំពោះបទល្មើសកម្រិតមធ្យមចៅក្រមស៊ើបសួរអាចធ្វើ ឬ មិនធ្វើការស៊ើបសួរបាន ដោយយោងទៅតាមការសម្រេចពីព្រះរាជអាជ្ញាក្នុងករណីដែលព្រះរាជអាជ្ញាគិតថាមានភស្តុតាង និងសាក្សីគ្រប់គ្រាន់ក្នុងការចោទនរណាម្នាក់។ ម្យ៉ាងវិញទៀតបើយោងតាមមាត្រា៤៤ និងមាត្រា១២៤ នៃក្រមនេះក៏បានកំណត់ផងដែរថាចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរបានលុះត្រាតែទទួលបាននូវដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ទើបអាចដំណើរការសកម្មភាពស៊ើបសួររបស់ខ្លួនបាន លើកលែងតែក្នុងករណីពិសេសដែលក្រមនេះបានចែង។ សូមបញ្ជាក់ផងដែរថាចៅក្រមស៊ើបសួរមិនអាចធ្វើការដាក់បុគ្គលណាមួយ ឬអង្គហេតុណាមួយឲ្យស្ថិតក្នុងការត្រួតពិនិត្យ ហើយស៊ើបសួរបានទេប្រសិនបើបុគ្គល ឬអង្គហេតុនោះមិនត្រូវបានរៀបរាប់ពីព្រះរាជអាជ្ញាដែលមានបញ្ជាក់នៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ច្រើនជាងនេះទៅទៀតក្នុងករណីដែលចៅក្រមស៊ើបសួរបានរកឃើញនូវបទល្មើសថ្មីផ្សេងពីបទល្មើសដែលព្រះរាជអាជ្ញាដាក់មកក្នុងពេលនៃការស៊ើបសួររបស់ខ្លួន ចៅក្រមត្រូវផ្តល់ដំណឹងអំពីបទល្មើសថ្មីនោះទៅព្រះរាជអាជ្ញាដែលអ្នកសម្រេចថាចោទចំពោះបទល្មើសថ្មី ឬបន្តការស៊ើបសួរដើម្បីស្វែងរកបទល្មើសមួយដែលពិតប្រាកដ។ នៅក្នុងករណីខាងលើ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានផ្តល់នូវសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចថាតើគួរ ឬមិនគួរជុំវិញទៅនឹងអង្គហេតុថ្មីនោះ ហើយព្រះរាជអាជ្ញាអាចធ្វើការបង្គាប់ឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរអំពីបទល្មើសថ្មីដែលលេចចេញមកនោះបានតាមរយៈដីការសន្និដ្ឋានបញ្ជូន

រឿងឲ្យស៊ើបសួរបន្ថែម។

**២.៤.នីតិវិធីនៃការបើកការស៊ើបសួរ**

ជាកិច្ចចាប់ផ្ដើមនៃការបើកការស៊ើបសួរ យើងតែងឃើញចៅក្រមស៊ើបសួរដែលបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ តែងដឹកនាំបន្តនូវកិច្ចនីតិវិធីព្រហ្មទណ្ឌដើម្បីឆ្ពោះទៅរកយុត្តិធម៌មួយដ៏ពិតប្រាកដសម្រាប់គូភាគី។ បន្ទាប់ពីព្រះរាជអាជ្ញាបានប្រាប់ និងបញ្ជូននូវព័ត៌មានមួយចំនួនអំពីជនជាប់ចោទទៅដល់ដៃចៅក្រមស៊ើបសួរ ចៅក្រមរូបនោះនឹងដាក់ជននោះឲ្យស្ថិតនូវក្រោមការត្រួតពិនិត្យ (មាត្រា១២៦ នៃក្រមនេះ) មានន័យថាជននោះស្ថិតក្រោមការស្វែងរកពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចចុះទៅដល់ទីកន្លែងកើតហេតុ ពិនិត្យ និងឆែកឆេរទៅលើវត្ថុតាង ឃាត់ខ្លួនជនណាមួយដែលសង្ស័យពាក់ព័ន្ធទៅនឹងបទល្មើសបាន (មាត្រា ១៣០ នៃក្រមនេះ) ។ គេតែងប្រទះឃើញចៅក្រមស៊ើបសួរតែងអមដោយក្រឡាបញ្ជីមួយរូប ឬពីរនូវពេលចុះទៅដល់កន្លែងកើតហេតុ ព្រោះក្រឡាបញ្ជីគឺជាជំនួយការពិសេសរបស់ចៅក្រមស៊ើបសួរក្នុងពេលបំពេញបេសកម្មរបស់ខ្លួន (មាត្រា ១២៩ នៃក្រមនេះ)។ មុនរាល់ការបើកការស៊ើបសួរនីមួយៗចៅក្រមត្រូវផ្ដល់ដំណឹងទៅដល់ព្រះរាជអាជ្ញា បើទោះបីជាមានដីកាសន្និដ្ឋានបញ្ជូនរឿងហើយក៏ដោយ ហើយក្នុងករណីចាំបាច់ណាផ្សេងៗទៀតព្រះរាជអាជ្ញាក៏អាចនឹងត្រូវមានវត្តមាននៅក្នុងកិច្ចនីតិវិធីស៊ើបសួរផងដែរ ប្រសិនបើព្រះរាជអាជ្ញាគិតថាវាមានប្រយោជន៍សម្រាប់សណ្ដាប់ធ្នាប់សាធារណៈដូចជាចុះទៅដល់ទីកន្លែងកើតហេតុជាមួយចៅក្រមស៊ើបសួរជាដើម។ ក្នុងករណីដែលចៅក្រមស៊ើបសួររូបនោះមានភារៈ ឬមិនអាចបំពេញកិច្ចការរបស់ខ្លួន ចៅក្រមស៊ើបសួរអាចមានសិទ្ធិក្នុងការសុំឲ្យចៅក្រមផ្សេងៗ ឬមន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ឲ្យបំពេញកិច្ចមួយចំនួនដូចដែលបានកំណត់នៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស (មាត្រា១៣១ នៃក្រមនេះ)។ ចំពោះកិច្ចឲ្យស៊ើបសួរជំនួសនោះត្រូវអនុវត្តដោយគោរពលក្ខខណ្ឌដែលមានចែងនៅមាត្រា១៧៣ (ដីកាចាត់ឲ្យស៊ើបសួរជំនួស) ដល់មាត្រា១៨៥ (កំណត់ហេតុសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ។ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរមិនមែនសុទ្ធតែអនុវត្តតាមទាំងស្រុងទៅតាមដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ប៉ុន្តែយោងតាមមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) មាត្រា១៣៣ (ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ) និង មាត្រា១៣៤ (ការស្នើសុំឲ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី) ក៏អាចស្នើសុំឲ្យចៅក្រមងាកមកពិនិត្យមើលលើបញ្ហាដែលបានដាក់មកនោះ ដែលវាអាចថាជាប្រភពវិវាទ ឬជាផ្នែកណាមួយនៃវិវាទ ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចមានសិទ្ធិក្នុងការជំនួសផងដែរទៅលើការស្នើសុំរបស់ព្រះរាជអាជ្ញា ឬ ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី

ហើយការជំនួសនោះត្រូវមានហេតុផលច្បាស់លាស់ និងសំអាងហេតុ ។ កាលបើលើសថេរវេលាហើយចៅក្រមស៊ើបសួរនូវតែមិនមានការឆ្លើយតប នោះព្រះរាជអាជ្ញា ឬជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចទៅប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលជាអ្នកសម្រេចជំនួសចៅក្រមស៊ើបសួរ។ យ៉ាងណាមិញនៅគ្រប់នីតិវិធីនៃកិច្ចស៊ើបសួរ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវសិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការពិនិត្យមើលទៅលើសំណុំរឿងបានគ្រប់ពេលវេលា ប៉ុន្តែព្រះរាជអាជ្ញាក៏ត្រូវប្រគល់សំណុំរឿងនោះវិលត្រលប់ទៅដល់ចៅក្រមស៊ើបសួរវិញផងដែរក្នុងរយះពេល ២៤ ម៉ោង ដែរជាថេរវេដែលច្បាប់បានកំណត់ (មាត្រា ១៣៥ នៃក្រមនេះ)។ មិនត្រឹមតែប៉ុណ្ណោះ ព្រះរាជអាជ្ញាក៏អាចចូលរួមក្នុងការស្តាប់ ឬសួរសំណួរផ្សេងៗទៅដល់ជនត្រូវចោទផងដែរ។

## កថាខណ្ឌ៣-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

### ៣.១.លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាលិខិត ដែលព្រះរាជអាជ្ញាប្តឹងទៅតុលាការ និងបង្គាប់ឲ្យជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចអនុវត្តចំពោះបទមជ្ឈិមតូចតាច និងចំពោះគ្រប់បទលហុ។ ជាគោលការណ៍ ព្រះរាជអាជ្ញាចាត់ការតាមនីតិវិធីនេះ នៅពេលដែលសំណុំរឿងមូលសព្វគ្រប់ (មានន័យថា ស្ថានភាពនៃរឿងក្តីមិនទាមទារឲ្យមានការស៊ើបសួរ ឬនិយាយម្យ៉ាងទៀតថា រឿងក្តីនោះ មានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះ) ហើយអង្គហេតុនៃរឿងមិនបំពេញលក្ខខណ្ឌនៃការចាត់នីតិវិធីនៃការបង្ហាញខ្លួនភ្លាម។ ជាទូទៅ ទោះបីជា ព្រះរាជអាជ្ញាមិនបើកការស៊ើបសួរក៏ដោយ ក៏ប៉ន្តែព្រះរាជអាជ្ញាអាចធ្វើការស្វែរកព័ត៌មាន និងភស្តុតាងផ្សេងៗ តាមរយះការបើកការស៊ើបអង្កេតបឋម ឬការបង្គាប់ឲ្យស្រាវជ្រាវបន្ថែម (មាត្រា ៤0 និងមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ៖ យោងតាមមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះត្រូវចុះ ៖ (១) អត្តសញ្ញាណជនជាប់ចោទ (២) សេចក្តីសង្ខេបអង្គហេតុ (៣) ឈ្មោះនៃបទល្មើស និង (៤) អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ហើយដីកានេះ ត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវបញ្ជាក់ផងដែរថាជនជាប់ចោទអាចសុំជំនួយពីមេធាវី។ ប្រសិនបើជនជាប់ចោទសុំរយះពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះ ភ្លាមៗបានទេនោះសំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ។

តុលាការអាចបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។ តុលាការចេញដីកាសម្រេចបង្គាប់ឲ្យឃុំខ្លួន។ សាលក្រមលើអង្គសេចក្តី ត្រូវ

តែប្រកាសក្នុងរយៈពេលមិនអាចលើសពី ២សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈ ២សប្តាហ៍។

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម យល់ឃើញថា លក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពសាំញ៉ាំនៃសំណុំរឿង តម្រូវជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវឲ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជានជាប់ចោទ ត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែ ដោះលែងឲ្យមានសេរីភាពឡើងវិញ។

**៣.២.នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ មានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ២៩៥, ៣០២, ៣១០, (ការនាំខ្លួនជនជាប់ចោទ ក្នុងករណីរឿងមជ្ឈិម និងរឿងឧក្រិដ្ឋ) ចាប់ពីមាត្រា ៣១១ ដល់មាត្រា ៣១៥ (ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី) និងចាប់ពីមាត្រា ៤៥៦ ដល់មាត្រា ៤៦៤ (ដីកាកោះហៅទៅជំនុំជម្រះផ្ទាល់)។ ចំពោះថិរវេលានៃការបញ្ជូនដីកាកោះហៅគឺត្រូវកោះហៅមុនកាលបរិច្ឆេទសវនាការ គឺ ១៥ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីសមត្ថកិច្ចរបស់តុលាការ ឬ ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែង ផ្សេងទៀតក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ថិរវេលានេះ ត្រូវបានកំណត់ ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទឹកដីនៃរដ្ឋជិតខាងនៃព្រះរាជាណាចក្រកម្ពុជា និង ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេងពីនេះ (មាត្រា ៤៥៧)។ ថិរវេលានេះ ត្រូវតែគោរព បើពុំនោះទេ នឹងនាំឲ្យមានមោឃៈភាពនៃនីតិវិធី លើកលែងតែជនជាប់ចោទយល់ព្រមចូលខ្លួនមកបង្ហាញដោយស្ម័គ្រចិត្ត។ ថិរវេលាទាំងនេះ ដូចគ្នាទៅនឹងករណីដែលជនជាប់ចោទទទួលបានការកោះហៅ។ ដីកាកោះហៅ អាចត្រូវប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា លិខិតនេះបានប្រគល់ឲ្យជនជាប់ចោទ ឬដល់បុគ្គលដែលមានវត្តមានក្នុងផ្ទះជនជាប់ចោទ។ ជាចុងក្រោយ លិខិតនឹងត្រូវប្រគល់ឲ្យប្រធានឃុំ ឬសង្កាត់ ឬអនុប្រធាន ប្រសិនបើជនជាប់ចោទបដិសេធ មិនទទួលដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬគ្មានបុគ្គលណាម្នាក់ មានវត្តមានក្នុងលំនៅជនជាប់ចោទ ឬប្រសិនបើគ្មានបុគ្គលណាម្នាក់ដែលមានវត្តមានក្នុងលំនៅជនជាប់ចោទ យល់ព្រមទទួលលិខិតនេះទេ (មាត្រា ៤៦២) ។ ប៉ុន្តែលិខិតនេះ ក៏អាចប្រគល់ឲ្យដោយក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬជាចុងក្រោយ តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ (មាត្រា ៤៦៣)។ អត្តសញ្ញាណរបស់បុគ្គលដែលបានប្រគល់លិខិត ព្រមទាំងឋានៈរបស់គាត់ត្រូវមានចុះនិទ្ទេស ។ លិខិត ក៏ត្រូវមានហត្ថលេខារបស់គាត់ផងដែរ។ ដោយឡែក ក្នុងករណីបទល្មើសដែលនឹងត្រូវចោទប្រកាន់ ជាបទលហុ

ព្រះរាជាអាជ្ញាត្រូវសម្រេចអំពី បណ្តឹងអាជ្ញា ដោយចោទប្រកាន់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (មាត្រា ៤៩) តាមនីតិវិធីដែលមានចែងក្នុងមាត្រា ៤៦ មាត្រា ៤៥៦ ដល់មាត្រា ៤៦៤ ។ ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងក្នុងមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ។

## ផ្នែកទី២៖ការឃុំខ្លួនបណ្តោះអាសន្ន

### កថាខណ្ឌ១-មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ជាទូទៅជនដែលជនត្រូវចោទគឺអាច ឬមិនអាចក្នុងការឃុំខ្លួនបណ្តោះអាសន្នព្រោះដើម្បីបន្តកិច្ចនីតិវិធីនៃការស៊ើបសួរចៅក្រមចាំបាច់ណាស់ក្នុងការឃុំខ្លួន ដើម្បីទទួលបានពេលវេលាមួយសមរម្យក្នុងការចាត់ចែងកិច្ចនានា ឬ ចុះទៅទីកន្លែងកើតហេតុជាដើម។

តាមស្ថានភាពជាក់ស្តែងនៃសង្គមបច្ចុប្បន្ននៅពេលកើតមានបទល្មើសណាមួយដែលមានចរិតលក្ខណៈធ្ងន់ធ្ងរ ជនដែលបានប្រព្រឹត្តបទល្មើសអាចនឹងត្រូវបានគេឃាត់ខ្លួនភ្លាមៗ ឬអាចសម្រេចឃុំខ្លួនជាដើម ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ ឬកើតមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងមុនពីអំពើល្មើសនោះ។ ប៉ុន្តែមិនមែនគ្រប់ពេលដែលមានបទល្មើសកើតឡើង ការសម្រេចឃុំត្រូវតែធ្វើឡើងនោះទេ ពោលគេត្រូវសិក្សាទៅលើស្ថានភាពនៃបទល្មើស ក៏ដូចជាស្ថានភាពជនដែលបានប្រព្រឹត្តបទល្មើសជាមុនសិន ដើម្បីជៀសវាងថាការសម្រេចឃុំខ្លួននោះ នឹងអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិនិងសេរីភាពបុគ្គលរបស់គេ។ដូច្នេះតើការឃុំត្រូវធ្វើឡើងបែបណាទើបស្របតាមនីតិវិធីច្បាប់?

ដើម្បីស្វែងយល់ពីនីតិវិធីនេះឲ្យបានច្បាស់ កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ បានលើកយកប្រធានបទមួយស្តីពី ការឃុំខ្លួនបណ្តោះអាសន្ន មកបង្ហាញជូនបងប្អូនប្រជាពលរដ្ឋ សិស្ស និស្សិតដូចខាងក្រោម៖

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី មួយឆ្នាំឡើងទៅ។ យោងតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖

១.ដើម្បីបញ្ចប់បទល្មើស ឬបង្កកុំឲ្យកើតមានឡើងម្តងទៀត

២.ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមាន ការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទនិងអ្នកសមគំនិត

៣.ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារះ

៤.ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

៥.ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

៦.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ជាទូទៅការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត។

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

**១.១.ដើម្បីបញ្ចប់បទល្មើសឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី**

ជាធម្មតាបទល្មើសមួយកើតឡើង យើងតែងប្រទះឃើញមានជនល្មើស និងជនរងគ្រោះ ឬអាចឈានទៅដល់មានអ្នកទទួលខុសត្រូវរដ្ឋប្បវេណីថែមទៀតផង។ ប៉ុន្តែបទល្មើសតែងបង្កើតឡើងដោយជនល្មើសហើយត្រង់ចំណុចនេះហើយទើប ច្បាប់បានបង្កើតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នដែលជាសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការឃុំខ្លួនជននោះកុំឲ្យគាត់ដើរបន្តប្រព្រឹត្តបទល្មើសទាំងនោះតទៀត ក៏ដូចជាទប់ស្កាត់កុំឲ្យបទល្មើសនោះកើតជាថ្មីម្តងទៀត។

**១.២.ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមាន ការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទនិងអ្នកសមគំនិត**

គ្មានមនុស្សណាម្នាក់ដែលសប្បាយទេ នៅពេលដែលខ្លួនចាញ់ក្តីនោះហើយពេលខ្លះមនុស្សដើម្បីចង់ទទួលបានជ័យជម្នះហ៊ានធ្វើអ្វីៗ គ្រប់យ៉ាងដើម្បីវាបើទោះបីពេលខ្លះសកម្មភាពទាំងនោះខុសច្បាប់ក៏ដោយ យល់ឃើញបែបនេះចង់ ឬមិនចង់ច្បាប់ត្រូវតែកំណត់ផ្តល់នូវសិទ្ធិយ៉ាងធំទូលាយដល់ចៅក្រមស៊ើបសួរ ក្នុងការឃុំខ្លួនជននោះដើម្បីកុំឲ្យជនត្រូវចោទនោះមានសេរីភាពក្នុងការអុកឡុកសាក្សី ឬជនរងគ្រោះក្នុងរូបភាពណាមួយ ដើម្បីផលប្រយោជន៍អវិជ្ជមានរបស់ខ្លួន។ ច្រើនជាងនេះទៅទៀតកាលបើជនត្រូវចោទមានសេរី ដូចនេះអ្នកសមគំនិត ឬផ្តើមគំនិតនឹងងាយស្រួលក្នុងការផ្តោះប្តូពាក្យសម្តី ឬប្រាប់ពីឧបាយកលដល់ជនត្រូវចោទ

ក្រោមរូបភាពផ្សេងៗ ក្នុងការអនុវត្តក្នុងពេលសាវនាការជាដើម ។ឧទាហរណ៍ដូចជាអ្នកសមគំនិតប្រាប់ជនត្រូវចោទឲ្យនិយាយពាក្យមិនពិតនៅចំពោះមុខអង្គជំនុំជម្រះឬប្រាប់ពីរបៀបក្នុងការឆ្លើយនូវសំណួរជាដើម។

**១.៣.ដើម្បីរក្សាភស្តុតាងឬតម្រុយជាសម្ភារៈ**

ភាគច្រើនមនុស្សគ្មាននរណាអ្នកនឹងសប្បាយចិត្តទេ នៅពេលដែលមានភស្តុតាង ឬតម្រុយណាមួយដែលនិយាយថាអ្នកបានប្រព្រឹត្តខុស ឬបង្ហាញពីភាពមិនប្រក្រតីរបស់ខ្លួនទៅកាន់មនុស្សជុំវិញខ្លួននោះ ដូចនេះប្រសិនបើមានឱកាស បុគ្គលទាំងនោះអាចនឹងត្រលប់ទៅលាងសម្អាតរាល់ភាពអវិជ្ជមានរបស់ខ្លួន ឬកំហុសរបស់ខ្លួនដែលខ្លួនបានប្រព្រឹត្ត ។ដែលមានគោលបំណងចង់រត់គេចពីនីតិវិធីផ្លូវច្បាប់ ដូចនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ មានចែងក្នុងការរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈក្នុងរឿងក្តីនីមួយៗដើម្បីសម្រួលដល់ការស្វែងរកយុត្តិធម៌ឲ្យបានឆាប់រហ័ស។

**១.៤.ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី**

ការធានាក្នុងការរក្សាទុកជនត្រូវចោទគឺចាំបាច់ណាស់ក្នុងការបន្តនីតិវិធីនៃរឿងក្តី។ វត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការគឺជារឿងដ៏សំខាន់ព្រោះជនជាប់ចោទគឺជាបណ្តុំនៃមូលហេតុ និងព័ត៌មានផ្សេងៗទៀត ដែលវាមានអត្ថប្រយោជន៍ដូចជាការផ្តល់នូវមូលដ្ឋាននៃអង្គហេតុ ដំណើររឿង ដើមទងនៃរឿងជាដើមទៅដល់ចៅក្រមជំនុំជម្រះក្នុងការសម្រេចអ្នកណាឈ្នះអ្នកណាចាញ់។ ជារឿយៗក្នុងសង្គមបច្ចុប្បន្នយើងឃើញថាសាលក្រមកំបាំងមុខភាគច្រើនតែងត្រូវបានពិរុទ្ធជនប្តឹងទាស់ដែលមិនយល់ស្របជាមួយលទ្ធផលដែលសម្រេចលើខ្លួន (មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ពេលខ្លះពិរុទ្ធជនមានពាក្យពេចន៍ចង់បង្ហាញដល់សវនាកា ឬប្រាប់ពីព្រឹត្តការណ៍ណាមួយដែលចៅក្រមជំនុំជម្រះ ឬចៅក្រមស៊ើបសួរពុំបានរកឃើញ។ ដូចនេះការរក្សាទុកជនត្រូវចោទសម្រាប់តុលាការគឺជាហេតុផលដ៏ល្អក្នុងការឃុំជនជាប់ចោទ។

**១.៥.ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ**

ក្នុងករណីមួយចំនួនសម្រាប់បទល្មើសឧក្រិដ្ឋ តុលាការត្រូវតែឃុំខ្លួនជនជាប់ចោទទុកដើម្បីរក្សានូវចម្លើយក៏ដូចជាដើមហេតុនៃបទល្មើសផងដែរ ព្រោះជួនកាលជនជាប់ចោទដែលជាជនល្មើសរូបនោះគ្រាន់តែស៊ីឈ្នួលពីបុគ្គលមួយចំនួនដូចជាអ្នកសមគំនិត អ្នកផ្តើមគំនិត ឬដទៃជនផ្សេងៗទៀតដែលចូលរួមប្រព្រឹត្តបទល្មើសនោះដោយប្រយោល។ ដូចនេះក្នុងចំណោមបុគ្គលដែលបានរៀបរាប់ខាងលើអាចនឹងសម្លាប់ជនជាប់ចោទបំបិតមាត់ ប្រសិនបើតុលាការអនុញ្ញាតឲ្យមានសេរីភាព ព្រោះពួកគេអាចគិតថាជនជាប់ចោទអាចនឹងសារភាពហើយបកអាក្រាតពីសាវដាររបស់ពួកគេដូចនេះចង់ឬមិនចង់ពួកគេនឹងសម្លាប់ជននោះបំបិតមាត់។

**១.៦.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស**

ចៅក្រមស៊ើបសួរអាចគិតថាប្រសិនបើដោះលែងជនជាប់ចោទឲ្យមានសេរីភាព បុគ្គលរូបនោះអាចនឹងទៅប្រព្រឹត្តបទល្មើសនោះដដែលដោយមិនរៀងចាលដោយសារតែភាពអំណួតរបស់ខ្លួន ឬតាមការបង្កប់ពីជនសមគំនិតណាម្នាក់ ឬតាមការគាបសង្កត់ផ្លូវណាតាមវិធីណាមួយ។ ជាទូទៅចៅក្រមស៊ើបសួរតែងគិតអំពីស្ថានភាពនៃបទល្មើស ឬអត្តចរិករបស់ជននោះជាមុន មុនពេលសម្រេចក្នុងការអនុញ្ញាតឬមិនអនុញ្ញាតឲ្យជននោះមានសេរីភាព ឬបិទសិទ្ធិមួយចំនួន។ ការធ្វើបែបនេះគឺពិតជាល្អប្រសើរណាស់ទៅដល់គូភាគីនៅក្នុងរឿងក្តីផង និងមានប្រយោជន៍ដោយប្រយោលទៅដល់ប្រជាពលរដ្ឋផងដែរតាមរយៈបង្ការ ដូចពាក្យចាស់លោកពោលថា "ការពារប្រសើរជាងព្យាបាល" ដូចនេះកុំចាំដល់ជនជាប់ចោទប្រព្រឹត្តម្តងទៀតហើយចាំឃុំនោះ ចង់ឬមិនចង់ជននោះអាចមានអត្តចរិកក្មេងក្មាង កាច ក្រអើតក្រទម មិនអោយតម្លៃអ្នកដទៃ ឆេវឆាវជាដើមចៅក្រមស៊ើបសួរនឹងធ្វើការឃុំខ្លួនជននោះទៅតាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧។

## កថាខណ្ឌ២-នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

**២.១.ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

- ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន
- ការឃុំខ្លួនបណ្តោះអាសន្នដោយគំនិតផ្ទាល់ខ្លួនបន្ទាប់ពីស្នើយោបល់ពីព្រះរាជអាជ្ញា
- ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នមានន័យថាចាំបាច់ត្រូវតែចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន
- ការឃុំខ្លួនក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

**២.១.១.ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន**

ដីកាបង្គាប់ឲ្យឃុំ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលឃុំខ្លួនជនជាប់ចោទដែលមានតែ ចៅក្រម ស៊ើបសួរទេអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានយោងតាមមាត្រា២១៩ និង មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នមានន័យថាចាំបាច់ត្រូវតែចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ទើបចៅក្រមមានមូលដ្ឋានគតិយុត្តិដោយសំអាងហេតុ ដែលនាំឲ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែចៅក្រមស៊ើបសួរ មិនអាចដាក់ចេញដីកាបង្គាប់ឲ្យឃុំខ្លួនមុនដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ននោះទេដោយហេតុថាដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវបំពេញបន្ថែមលើដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវភ្ជាប់ទៅជាមួយជនជាប់ឃុំតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាធរមានសមត្ថកិច្ចទៅប្រធានពន្ធនាគារ ឬ

មណ្ឌលឃុំខ្លួន ត្រូវតែទទួលឃុំខ្លួនបុគ្គលណាមួយដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនប៉ុណ្ណោះ រហូតទាល់តែដល់មានការទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ (មាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) មានន័យថាបុគ្គលណាដែលជាប់ឃុំដោយគ្មានសេចក្ដីសម្រេចពីតុលាការណាមួយ ឬដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនទេ នោះធ្វើឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន មិនអាចឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនបានឡើយ ព្រោះប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអាចប្រឈមមុខ និងការប្រព្រឹត្តបទល្មើសទាក់ទិន និងការបង្ខាំងមនុស្សដោយខុសច្បាប់។ ដោយច្បាប់ធានារ៉ាប់រង មិនឲ្យមានការរំលោភបំពានលើរូបកាយបុគ្គលណាមួយឡើយ ហើយច្បាប់ត្រូវធានាការពារជីវិត កិត្តិយស កេរ្តិ៍ឈ្មោះ សេចក្ដីថ្លៃថ្នូររបស់បុគ្គលគ្រប់រូប ប៉ុន្តែបើមានការចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនជនណាម្នាក់ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តតាមបញ្ញត្តិច្បាប់ចែងជាធរមាន ដែលច្បាប់ហាមឃាត់មិនឲ្យធ្វើឡើងចំពោះការបង្ខិតបង្ខំធ្វើបាបលើរូបកាយ ឬប្រព្រឹត្តកម្មណាមួយដែល បន្ថែមទណ្ឌកម្មអនុវត្តលើជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ។ ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោសដរាបណា តុលាការផ្ដន្ទាទោសជាស្ថាពរ(ផ្អែកតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ)។ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមាន និទ្ទេសពិស្ដារដូចតទៅ៖

- អត្តសញ្ញាណជនត្រូវចោទ។
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។
- ឈ្មោះ និងឋានៈ របស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ (ដោយយោងតាមមាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម។

### ២.២.១.ការឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ទាល់ខ្លួនបន្ទាប់ពីស្នើយោបល់ពីព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរចេញដីកាសម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នតាមគំនិតខ្លួនឯងផ្ទាល់ និងតាមសេចក្ដីសន្និដ្ឋានស្ថាពររបស់ព្រះរាជាអាជ្ញា ក្រោយពីជនជាប់ចោទបង្ហាញខ្លួនលើកដំបូងបន្ទាប់ពីចៅក្រមស៊ើបសួរ ធ្វើការកត់កំណត់ហេតុទាញហេតុផលលើជនត្រូវចោទ នៃមូលវិចារគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ នៅក្រោយពេលចៅក្រមស៊ើបសួរ ទទួលបណ្ដឹងតាមរយៈដីកាសន្និដ្ឋានស្ថាពរបញ្ជូនសំណុំរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា។ [3]មានន័យថាចៅក្រមស៊ើបសួរត្រូវដោះលែង ឬឃុំខ្លួនបណ្ដោះអាសន្ននៅពេលជនជាប់ចោទបង្ហាញខ្លួន លើកដំបូងនៅចំពោះមុខតុលាការ ទោះបីជាមានការប្ដឹងឧទ្ធរណ៍

[3] មាត្រា២០៦នៃក្រមវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ពីជនជាប់ចោទ ឬជនត្រូវចោទក៏ដោយ ចៅក្រមស៊ើបសួរនៅតែឃុំខ្លួនដដែល ដោយហេតុថាព្រះរាជអាជ្ញាបានឯកភាពរួចហើយលើកលែងតែមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើសេចក្តីសម្រេចនេះ នាំឲ្យដីកានេះលែងមានអានុភាពអនុវត្តភ្លាម ប្រសិនជាមានសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បង្គាប់ឲ្យដោះលែង។ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។[4]

ចៅក្រមស៊ើបសួរបិទការស៊ើបសួរ ចេញដីកាដំណោះស្រាយ បញ្ជូនជនជាប់ចោទទៅជម្រះ ឬលើកលែងចោទប្រកាន់នៅចំពោះមុខតុលាការ។ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាឡើយ។ ហើយចៅក្រមស៊ើបសួរអាចរក្សាទុកជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលមានអានុភាពរយៈពេល៤ខែ ប្រសិនបើមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេល ៤ខែទេនោះ ត្រូវដោះលែងឲ្យនៅក្រៅឃុំដោយស្វ័យភាព ប៉ុន្តែក្រោយពីដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរហើយ បើមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ ហើយអាចឃុំខ្លួនជនជាប់ចោទវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអង្គហេតុថ្មីនោះឡើយ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេប្រសិនបើអង្គហេតុនោះ ជាស្ថានទម្ងន់ទោសលើអង្គហេតុដែលចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។[5]

**២.១.៣.ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាមានសិទ្ធិ សុំឲ្យចៅក្រមស៊ើបសួរឃុំខ្លួនជនប្រព្រឹត្តបទល្មើសជាបណ្តោះអាសន្នតាមដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរនៅគ្រប់ពេលវេលានៃការស៊ើបសួរ ដែលខ្លួនយល់ថាមានប្រយោជន៍ទៅលើការចោទប្រកាន់ ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋរបស់ព្រះរាជអាជ្ញាជាការចាំបាច់ខានមិនបានឡើយ ប៉ុន្តែក្នុងករណីបទមជ្ឈិមអាច បើការស៊ើបសួរបានដូចការស៊ើបសួរបទឧក្រិដ្ឋ ហើយបញ្ជូនទៅជម្រះផ្ទាល់ភ្លាម ដែលព្រះរាជអាជ្ញាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង។

ប្រសិនចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងរយៈពេល១៥ថ្ងៃ ត្រូវបញ្ជាក់ពីអង្គហេតុ ហើយជូនព័ត៌មានទៅព្រះរាជអាជ្ញាក្នុង

[4] មាត្រា២៧០នៃក្រមឧិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[5] មាត្រា១២៧,២៤៧,២៤៩,២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

រយះពេលយ៉ាងខ្លីបំផុត ប៉ុន្តែក្នុងករណីចៅក្រមស៊ើបសួរមិនសំរេចក្នុងរយះពេល១៥ថ្ងៃទេ ព្រះរាជអាជ្ញាអាច ប្តឹងដោយផ្ទាល់តាមពាក្យសុំទៅឲ្យសភាស៊ើបសួរជំនួសចៅក្រមស៊ើបសួរ ប្រឆាំងលើបុគ្គលណាម្នាក់ ឬច្រើន នាក់ ដោយមានចង្អុលបង្ហាញប្រាប់ឈ្មោះ ឬប្រឆាំងលើអញ្ញាតជន ដែលក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវ បញ្ជាក់ពីអត្តសញ្ញាណ នៃជនជាប់ចោទសេចក្តីសង្ខេបនៃរឿងក្តី ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ បង្ក្រាបបទល្មើស និងព្រមទាំងចង្អុលប្រាប់ពីតុលាការ ទីកន្លែង កាលបរិច្ឆេទ ម៉ោងពេលនៃសវនាការ។[6]

ព្រះរាជអាជ្ញាសុំឲ្យចៅក្រមស៊ើបសួរចោទប្រកាន់ ព្រមទាំងជា យថាហេតុឃុំខ្លួនជនសង្ស័យ ក្រោយពី បានពិនិត្យសំណុំរឿងពីនគរបាលយុត្តិធម៌រួច ធ្វើការរៀបចំដីកាសន្និដ្ឋានស្ថាពរមួយទុកជាសេចក្តីផ្តើមចោទ យោងតាមអង្គហេតុជាក់ស្តែង និងដែនកំណត់បទល្មើសស្របតាមបញ្ញត្តិច្បាប់នីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៣ វាក្យខណ្ឌទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនដំណឹង ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹង និងមេធាវី ហើយ២ថ្ងៃក្រោយចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យ ព្រះរាជអាជ្ញាពិនិត្យ ប្រសិនបើ ព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ក្នុងរយះ ពេល១៥ថ្ងៃ ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួន និង ១ខែ ក្នុងករណីជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញា បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរ ក្នុងចិរវេលា ២៤ ម៉ោងដោយដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយ។[7]

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ការស៊ើបសួរត្រូវបានបញ្ចប់ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ បន្ទាប់មកព្រះរាជអាជ្ញាអាចប្តឹងទៅ ចៅក្រមស៊ើបសួរសំរេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬលើកលែងចោទប្រកាន់ មានចែង ក្នុងមាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បានកាលណា ចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទដែល ជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុក នៅក្នុងពន្ធនាគាររហូតដល់ផុតរយះពេលសំរាប់ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យ ដោះលែងជនត្រូវចោទនោះភ្លាម។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកានោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់ នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវរក្សាទុកក្នុងពន្ធនាគាររហូតដល់សភាស៊ើបសួរបានសម្រេចអំពីបណ្តឹង

[6] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

[7] មាត្រា១៣៥ នៃក្រមឱវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ឧទ្ធរណ៍។[8]

### ២.១.៤.ការឃុំខ្លួនក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័ត៌មានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅ របស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួន ដូចជាជនត្រូវចោទជាអនីតិជនជាស្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬជនត្រូវចោទចាស់ជរា។ល។ ក្នុងករណីបែបនេះបើអាចជៀសវាងបានមិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។[9]

ជនសង្ស័យបន្ទាប់ពីចូលខ្លួនលើកដំបូងចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចថា ត្រូវឲ្យជនសង្ស័យឲ្យនៅក្រៅឃុំ ឬឃុំខ្លួនទុកជាបណ្តោះអាសន្ន ដោយគំនិតដោយផ្ទាល់ ឬក្រោយពីមានសេចក្តីសន្និដ្ឋានស្ថាពរបញ្ជូនសំណុំរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ព្រោះថាការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលត្រូវបានប្តឹងទៅចៅក្រមស៊ើបសួរ ដោយយោងតាមមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលណាម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ហើយការបើការស៊ើបសួរតាមដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួរដល់ចៅក្រមស៊ើបសួរ លុះត្រាតែមានសេចក្តីសង្ខេបនៃអង្គហេតុ ចង្អុលប្រាប់ឈ្មោះបទល្មើស បង្ហាញពីអត្ថបទច្បាប់ និងបង្ក្រាបបទល្មើស ឬឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ តាមការកំណត់ដោយមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាផង។ បើមិនគោរពតាមទម្រង់នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចាត់ទុកជាមោឃៈ ដែលជាហេតុនាំឲ្យគ្មានភស្តុតាងបញ្ជាក់ដល់ជនប្រព្រឹត្តបទល្មើសសំណុំរឿងត្រូវបានបញ្ចប់នៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៤៨

ការឃុំខ្លួនជនសង្ស័យ ឬចារី របស់ចៅក្រមស៊ើបសួរ គឺជាវិធានការចុងក្រោយបំផុត ក្នុងការឃុំឃាំងជនល្មើសក្នុងមួយរយៈស៊ើបសួរភាគខ្លះ ឬទាំងស្រុង ទោះជាវិធានការនេះបានដកសិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់បុគ្គលក៏ដោយ តែវាជាការចាំបាច់អត់ឃុំមិនបានប្រសិនបើចៅក្រមយល់ឃើញថា៖

- ខ្លាចក្រែងជនសង្ស័យរត់គេចខ្លួន ដោយគ្មានអ្វីធានាបានថា ជនសង្ស័យប្រាកដជាមកបង្ហាញខ្លួនចំពោះមុខតុលាការវិញ ដែលបានដឹងថាខ្លួនត្រូវបានតុលាការចោទប្រកាន់ ឬក៏ធ្វើការគាបសង្កត់លើសាក្សី ដើម្បីរារាំងសំដែងឲ្យដឹងពីការពិតនោះ ឬគ្មានការងារធ្វើពិតប្រាកដ គ្មានគ្រួសារ គ្មាន

[8] មាត្រា២៧៦ នៃក្រមឧិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[9] សន្និសិទស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឆ្នាំ២០១២ ទំព័រ៨

ទីលំនៅមិនប្រាកដ ឬអាចរារាំងដល់ការចោទប្រកាន់ ការជំនុំជម្រះ ព្រមទាំងពិបាកក្នុងការអនុវត្ត សាលក្រមទៀតផង ។

- ជាពិសេសមានលក្ខណៈងាយស្រួលដល់ការស៊ើបសួរ ស្វែងរកភស្តុតាងជាក់ ឬដោះបន្ទុកលើចារី ហើយងាយដំណើរការបញ្ចប់រឿងក្តី មានចែងក្នុងមាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ដោយមានសំណើសុំឲ្យធ្វើការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទតាមសំណើរបស់តំណាងអយ្យការអមតុលាការខេត្តទៅ (ជនរងគ្រោះ) ក្រុង ឬតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី/ចៅក្រមស៊ើបសួរ។

តាមបទពិសោធន៍និងការអនុវត្តជាក់ស្តែង ដែលអាចទទួលបានឃើញថា ការឃុំខ្លួនបណ្តោះអាសន្នត្រូវអនុវត្តដូចខាងក្រោម៖[10]

- ជនត្រូវចោទ ឬជនជាប់ចោទ គឺត្រូវឃុំខ្លួនបណ្តោះអាសន្ន
- ជនត្រូវចោទ ឬជនជាប់ចោទ ដែលបានប្រព្រឹត្តបទល្មើសជាបទឧក្រិដ្ឋ
- ជនត្រូវចោទ ឬជនជាប់ចោទ ដែលបានប្រព្រឹត្តបទមជ្ឈិម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ហើយមានសំអាងបញ្ជាក់ថាជននោះរត់គេចខ្លួន ឬបង្អាកដល់ដំណើរការស៊ើបសួរ ការជំនុំជម្រះ ពិបាកអនុវត្តសាលក្រម និងបន្តការប្រព្រឹត្តអំពើល្មើសទៀត។

តាមច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ចរិកនៃគ្រោះថ្នាក់ដល់សង្គមនៃការប្រព្រឹត្តបទល្មើស និងកំរិតនៃទោសដាក់ពន្ធនាគារដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ ពុំត្រូវបានលើកយកមក ធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចលើការឃុំខ្លួននោះទេ គឺជាក់ស្តែងតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា៖ មានតែចៅក្រមទេដែលជាអ្នកសម្រេចលើការឃុំខ្លួន ជនជាប់ចោទក្នុងកន្លែងឃុំឃាំង តាមសេចក្តីស្នើសុំរបស់ព្រះរាជអាជ្ញា ដែលបានបារម្ភណ៍ខ្លាចក្រែង ជនត្រូវចោទរត់គេចខ្លួន ដោយគ្មានការធានាបានថាជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ។

ទោះបីជាការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងករណីខាងលើក៏ដោយ នោះចៅក្រមគប្បីពិចារណា ព្រមទាំងប្រើប្រាស់នូវវិធានការរារាំង ផ្សេងៗ ក្រៅពីការឃុំខ្លួនជាបណ្តោះអាសន្ន ចំពោះជនដែលត្រូវចោទ ឬជនជាប់ចោទ ដែលជានារីមានផ្ទៃពោះ ឬមានកូនបៅដោះ ក្រោមអាយុ១២ខែ នៅឡើយ ឬជាជនចាស់ជរា មានជម្ងឺជាទំងន់ដែលមានលំនៅច្បាស់លាស់ លើកលែងតែក្នុងករណីពិសេសចាំបាច់បំផុត ដូចជាអំពើល្មើស

[10] គន្លឹទី៤ ការស៊ើបសួរ មាតិកាទី១ ចៅក្រមស៊ើបសួរ ជំពូកទី៣វិធានការនិរន្តរាយ ផ្នែកទី៦ដីកាបង្គាប់ឃុំខ្លួន

ប្រព្រឹត្តយ៉ាងព្រៃផ្សៃ និងអមនុស្សធម៌។ ប៉ុន្តែក្នុងករណីមួយចំនួនច្បាប់ក៏មិនអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នបានដែរដូចជាៈ

- ក្រោយពីបានធ្វើការស៊ើបសួរលើរឿងក្តីទៅឃើញថាជនដែលបានប្រព្រឹត្តអំពើល្មើស ជាបទល្មើសរដ្ឋប្បវេណី និងជាបទល្មើសផ្សេងក្រៅពីបទល្មើសព្រហ្មទណ្ឌ ឬមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់(ម.៤១ ក្រមព្រហ្មទណ្ឌ)។
- ជនល្មើសដែលមិនទទួលខុសត្រូវដោយមូលហេតុវិបល្លាស្មារតី (ម.៣១ ក្រមព្រហ្មទណ្ឌ)។
- ជនដែលប្រព្រឹត្តអំពើល្មើសជាបទលហុ តែតុលាការផ្តន្ទាទោសជាប្រាក់ពិន័យវិញ។
- ជនដែលបានអង្កេតចប់ទៅឃើញថា មិនបានប្រព្រឹត្តបទល្មើស។
- ជនល្មើសជាអនីតិជន ដែលមានអាយុតិចជាង១៤ ឆ្នាំ (ម.២ ១២ នីតិវិធីក្រមព្រហ្មទណ្ឌ)។
- ជនល្មើសត្រូវបានអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ (ម.៣២ នៃក្រមព្រហ្មទណ្ឌ)ៗ។
- ជនល្មើសត្រូវបានការការពារ និងសច្ចធារណ៍ស្របច្បាប់ (ម.៣៣-៣៤ នៃក្រមព្រហ្មទណ្ឌ)។
- ជនល្មើសប្រព្រឹត្តក្នុងស្ថានភាពចាំបាច់ និងអានុភាពកំលាំងបង្ខំ(ម.៣៥-៣៦ ក្រមព្រហ្មទណ្ឌ)។
- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌមិននាំឲ្យមានទណ្ឌកម្មណាមួយទេ(ម.៣៧ក្រមព្រហ្មទណ្ឌ)

**២.២.សៀវភៅឃុំខ្លួនបណ្តោះអាសន្ន**

សៀវភៅឃុំខ្លួនត្រូវបានគ្រប់គ្រងដោយព្រះរាជអាជ្ញា សៀវភៅឃុំខ្លួនប្រើសំរាប់ចុះយកលេខ ថ្ងៃ ខែ ឆ្នាំ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាបង្គាប់ឲ្យឃុំខ្លួនបន្ត ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងដីកាសម្រេចមិនឃុំរបស់ចៅក្រមស៊ើបសួរដោយក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរ ជាអ្នករៀបចំដីកាឃុំខ្លួនរួចសរសេរចូលទៅក្នុងសៀវភៅឃុំខ្លួន ដើម្បីយកលេខ ថ្ងៃ ខែ ឆ្នាំ ហើយរក្សាទុកក្នុងសំណុំរឿង និងសរសេរចុះក្នុងសៀវភៅទទួលបណ្តឹងព្រហ្មទណ្ឌ។[11]

ដីកាឃុំខ្លួន ត្រូវសរសេរបំពេញចំនួនពីរច្បាប់ដូចៗគ្នា មួយច្បាប់ត្រូវបញ្ជូនទៅពន្ធនាគារជាមួយជនជាប់ចោទ តាមរយៈនគរបាលយុត្តិធម៌ ឬកងការពារពន្ធនាគារ ឬសមត្ថកិច្ចនាំជនល្មើសទៅមន្ទីរឃុំឃាំង និងមួយច្បាប់ទៀតត្រូវរក្សាទុកក្នុងសំណុំរឿងតំកល់ទុកនៅតុលាការរង់ចាំសេចក្តីសម្រេចដោះលែង ដោយដីកាដំណោះស្រាយពីតុលាការ។ តាមគោលការណ៍ក្រមនីតិវិធីព្រហ្មទណ្ឌគ្រប់រាល់ដីកាបញ្ជូនទាំងអស់ចំបាច់ត្រូវមានសរសេរបំពេញចំនួនពីរដូចៗគ្នា ដោយមួយច្បាប់រក្សាទុកក្នុងសំណុំរឿង ហើយមួយច្បាប់ទៀតភ្ជាប់

[11] សៀវភៅក្បួនឌីពីពីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១៤៦ដល់១៦០ នៅឆ្នាំ ២០០៦

ជាមួយដីកាដែលបញ្ជូនចេញ។ ដីកាឃុំខ្លួនត្រូវធ្វើរៀបឡើងជាពីរច្បាប់ដូចៗគ្នាគឺដើមដីកា និងចុងដីកា ចំពោះដីកាដែលបញ្ចេញត្រូវចុះហត្ថលេខាដោយជនដែលទទួលដីកា ហើយបង្វិលដើមដីកាមក តុលាការវិញ ដើម្បីទុកជាសក្ខីប័ណ្ណ នៃសំណុំរឿង រួចដាក់ក្នុងក្រូណូ ឬមាតិកាតាមតារាងលេខរៀងនៃលំដាប់។[12]

នៅមន្ទីរឃុំឃាំង ឬពន្ធនាគារមិនអាចទទួលពិរុទ្ធជន ឬអ្នកទោសបានទេ ប្រសិនបើគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនពីតុលាការបញ្ជូនមកជាមួយទេនោះ(មានចែងក្នុងមាត្រា១៧នៃច្បាប់ពន្ធនាគារ)។

### ២.២.១.កំណត់ហេតុស្តីពីបញ្ជីជនជាប់ឃុំខ្លួនបណ្តោះអាសន្ន

គ្រប់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទាំងអស់ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទ នៃការឃុំខ្លួន និងកាលបរិច្ឆេទ នៃការដោះលែង ដែលបញ្ជីនេះត្រូវត្រួតពិនិត្យបានគ្រប់ពេលវេលា ត្រូវចុះទិដ្ឋាការដោយអយ្យការ។ គ្រប់ភ្នាក់ងារ នៃរដ្ឋបាលពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញ ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ហើយភ្នាក់ងាររដ្ឋបាល ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតអនុញ្ញាចេញពីអាជ្ញាធរតុលាការនោះឡើយ ប្រសិនបើមានការឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញពីអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធភាពពីបទបង្ខាំងមនុស្សដោយខុសច្បាប់ នៅពេលនោះគ្រប់ចៅក្រមទាំងអស់ ដែលទទួលបណ្តឹងស្តីការឃុំខ្លួន បុគ្គលណាម្នាក់ដោយខុសច្បាប់នោះ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាការចាំបាច់ភ្លាម។

### ២.២.២.ទំរង់ពិស្តារស្តីពីការឃុំខ្លួនបណ្តោះអាសន្ន

ដីកាឃុំខ្លួនចេញដោយចៅក្រម ដែលបញ្ជាក់ជាលាយលក្ខណ៍អក្សរ ត្រូវចុះនិទ្ទេសដូចជា៖

- លេខ ថ្ងៃ ខែ ឆ្នាំ ទទួលវត្ថុតាង
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- ឈ្មោះ និងសាវតាជាតិជនល្មើស
- បទល្មើស ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ប្រព្រឹត្តបទល្មើស និងអត្ថបទច្បាប់បង្ក្រាបបទល្មើស
- វត្ថុតាង និងស្ថានភាព នៃវត្ថុតាង
- ឈ្មោះអ្នកទទួលវត្ថុតាង
- សេចក្តីសម្រេច និងសេចក្តីផ្សេងៗ។

[12] មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចុះកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា មានចែងក្នុង មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២.៣.រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ**

ជាគោលការណ៍ទូទៅការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ មិនឲ្យលើសពីរយៈពេល៦ខែបានទេ ហើយគ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តីយ៉ាងយូរ ៦ខែក្រោយការចាប់ខ្លួន។[13]

ចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនមិនឲ្យលើសពី១ ឆ្នាំបានទេ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចពន្យាពេលឃុំខ្លួនបណ្តោះអាសន្នម្តងបាន១ឆ្នាំ ដោយដីកាសំអាង ហេតុត្រឹមត្រូវ និងច្បាស់លាស់ ហើយការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន របស់ចៅក្រមស៊ើបសួរនេះបានតែ ២ដងគត់ ដោយយោងតាមមាត្រា២១០ នៃក្រមនីតិវិធី។ ការគិតចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះជនណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ចិរវេលា នៃការឃុំខ្លួនត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបើមាន ។[14]

**២.៣.១.ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជនករណីបទឧក្រិដ្ឋឬបទមជ្ឈិម**

ការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ ក្នុងករណីបទឧក្រិដ្ឋចំពោះនីតិជន មិនត្រូវឲ្យលើសពីរយៈពេល ៦ខែឡើយ ប៉ុន្តែចៅក្រមអាចបន្តរយៈពេលនេះរហូតដល់ទៅ ៦ខែ ប្រសិនបើមានតម្រូវការចាំបាច់ក្នុងការស៊ើបសួរ ចៅក្រមត្រូវបញ្ជាក់អំពីហេតុផល នៃការពន្យាពេលនេះឲ្យបានច្បាស់លាស់។

ប្រសិនបើការឃុំខ្លួនហួសរយៈពេលកំណត់ជនជាប់ចោទត្រូវបានដោះលែង បើទោះបីជាការស៊ើបសួរមិនទាន់ចប់សព្វគ្រប់ហើយក៏ដោយ។ យើងអាចបញ្ជាក់ឲ្យបានច្បាប់ថា នៅក្នុងកាលៈទេសៈបែបនេះបណ្តឹងអាជ្ញា មិនអាចបន្តបានទេ ហើយត្រូវតែបានបញ្ចប់។ គ្រប់ជនជាប់ពិរុទ្ធទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តីត្រូវតែបានទទួលការកាត់ក្តីយ៉ាងយូរបំផុត៦ខែក្រោយពីថ្ងៃចាប់ខ្លួន។

ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ក្នុងករណីបទមជ្ឈិម ការឃុំខ្លួនមិនឲ្យលើស៤ខែបានទេ។ នៅពេលផុតចិរវេលានៃការឃុំខ្លួន ចៅក្រមអាចពន្យាពេលឃុំខ្លួនបានតែម្តងគត់មិនឲ្យលើស២ដងទេ ដោយ

[13] មាត្រា២០៨ កថាខណ្ឌទី ១ នៃក្រមឌីពីវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២១ នៃក្រមព្រហ្មទណ្ឌអន្តរកាល ១៩៩២

[14] មាត្រា១៩៤ នៃក្រមឌីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤១ នៃក្រមព្រហ្មទណ្ឌ

ដីកានេះមានសំអាងហេតុច្បាស់លាស់ ចិរវេលា នៃការឃុំខ្លួននេះមិនត្រូវលើសពីពាក់កណ្តាល នៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់ឡើយ។

### ២.៣.២.ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម

អនីតិជនត្រូវបានពិចារណាលើអាយុរបស់គេ និងតម្រូវលើកស្ទួយការស្តារនីតិសម្បទា ដោយធានា កិច្ចការពារក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវជំនុំជំរះឲ្យបានឆាប់រហ័សក្នុងសវនាការត្រឹមត្រូវនៅចំពោះមុខ មេធាវី ជំនួយស្របច្បាប់ដទៃទៀត និងឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ លុះត្រាតែទង្វើនោះ ត្រូវបានចាត់ទុកថា បម្រើឲ្យឧត្តមប្រយោជន៍របស់កុមារ ជាពិសេសត្រូវពិចារណាលើអាយុ ឬស្ថានភាពរបស់ គេ ការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវជៀសវាងឲ្យអស់ពីលទ្ធភាពបំផុត។ រដ្ឋគួរតែចាត់វិធានការនានា ដើម្បី បង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជន ដ៏សមស្របមួយដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តអំពើដែលច្បាប់ ព្រហ្មទណ្ឌហាមឃាត់ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូចជាការសម្រុះសម្រួលរវាងជនល្មើស និងជនរង គ្រោះ ការប្រឹក្សាយោបល់ ឬដាក់ស្ថិតក្រោមកម្មវិធីអប់រំរបស់ជនល្មើសអនីតិជន។ អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នបានទេ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យអនីតិជននេះឲ្យឪពុកម្តាយ អ្នក អាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំកែប្រែថែរក្សាបណ្តោះ អាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ។[15] អនីតិជនដែលមានអាយុ១៤ដល់១៨ឆ្នាំមិនអាចជាប់ឃុំឃាំង បណ្តោះអាសន្នលើសពី១ខែឡើយ។[16] ប៉ុន្តែការឃុំខ្លួនអនីតិជនក្រោម១៨ឆ្នាំមិនត្រូវឃុំខ្លួនជាមួយនីតិជនបាន ឡើយ។

អនីតិជនដែលត្រូវឃុំខ្លួន មិនត្រូវទទួលរងទណ្ឌកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ ឬទង្វើណាមួយ ដែលនាំឲ្យខូចខាតដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ។ អនីតិជនដែលត្រូវស្ថិតនៅក្នុងការឃុំខ្លួនត្រូវ ទទួលបានការថែទាំប្រកបដោយមនុស្សធម៌ ហើយគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតរបស់មនុស្ស។[17]

- ការឃុំខ្លួនអនីតិជនទាក់ទងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានអាយុ១៤ ដល់១៨ឆ្នាំមាន៖
  - **ការឃុំខ្លួនអនីតិជនមានអាយុចាប់ពី១៤ដល់១៦ ឆ្នាំមានពីករណី**
    - ក្នុងករណីបទឧក្រិដ្ឋការឃុំខ្លួនមិនឲ្យលើសពី៤ ខែបានទេ
    - ក្នុងករណីបទមជ្ឈិមការឃុំខ្លួនមិនឲ្យលើសពី២ ខែបានទេ

[15] មាត្រា២១២ នៃនីតិវិធីក្រមព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[16] មាត្រា១៨៥ វាក្យខណ្ឌ២ នៃក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

[17] សេចក្តីណែនាំលេខៈ១ ក ០៩ ០៦ /យ សណឌ.,២០០៨ របស់ក្រសួងយុត្តិធម៌ ស្តីពីគោការណ៍យុត្តិធម៌អនីជន

❖ **ការឃុំខ្លួនអនីតិជនមានអាយុចាប់ពី១៦ដល់១៨ ឆ្នាំមានពីករណី**

- ក្នុងករណីបទឧក្រិដ្ឋការឃុំខ្លួនមិនឲ្យលើសពី៦ ខែបានទេ
- ក្នុងករណីបទមជ្ឈិមការឃុំខ្លួនមិនឲ្យលើសពី៤ ខែបានទេ

**២.៣.៣.ឧប្បទេវហេតុនៃការពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន**

កាលណាចៅក្រមស៊ើបសួរសម្រេចពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់ចម្លើយរបស់ជននេះ កាលណាជនត្រូវចោទមានមេធាវីអម មេធាវីត្រូវបង្ហាញមធ្យោបាយការពារកូនក្តីរបស់ខ្លួន ដើម្បីឲ្យរួចផុតពីការចោទប្រកាន់ពីបទល្មើស និងមានសេរីភាពត្រឡប់ទៅរស់នៅក្នុងសង្គមវិញ។[18]

ចៅក្រមស៊ើបសួរពន្យាពេលការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុព្រោះថាបទល្មើសមួយអាចមិនទាន់មានធាតុផ្សំគ្រប់គ្រាន់ក្នុងការបិទការស៊ើបសួរ ហេតុនេះចៅក្រមបន្តការឃុំខ្លួនក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកលើជនជាប់ឃុំ ដោយចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិមាត្រា២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ប៉ុន្តែក្នុងករណីហួសរយះពេល៦ខែ នៃការឃុំខ្លួន ឬហួសនៃការពន្យាពេលឃុំខ្លួន ទោះបីបានសម្រេចលទ្ធផល ឬមិនសម្រេចលទ្ធផលក្តីចៅក្រមស៊ើបសួរមិនអាចឃុំខ្លួនបន្តទៀតបានទេ។

ជាគោលការណ៍ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សច្ចធារណ៍នៃទោស គឺសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលការជំនុំជម្រះដោយមិនពន្យារពេលយូរផ្អែកតាមច្បាប់ ប៉ុន្តែការជំនុំជម្រះជនត្រូវចោទត្រូវធ្វើឡើងក្នុងរយះពេល ៦ខែ គិតចាប់តាំងពីពេលចាប់ខ្លួន មានន័យថាការឃុំខ្លួនជនជាប់ចោទ ឬជនត្រូវចោទបណ្តោះអាសន្នមិនលើសពី៦ខែឡើយ ប្រសិនបើលើអំឡុងពេល ៦ខែ មន្ត្រីដែលឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទ លើសរយះពេលកំណត់ដោយច្បាប់យ៉ាងណានោះ គឺរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ហេតុនេះអាចត្រូវផ្តន្ទាទោសជននេះបាន ចំណែកឯជនជាប់ចោទត្រូវទទួលការដោះលែង ឬយ៉ាងហោចណាស់យើងនិយាយតវ៉ាឲ្យលើកលែងការចោទប្រកាន់។ មូលដ្ឋានសំខាន់មួយនៃគោលការណ៍ទាំងនេះ គឺការសន្មតថាគ្មានទោសប្រសិនបើជនជាប់ចោទត្រូវបានសន្មតថាគ្មានទោសរហូតដល់មានសាលក្រមស្ថាពរ ដូចនេះការពន្យាពេលដើម្បីការស៊ើបសួរ ឬឃុំខ្លួនហួសកំណត់ដោយមិនបើកសវនាការ គឺជាការរំលោភបំពានមួយ ដែលមិនសមហេតុផល និងជាការរំលោភលើសិទ្ធិរបស់បុគ្គលផងដែរ។[19]

---

[18] មាត្រា២១១ ៩ក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

[19] សេចក្តីពន្យល់ នៃមាត្រាទាំងឡាយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការសម្រេចការឃុំខ្លួនបណ្តោះអាសន្ន ឆ្នាំ២០១៤

ការពន្យាពេលក្នុងការនាំខ្លួនជនជាប់ចោទមកសវនាការ គឺរំលោភសិទ្ធិមនុស្សជាមូលដ្ឋានរបស់បុគ្គលដល់ដំណើរការសវនាការ ដោយយុត្តិធម៌ពីព្រោះ វាអាចមានបុរេវិនិច្ឆ័យចំពោះសមត្ថភាពជនជាប់ចោទក្នុងការបង្ហាញនូវការការពារប្រកបដោយមានប្រសិទ្ធិភាព ក្នុងករណីនេះដែរធ្វើឲ្យមានសាក្សីសំខាន់ៗអាចត្រូវបានបាត់បង់ ឬស្លាប់ ភស្តុតាងអាចបាត់បង់ការចង់ចាំរបស់សាក្សីអំពីឧប្បទ្ទវហេតុមិនអាចគួរឲ្យជឿបាន ដោយរយៈពេលនៃការជំនុំជម្រះ អាចឲ្យការជំនុំជម្រះមិនអាចប្រកប ដោយភាពយុត្តិធម៌បាន ដូចនេះច្បាប់របស់កម្ពុជាបានកំណត់ថាជនជាប់ចោទត្រូវជំនុំជម្រះក្នុងអំឡុងពេល៦ខែ បន្ទាប់ពីចាប់ខ្លួនយ៉ាងយូរ។

កាលណាជនត្រូវចោទមានអាយុចាប់ពី១៨ ឆ្នាំឡើង ការឃុំខ្លួនបណ្តោះអាសន្នបទឧក្រិដ្ឋ ត្រូវពន្យាពេលបាន ២ដង ក្នុងម្តងបាន ៦ខែ ដោយឡែកការឃុំខ្លួនបណ្តោះអាសន្នចំពោះបទមជ្ឈិមអាចពន្យាពេលបានម្តងគត់ ដោយពន្យាពេលបាន២ខែ (មាត្រា២០៩-២០៨) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចិរវេលានៃការឃុំខ្លួនចំពោះបទមជ្ឈិម ដែលប្រព្រឹត្តដោយជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ មិនត្រូវលើសពីពាក់កណ្តាល នៃអប្បបរមា នៃទោសដែលកំណត់ដោយច្បាប់ឡើយ។ ប៉ុន្តែចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបាន២ដងគត់(មាត្រា២១០)នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.៤.សិទ្ធិមានទេចាតីសង្គ្រោះផ្នែកច្បាប់បន្ទាប់ពីឃុំខ្លួន

សិទ្ធិពឹងពាក់មេធាវីត្រូវបានធានាជនគ្រប់រូប ដែលជាប់ចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយហេតុថាជនត្រូវចោទទាំងអស់ មិនមែនសេរីភាពជាមូលដ្ឋានផ្នែកច្បាប់ដូចមេធាវីឡើយ ទោះជនត្រូវចោទខ្លះជាអ្នកច្បាប់ក៏ដោយព្រោះនៅពេលមានការចោទប្រកាន់ខ្លួន ឬជននេះមិនមានសេរីភាពដូចមេធាវីដែលជាជនវិជ្ជាជីវៈក្នុងវិស័យច្បាប់មានលក្ខណៈគ្រប់គ្រាន់ក្នុងការប្រើសិទ្ធិសេរីភាពពេញបរិបូរណ៍ទេ។ ម្យ៉ាងទៀតនៅពេលជនណាម្នាក់ត្រូវចោទប្រកាន់ខ្លួនត្រូវបានគេដកហូតនូវសិទ្ធិសេរីភាពមួយចំនួនដែលខ្លួនបានធ្វើសកម្មភាពឡើង នៅពេលប្រព្រឹត្តបទល្មើស ដូចនេះទើបគេផ្តល់សិទ្ធិឲ្យជនត្រូវចោទ ពឹងពាក់មេធាវី ទីប្រឹក្សាជនត្រូវចោទតាមលក្ខន្តិកៈមេធាវី។[20]

សិទ្ធិមានមេធាវីធានាថាជនជាប់ចោទមានឱកាស ក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈ ពីអ្នកជំនាញខាងតស៊ូមតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ពន្យល់ពីសិទ្ធិណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ ជាសេចក្តីតម្រូវការសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬក៏ជននោះជាអនីតិជន។

[20] សៀវភៅពិភាក្សាព្រហ្មហ្មទណ្ឌ ច្បាប់កម្ពុជា ទំព័រ ២៤៦-២៥៦

នៅខណៈដែលពុំមានការតម្រូវដោយច្បាប់ចំពោះ ការទទួលបានមេធាវីប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ជននោះនៅតែមានជម្រើសមានមេធាវីបើខ្លួនត្រូវការ។[21]

ក្នុងការសម្រេចចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដែលបញ្ជាក់ពី៖

- ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។
- ការពារខ្លួនដោយផ្ទាល់ខ្លួន ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន។
- ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់។
- ត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។[22]

ចំពោះគោលបំណងនៃការពារខ្លួននេះត្រូវអនុញ្ញាតឲ្យអ្នកទោសដែល មិនទាន់បានទទួលការកាត់ទោសរកជំនួយផ្នែកតុលាការ ដូចជាអ្នកច្បាប់ ឬសាក្សីជាដើម ដើម្បីការពារខ្លួនគេ។ ហើយត្រូវអនុញ្ញាតឲ្យទីប្រឹក្សាច្បាប់ចូលជួបអ្នកទោសទាំងនោះ ក្នុងគោលដៅរៀបចំការការពារខ្លួនសំរាប់ថ្ងៃកាត់សេចក្តីនៅមុខតុលាការ។ ទីប្រឹក្សាច្បាប់របស់អ្នកទោសម្នាក់ៗ អាចផ្តល់ឯកសារសំងាត់ផ្សេងៗ ឲ្យអ្នកទោសដែលគេការពារ។ ឯការសំភាសន៍រវាងទីប្រឹក្សា និងអ្នកទោសអាចប្រព្រឹត្តទៅបាននៅក្នុងមន្ទីរឃុំឃាំង ក្នុងស្ថានភាពដែលពួកគំរូតប្រចាំមន្ទីរអាចមើលឃើញ តែមិនអាចស្តាប់នូវការពិភាក្សានោះទេ មានចែងក្នុងមាត្រា៩៣ នៃបទបញ្ញតិជាបទដ្ឋានអប្បបរិមាសំរាប់ការគ្រប់គ្រង អ្នកទោស។

ជនជាប់ឃុំមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់ មេធាវី ដូចមានចែងក្នុងច្បាប់។ ជនជាប់ឃុំត្រូវទទួលបានការជូនដំណឹងភ្លាមអំពីសិទ្ធិត្រូវមានមេធាវី ពីអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីការចាប់ខ្លួនហើយត្រូវឃុំខ្លួនក្នុងទីកន្លែងសមរម្យ។ ប្រសិនជនជាប់ឃុំមិនទាន់មានសិទ្ធិ ឬមិនអាចមានលទ្ធភាពរក មេធាវីដោយខ្លួនឯងបាន នោះជនជាប់ឃុំអាចទទួលមេធាវី ដែលចាត់តាំង ដោយអាជ្ញាធរដ៏ទៃទៀត ដោយគ្មានការបង់ថ្លៃ ដើម្បីជាប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌។ ជនជាប់ឃុំឃាំងមានសិទ្ធិទំនាក់ទំនងជាមួយនឹងអ្នកតំណាងស្របច្បាប់របស់ខ្លួនបានគ្រប់ពេលវេលា ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកតំណាងស្របច្បាប់

[21] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ឆ្នាំ២០១២-២០១៣ ទំព័រ៣៣-៣៦

[22] រដ្ឋធម្មនុញ្ញមាត្រា៣១ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៥ កថាខណ្ឌ៣ ឆ្នាំ១៩៦៦

របស់ខ្លួន ត្រូវស្ថិតនៅកន្លែងដែលមានការការពារប៉ុន្តែមិនអាចស្តាប់បានឡើយ ពីមន្ត្រីអនុវត្តច្បាប់។ ការទំនាក់ទំនងរវាងជនជាប់ឃុំ និងអ្នកតំណាងស្របច្បាប់ មិនអាចទទួលយកជាភស្តុតាងសំរាប់ប្រឆាំងទៅលើជនជាប់ឃុំបានឡើយប្រសិនបើការពិភាក្សានោះ មិនពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសថ្មីណាមួយនោះទេ។[23]

**២.៤.១.សិទ្ធិវិជ្ជាជីវៈរបស់មេធាវី**

មេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌ នៃគណៈមេធាវី មានចែងក្នុងច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី មាត្រា១។

មេធាវីជាជំនួយផ្នែកច្បាប់ ដែលជាភាគីតែមួយគត់ក្នុងរឿងក្តីព្រហ្មទណ្ឌ មានវិជ្ជាជីវៈក្នុងវិស័យច្បាប់ច្បាស់លាស់ គឺដើម្បីការពារជនត្រូវចោទក្នុងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា ។

មេធាវីតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីច្បាប់ លើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងសង្គមកិច្ច។ ក្នុងរឿងព្រហ្មទណ្ឌ មេធាវីការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន។[24]

កាលណាជនដែលត្រូវគេចោទប្រកាន់មានសិទ្ធិទទួលបានជំនួយពីមេធាវី នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើជនជាប់ចោទមិនមានភាពច្បាស់លាស់តាមច្បាប់ ឬមិនមានការយល់ដឹងអំពីភាពស្មុគស្មាញក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ដែលត្រូវបានគេចោទប្រកាន់ ឬស្ថិតក្រោមការស៊ើបសួរត្រូវមានជំនួយតាមផ្លូវច្បាប់ភ្លាមៗ ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់ អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួនឬជាមុខងារដែលច្បាប់បានអនុញ្ញាត។

**២.៤.២.សិទ្ធិមានមេធាវីក្រោយការសម្រេចលើការឃុំខ្លួន**

**ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ មានចែងក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ។**

សិទ្ធិពឹងពាក់មេធាវីត្រូវបានធានាជូនជនគ្រប់រូប ដែលជាប់ចោទពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។[25] ទោះបីជាបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវទទួលការឃាត់ខ្លួនលើសរយៈពេល៤៨ ម៉ោង ដោយគ្មានបានទទួលជំនួយមេធាវីឡើយ ហើយក៏គ្មានជនណាម្នាក់ជាប់ឃុំនៅលើទឹកដីកម្ពុជាលើសពី

---

[23] គោលការណ៍អគ្គរជាតិ ស្តីពី ការការពារដល់ព្រប់ជនឌដែលទទួលការឃុំខ្លួន មាត្រា ១១,១៧១៨.

[24] ច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី មាត្រា២។

[25] មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៤៨ម៉ោង ដោយគ្មានជំនួយទីប្រឹក្សាច្បាប់ពីមេធាវី ឬអ្នកតំណាងដែលច្បាប់បានអនុវត្តទេ បន្ទាប់ក្រោយពីឃុំខ្លួន២៤ម៉ោងកន្លងផុតទៅ មេធាវីអាចចូលជួបកូនក្តីរបស់ខ្លួនបានរយៈពេល៣០នាទី ដោយរក្សាការសំងាត់ នៃការសន្ទនា ឬកត់ត្រានោះទេ។ [26]ហើយមេធាវីអាចបើកសំណុំរឿងក្តីតាំងពីដំបូង និងថតចំលងសំណុំរឿងទាំងអស់បាន។ ប៉ុន្តែមេធាវីមិនអាចឲ្យលិខិតថតចំលង នៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ មានចែងក្នុងមាត្រា១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មេធាវីជាភ្នាក់ងារដ៏សំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ ដែលមានគោលដៅចំបង ការពារដេញដោលដោះបន្ទុកលើការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់ក្នុងរឿងក្តីព្រហ្មទណ្ឌ ចាប់តាំងពីពេលចាប់ឃាត់ខ្លួន ឬឃុំខ្លួនរហូតដល់ដំណាក់កាលបើកសវនាការជំនុំជម្រះនៃការបញ្ចប់រឿងក្តីជាស្ថាពរ។[27]

ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាត្រូវប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ហើយដើមបណ្តឹងក៏អាចត្រូវតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់បានដែរ តែត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ តាំងពីជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង។[28]

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅយ៉ាងតិចបំផុត ៨ថ្ងៃមុនការស៊ើបសួរ ហើយជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ក្នុងថិរវេលានេះមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធីបាន ប៉ុន្តែប្រសិនបើមេធាវីដែលបានកោះហៅត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរក៏អាចសួរចំលើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវីបាន ដោយចុះនិទ្ទេសស្តីពីការអវត្តមាននេះក្នុងកំណត់ហេតុ សួរចំលើយជនត្រូវចោទ បន្ទាប់ពីជនត្រូវចោទចុះហត្ថលេខាយល់ព្រម។ តែក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចសួរចំលើយជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ បណ្តាលមកពីគ្រោះថ្នាក់ ដល់ស្លាប់ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាងដោយចុះក្នុងកំណត់ហេតុ។[29]

### ២.៤.៣.សិទ្ធិមានមេធាវីចំពោះអនីតិជនលើការឃុំខ្លួន

ចំពោះជនជាប់ចោទជាអនីតិជន ឬជនជាប់ចោទជាមនុស្សគថ្លង់ មនុស្សខ្វាក់ វិបត្តិស្មាតីត្រូវតែមាន

[26] មាត្រា៥១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[27] មាត្រា៩៨,៣៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងមាត្រា៣១ នៃច្បាប់ស្តីពីពន្ធនាគារ

[28] មាត្រា១៤៣កខ៣.,៣១៣៣១៨-, ៣៣០ ៤កខ៣.,៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ១០ .០៨ ២០០៧ និងមាត្រា២០ក /១ នៃច្បាប់ស្តីពីពន្ធនាគារ

[29]មាត្រា១៤៥,១៥០,២៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងមាត្រា៧៧នៃច្បាប់ស្តីគំនិតវិជំព្រហ្មទណ្ឌ ១៩៩២

មេធាវីអមជានិច្ច ទោះជាគ្មានការជ្រើសរើសដោយជនជាប់ចោទក៏ដោយ មេធាវីត្រូវចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីអំពីលក្ខន្តិកៈមេធាវី អាជ្ញាធរមានសមត្ថកិច្ចត្រូវតែជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ចែងក្នុង មាត្រា១៤៣ កថាខណ្ឌ៥ មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនិងមាត្រា៧៦ នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ។ កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗ នូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត។ ហើយការដែលកុមារជាប់សង្ស័យ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស និងច្បាប់ព្រហ្មទណ្ឌយ៉ាងហោចណាស់ត្រូវទទួលបាននូវការធានាដូចតទៅ៖

- ផ្តល់ទីប្រឹក្សាខាងផ្លូវច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត សម្រាប់ការរៀបចំ និងបង្ហាញនូវការការពារដល់កុមារ។

- ត្រូវទទួលការសាកសួរភ្លាមនៅចំពោះមុខទីប្រឹក្សាច្បាប់ ឬជំនួយសមស្របផ្សេងទៀតមានក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ត្រូវការពារសិទ្ធិ និងសុវត្ថិភាព និងលើកស្ទួយសុខមាលភាពរាងកាយ និងសតិស្មារតីរបស់អនីតិជន ការដាក់គុកត្រូវប្រើជាមធ្យោបាយចុងក្រោយបង្អស់។[30]

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារនិងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ ដែលនៅក្នុងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធីការឧបត្ថម្ភមានដូចជា៖

១/ ការប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជន នោះឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងមានទំនុកចិត្ត។

២/ ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣/ ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤/ ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥/ ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ហើយក្រៅពីរក្សានៅក្នុងមន្ទីរអប់រំ មានបញ្ញត្តិគ្រប់គ្រងជាច្រើនទៀតដូចជាការថែទាំ កាត់ម្រែតម្រង់ និងការពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឲ្យរស់នៅតាមគ្រួសារកម្មវិធីអប់រំទូទៅ និងអប់រំវិជ្ជាជីវៈព្រមទាំងដំណោះស្រាយផ្សេងទៀតដែលអាចប្រើប្រាស់បានដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំសមស្របជាមួយនឹងជាសុខភាពរបស់ខ្លួន។

[30] សេចក្តីណែនាំលេខ ០១ ក យ សណឧ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៥ របស់ក្រសួងយុត្តធម៌ ស្តីពីគោលការណ៍យុត្តិធម៌អនីតិជន

## ផ្នែកទី ៣ ៖នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរ

ការឃុំខ្លួនមិនត្រូវបានអនុវត្តតាមតែអំណាចរបស់ចៅក្រមស៊ើបសួរនោះទេ ត្រូវឆ្លងកាត់ចៅក្រមជំនុំជម្រះជាដាច់ខាតក្នុងករណីបទឧក្រិដ្ឋ ចំពោះបទមជ្ឈិមការដែលមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ល្មម អាចធ្វើការបញ្ជូននៅជម្រះភ្លាម ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់។ មានន័យថា គឺជាបញ្ជាដល់ជនជាប់ចោទឲ្យចូលខ្លួនទៅតុលាការជាន់ដំបូង ដែលសម្រេចពីរឿងក្តីព្រហ្មទណ្ឌ។

### កថាខណ្ឌ ១-ការសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន

មានតែចៅក្រមស៊ើបសួរប៉ុណ្ណោះទេមានសិទ្ធិ សម្រេចឃុំខ្លួន ឬមិនឃុំខ្លួនតាមគំនិតផ្ទាល់ខ្លួន តាមយោបល់របស់ព្រះរាជអាជ្ញា។ ហេតុសម្រេចលើការឃុំខ្លួនមាននីតិវិធីដូចជា៖ នីតិវិធីមុនសវនាការ និវិធីមុនអង្គសេចក្តី និងនីតិវិធីក្នុងអង្គសេចក្តី។

#### ១.១.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

ក្នុងករណីនេះ តុលាការជាន់ដំបូងទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលខ្លួនភ្លាម។ ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលការបង្ហាញខ្លួននេះត្រូវប្រព្រឹត្តនៅថ្ងៃនោះតែម្តង(មាត្រា៣០៤និង៤៧)។

នៅពេលបង្ហាញខ្លួន តុលាការធ្វើចំណាត់ការដូចតទៅ៖

- ពិនិត្យអត្តសញ្ញាណលើបុគ្គលដែលជាប់ចោទ
- ពិនិត្យមើលរបាយការណ៍សង្ខេបរឿងរបស់ជនជាប់ចោទ
- ប្រាប់ដល់ជនជាប់ចោទ អំពីការចោទប្រកាន់ និងរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងនោះមិនអាចទាន់ជំនុំជម្រះបានត្រូវលើកទៅសវនាការក្រោយទៀត ក្នុងករណីនេះតុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមសាលក្រមដោយមានសំអាងហេតុ និងចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដោយផ្អែកលើដីកាសម្រេចឲ្យឃុំខ្លួន។

ប្រសិនបើតុលាការយល់ឃើញថា នីតិវិធីពុំត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ក្នុងករណីនេះ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួនចំពោះចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តងៗ បើពុំដូច្នេះជនជាប់ចោទត្រូវតែ ដោះលែងឲ្យមានសេរីភាពវិញដោយខ្លួនឯង(មាត្រា៣០៤)។

### ១.២.នីតិវិធីមុនអង្គសេចក្តី

កាលណាតុលាការទទួលបានសំណុំរឿងតាមដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាហើយ ចៅក្រមស៊ើបសួរចាត់នីតិវិធីលើរឿងក្តីនោះ ដោយករណីបទឧក្រិដ្ឋមានភាពស្មុគស្មាញ ឬមានភាពជាក់ស្តែងចំពោះរឿងក្តីណាមួយ ធ្វើឲ្យចៅក្រមចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន តាមសាលក្រមដែលមានទម្រង់ច្បាប់ និងសំអាងហេតុ។ សាលក្រមលើអង្គសេចក្តីនោះត្រូវប្រកាសក្នុងរយៈពេលមិនឲ្យលើសពី២ សប្តាហ៍ គិតពីថ្ងៃនៃការចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខតុលាការ តែប្រសិនបើផុតរយៈពេល២សប្តាហ៍ហើយ ត្រូវដោះលែងឲ្យមានសេរីភាពវិញ។[31]

ការឃុំខ្លួនទៅលើជនសង្ស័យក្រោយពីបង្ហាញខ្លួនលើកដំបូងនេះ ដោយធ្វើការបើកអង្គសវនាការតូចមួយ ដើម្បីសម្រេចឃុំខ្លួន ទោះបីក្នុងករណី ជាក់ស្តែងដែលមានសំអាងហេតុបញ្ជាក់គ្រប់គ្រាន់ឬមិនគ្រប់គ្រាន់លើជនល្មើសក៏ដោយ ព្រោះដើម្បីធានានីតិវិធីក្នុងការដំណើរការរឿងក្តីបានល្អបន្ទាប់ចៅក្រមធ្វើសម្រេចឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការពេញអង្គ ក្រោយពីបញ្ចប់អង្គសវនាការស្តាប់ហេតុផលតូចមួយ ចៅក្រមចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនល្មើស ដោយយោងទៅលើដីកាសម្រេចឲ្យឃុំខ្លួនតាមសំអាងហេតុ ដីកាបង្គាប់ឲ្យចាប់ខ្លួនពីព្រះរាជអាជ្ញា ផ្អែកលើកំណត់ហេតុសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាមូលដ្ឋានឲ្យចៅក្រមចេញដីកាបង្គាប់ឃុំខ្លួនភ្លាមនៅថ្ងៃដែលគេបញ្ជូនជនជាប់ចោទ ឬជនសង្ស័យដល់តុលាការ ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវភ្ជាប់ទៅជាមួយជនត្រូវចោទ ប្រគល់ឲ្យទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬតាមសេនាធិការ ឬឆ្មាំគុករបស់ប្រធានពន្ធនាគារ រក្សាទុកជនសង្ស័យរហូតរង់ចាំអង្គសវនាការក្រោយគឺចៅក្រមស៊ើបសួរបិទសំណុំរឿងបញ្ជូនទៅជម្រះ។[32]

### ១.៣.នីតិវិធីក្នុងអង្គសេចក្តី

ក្រោយពីបានចេញដីកាបង្គាប់ឲ្យឃុំខ្លួនមិនឲ្យលើស ២ខែសប្តាហ៍មកចៅក្រមស៊ើបសួរ និងបន្តនីតិវិធីជជែកវែកញែកសួរដេញដោលរកហេតុផលលើជនជាប់ឃុំ ឬសាក្សី ឬស្វែងរកភស្តុតាងដើម្បីបញ្ជាក់ពីបទល្មើសរបស់ជនរងគ្រោះអំពីសកម្មភាពបទល្មើសដែលចៅក្រមបានឃុំខ្លួន ទៅតាមសាលក្រម បន្ទាប់ពីបានបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខតុលាការ។ ជនជាប់ចោទត្រូវបានបង្ខាំងទុកដោយមានកងកម្លាំងការពាររហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការក្នុងថ្ងៃនោះតែម្តង។

[31] មាត្រា៣០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[32] មាត្រា៤៨.១៣៥,២៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមានបន្ទុកគ្រាប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះ។ ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ អាចជាអំពើទាំងអស់ ឬមួយផ្នែក នៃសំណុំរឿង មានន័យថាអំពើខ្លះធ្វើការលើកលែងចោទប្រកាន់ ហើយអំពើខ្លះទៀតជាកម្មវត្ថុនៃការចោទប្រកាន់។ នៅពេលនោះចៅក្រមស៊ើបសួរអាចរក្សាទុកជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើជនជាប់ចោទនោះនៅឃុំខ្លួនបណ្ដោះអាសន្ន ព្រះរាជអាជ្ញាស្នើសុំឲ្យស៊ើបសួរបន្ថែមក្នុងរយៈពេល១៥ថ្ងៃ និង១ខែក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាអាចបង្វិលសំណុំ រឿងទៅចៅក្រមស៊ើបសួរវិញ ដោយដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផងដែរ។ នៅក្នុងដំណាក់កាលជំនុំជម្រះចៅក្រមជំរះត្រូវបើកនីតិវិធី សួរដេញដោលចំពោះមុខ គប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និងឬមេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការ/អះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះដើម្បីគាំទ្រ ឬប្រឆាំងនឹងការសម្រេចឃុំខ្លួន។នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្នឬមិនឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនបើសម្រេចថាឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នភ្លាម។ ការប្រើប្រាស់នីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលអំណះអំណាងបានគ្រប់ជ្រុងជ្រោយក្នុងការសម្រេចប្រកបដោយតម្លាភាព និងគណនេយ្យភាព។[33]

នៅពេលដែលតុលាការទទួលសំណុំរឿងព្រហ្មទណ្ឌ ពីតំណាងអយ្យការតាមនីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ និងពីចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរតាមដីកាបញ្ជូនរឿងទៅជម្រះ ប្រធានតុលាការចាត់តាំងចៅក្រមអាសនៈណាម្នាក់ដើម្បីទទួលបន្ទុកធ្វើការជំនុំជម្រះ ដែលចៅក្រមអាសនៈនេះអាចជាប្រធានតុលាការខ្លួនឯងផ្ទាល់ ឬចៅក្រមអាសនៈម្នាក់ផ្សេងទៀតក្រៅពីចៅក្រមដែលធ្វើការស៊ើបសួរសាលាដំបូងបើកការជំនុំជម្រះដោយមាន ចៅក្រម១រូប ឬ៣ រូប ដែលមានតំណាងអយ្យការ ១រូប និងក្រឡាបញ្ជី ១រូប។

មុននឹងបើកសវនាការចៅក្រមត្រូវជូនដំណឹង ដល់ភាគីទាំងសងខាង សាក្សី អ្នកតំណាង និងមេធាវីមុនរយៈពេល១៥ថ្ងៃ ដើម្បីឲ្យភាគីដែលពាក់ព័ន្ធ ឬមេធាវី ត្រៀមឯកសារការពារកូនក្តី អំពីកាលបរិច្ឆេទសវនាការ ក្នុងរយៈពេលសាកសួរពិភាក្សាដេញដោលអំពីរឿងក្តី ស្តាប់សេចក្តីសន្និដ្ឋាននានា ដើម្បីស្វែងរកការពិត (មេធាវី ឬសាក្សី) រួចសម្រេចចេញសាលក្រម ។

[33] សន្និសីទស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឆ្នាំ២០១២ ទំព័រ ៥.៦

ប៉ុន្តែរាល់ការបើកសវនាការជំនុំជម្រះធ្វើឡើងតាមកំណត់ហេតុស្តីពី ការចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា និងដោយដីកាបញ្ជូនរឿងរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរទៅតុលាការជំនុំជម្រះផ្ទាល់។ ប្រសិនបើជនជាប់ចោទកំពុងឃុំខ្លួន ចៅក្រមជម្រះ ឬព្រះរាជាអាជ្ញាចេញដីកាកោះបញ្ជាទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យនាំខ្លួនជនជាប់ចោទចេញពីមន្ទីរឃុំឃាំង ហើយប្រសិនបើជនជាប់ចោទមិនស្ថិតនៅក្នុងការឃុំទេ នោះចៅក្រមត្រូវចេញដីកាបង្គាប់ឲ្យនាំចូលខ្លួនតាមការកំណត់សវនាការ បន្ទាប់មកតុលាការបើកអង្គសវនាការស្តាប់ការអះអាងរបស់គូភាគី។

ក្នុងករណីដែលតុលាការទទួលបណ្តឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់ សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។

ព្រះរាជាអាជ្ញាចាត់វិធានការចាំបាច់ដើម្បីឲ្យជនជាប់ចោទ ដែលត្រូវឃុំខ្លួន ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ។ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងការឃុំបណ្តោះអាសន្នត្រូវអស់អានុភាពរយៈពេល ៤ខែ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឲ្យចូលបង្ហាញខ្លួននៅមុខតុលាការទេនោះជនជាប់ចោទត្រូវតែបានដោះលែងឲ្យមានសេរីភាពឡើងវិញដោយឯកឯង។ ជនជាប់ចោទដែលចូលបង្ហាញខ្លួននៅពេលសវនាការក្នុងឋានៈជាជនជាប់ឃុំនោះនៅតែជាប់ឃុំដដែល រហូតដល់មានសាលក្រមលើអង្គសេចក្តីលើកលែងដែលតុលាការបង្គាប់ឲ្យដោះលែងមានសេរីភាពវិញ។[34]

តាមដីកានេះ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅមុខតុលាការ បន្ទាប់ពីប្រគល់ដីកាកោះហៅ៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដី នៃតុលាការជាន់ដំបូង។
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត នៃដែនដីជាតិ។
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួន នោះរយៈពេលមិនត្រូវបានគិតគូរទេ រវាងការប្រគល់ដីកាកោះ និងការចូលបង្ហាញ ខ្លួននៅចំពោះមុខតុលាការ។[35] ហើយក៏អាចលើកអង្គសវនាការពេលក្រោយបានដែរ ប្រសិនបើមិនមានបន្ទុកគ្រប់គ្រាន់ដាក់ទោសលើជនល្មើស ចៅក្រមត្រូវចេញសាលក្រម ឬសាលដីកាលើអង្គសេចក្តីឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែងឲ្យនៅក្រៅឃុំដោយផ្អែកតាមមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

---

[34] មាត្រា៣០៨ ក.៣,២៤៩ ក.៣ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[35] មាត្រា៤៦៦ និង ៤៨៧ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**កថាខណ្ឌ ២-ការប្តឹងឧទ្ធរណ៍លើសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន**

ក្រោយពីសាលាឧទ្ធរណ៍ទទួលបានពាក្យបណ្តឹង ពីតុលាការជាន់ដំបូងក្នុងរឿងក្តី ការឃុំខ្លួនបណ្តោះអាសន្ន សាលដីការបស់សភាស៊ើបសួរត្រូវ ចេញសេចក្តីសម្រេចនៅក្នុងរយះពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ មានន័យថាសភាស៊ើបសួរពិនិត្យសំណុំរឿងក្នុងរយះពេលប្តឹងឧទ្ធរណ៍ បើផុតរយះពេលនេះជនជាប់ចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ឬសម្រេចឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែបើជនជាប់ចោទនៅក្រៅឃុំតាមអំណាចសាលក្រមរបស់សាលាដំបូង សភាស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនតាមសាលដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ហើយដីកានោះត្រូវមានសំអាងហេតុត្រឹមត្រូវ ដោយយោងតាមបទបញ្ញត្តិមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួន។ ហើយសំណុំរឿងត្រូវបង្វិលជាបន្ទាន់ទៅកាន់ចៅក្រមស៊ើបសួរទៅសាលាដំបូងវិញក្រោយពីអនុវត្តដីការួច។

ការឃុំខ្លួនតាមអំណាចសាលក្រម ត្រូវចេញដោយចៅក្រមក្រោយពីបានការបើកសវនាការសម្រេចលើកលែងចោទប្រកាន់ ឬរក្សាទុកជនជាប់ឃុំបណ្តោះអាសន្ន រហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការប្រសិនបើជននោះនៅជាប់ឃុំបណ្តោះអាសន្នទៅតាមកំណត់ច្បាប់។ ការសម្រេចរក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ន លែងមានអានុភាពរយះពេល ៤ខែ ហើយបើក្នុងករណីជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយះពេល ៤ខែ ទេនោះ ជនត្រូវចោទបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។[36]

ចំណែកឯការឃុំខ្លួនតាមសាលដីកាត្រូវចេញដោយសភាស៊ើបសួរបន្ទាប់ពី មានបណ្តឹងឧទ្ធរណ៍ដោយខ្លួនផ្ទាល់ ឬតាមរយះ អ្នកតំណាង ឬអ្នកមានប្រយោជន៍ ឬមេធាវី ឬតំណាងអយ្យការ នៅពេលដែលជនល្មើសត្រូវបានបិទការជំនុំជម្រះអង្គសវនាការនៅសាលាដំបូង ដែលសម្រេចឲ្យជនជាប់ចោទនៅក្រៅឃុំ ឬឃុំខ្លួនបន្ទាប់ពីមានសាលដីកាដោះលែង ឬជនត្រូវចោទដែលបានដោះលែងនៅក្រៅឃុំ ក្រោយពីបានបញ្ចប់សវនាការជំនុំជម្រះនៅសាលាដំបូង ក្នុងករណីមានការប្តឹងឧទ្ធរណ៍ចេញសេចក្តីសម្រេចធ្វើការចាប់ខ្លួនវិញ ដើម្បីធ្វើការកាត់សេចក្តីដោយចេញដីកាដំណោះស្រាយ។[37]

---

[36] មាត្រា២៤៩ កថាខណ្ឌ៣ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[37] មាត្រា២៧៦ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**២.១.ជនដែលមានសិទ្ធិប្តឹងឧទ្ធរណ៍**

បណ្តឹងឧទ្ធរណ៍ធ្វើដោយភាគីណាក៏ដោយគឺតាមគោលការណ៍ត្រូវធ្វើទៅការិយាល័យក្រឡាបញ្ជីដែលចេញសាលក្រម។ អ្នកប្តឹងឧទ្ធរណ៍មិនចាំបាច់ឲ្យដំណឹងនៃការប្តឹងឧទ្ធរណ៍របស់ខ្លួននោះទៅភាគីផ្សេងទៀតទេ។ ក្រឡាបញ្ជីត្រូវចុះបណ្តឹងឧទ្ធរណ៍ ក្នុងបញ្ជីមួយសម្រាប់ចុះពាក្យបណ្តឹង។ ក្រឡាបញ្ជី និងអ្នកប្តឹងត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបណ្តឹងដែលចុះក្នុងបញ្ជី។ អ្នកប្តឹងឧទ្ធរណ៍អាចជំនួសបានដោយអាជ្ញានុការីដែលមានលិខិតប្រគល់សិទ្ធិពិសេស ដោយផ្អែកតាម មាត្រា ១៧៦ ក ១ វ. ខ ៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

ជនដែលមាសិទ្ធិ ប្តឹងឧទ្ធរណ៍មានៈ[38]

- ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ
- អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬមេធាវីរបស់គេ
- ទណ្ឌិត ឬមេធាវីរបស់ទណ្ឌិត
- ដើមបណ្តឹងរដ្ឋប្បវេណី ឬភាគីពាក់ព័ន្ធ
- ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍អាចធ្វើតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតាបាន ប៉ុន្តែសំបុត្រត្រូវឲ្យក្រឡាបញ្ជីតុលាការចេញសាលក្រម មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ពិរុទ្ធជនដែលជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ពិរុទ្ធជននេះត្រូវបំពេញពាក្យប្តឹងឧទ្ធរណ៍ទៅតាមកាលបរិច្ឆេទ ហើយត្រូវចុះហត្ថលេខា។

បន្ទាប់មកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវចុះបញ្ជីលើពាក្យប្តឹងឧទ្ធរណ៍នៅក្នុងសៀវភៅបញ្ជីពិសេស ហើយពិរុទ្ធជនត្រូវចុះហត្ថលេខានៅលើរឹមទំព័រនេះ ហើយប្រធានពន្ធនាគារ ឬមណ្ឌលត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍រយៈពេលខ្លីបំផុតទៅក្រឡាបញ្ជី នៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យបណ្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្តឹងឧទ្ធរណ៍ នៃតុលាការ។

រយៈពេលរបស់ជនដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ធ្វើឡើង១ខែ កាលណាបើសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹង ឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម និងចំពោះសាលក្រមចាត់ទុកចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ គិតពីពេលទទួលដំណឹងអំពីសាលាក្រម ទោះបីជាការឲ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ ប៉ុន្តែការប្តឹងឧទ្ធរណ៍អាចបន្ថែមរយៈពេល៧ថ្ងៃទៀតបាន ដោយសារបណ្តឹងឧប្បត្តិហេតុ

[38] មាត្រា៣៧៥ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដែលផ្តើមគិតផុតរយៈពេលធម្មតា។ ចំណែកឯការប្តឹងឧទ្ធរណ៍ ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្នចំពោះពិរុទ្ធជនវិញ មានរយៈពេល ៥ថ្ងៃ ដោយគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួនមានចែងក្នុងមាត្រា៣៨៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

**២.២.សិទ្ធិប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា**

កាលណាជនជាប់ចោទ ត្រូវសម្រេចដោយចៅក្រមស៊ើបសួរដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន នៅពេលជនត្រូវចោទបានរក្សាទុកនៅក្នុងពន្ធនាគាររហូតផុតបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា មានន័យថានៅពេលជនជាប់ចោទ ត្រូវបានកាត់សេចក្តី ចេញសាលក្រមរួច តែព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនោះដោយមានមូលដ្ឋានសំអាងហេតុ(មាត្រា២៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧)។

ជាគោលការណ៍ការប្តឹងឧទ្ធរណ៍មានរយៈពេល១ខែ ក្រោយពីចេញសាលក្រមស្ថាពពីតុលាការជាន់ដំបូង។ ចំពោះបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញារយៈពេល៥ថ្ងៃ គិតចាប់ពីពេលថ្ងៃជូនដំណឹងប្រកាសសាដីកា។[39] តែក្នុងករណីរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍របស់ព្រះរាជាអាជ្ញាមានរយៈពេល៤៨ម៉ោង ផ្តើមគិតពីពេលដែលតុលាការសម្រេចលើការឃុំខ្លួន។[40] ប្រសិនបើផុតរយៈពេលប្តឹងឧទ្ធរណ៍មិនអាចប្តឹងបានទេ។

**២.៣.អំណាចរបស់សាលាឧទ្ធរណ៍**

ការប្តឹងឧទ្ធរណ៍ ការអនុវត្តសាលាក្រមត្រូវបង្អង់សិន ក្នុងករណីដែលជនជាប់ចោទបានចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារ ក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌនោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ប៉ុន្តែនៅតុលាការជាន់ដំបូងបានសម្រេចឲ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើនឹងរយៈពេល នៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាព មុនពេលផុតកំណត់ នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា ៣៩៨ ។

[39] មាត្រា២៧០ និងមាត្រា៣៨១ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[40] មាត្រា៣៨៤ នៃក្រមនីតិនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សាលាឧទ្ធរណ៍ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនជនជាប់ចោទជាថ្មី ក្នុងករណីជនជាប់ចោទនៅក្រៅឃុំ និងយកមកឃុំខ្លួនបណ្ដោះអាសន្នវិញបាន។ បន្ទាប់មកត្រូវបញ្ជូនជនត្រូវចោទដែលបានចាប់ខ្លួននោះមកមន្ទីរឃុំឃាំងក្នុងរយះពេលដ៏ខ្លីបំផុត ។[41]

សាលាឧទ្ធរណ៍បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទ ក្នុងករណីសម្រេចដាក់ទោសពន្ធនាគារយ៉ាងតិច១ឆ្នាំដោយគ្មានការព្យួរទេ ហើយប្រសិនបើវិធានការសន្តិសុខតម្រូវនោះ សាលាឧទ្ធរណ៍នឹងសម្រេចតាមលក្ខណៈពិសេស មានសំអាងហេតុអាចចេញនៅពេលសវនាការ នូវដីកាបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន ឬឲ្យចាប់ខ្លួនជនដែលអវត្តមាន ឬដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ ដែលអវត្តមាន និងមានអានុភាពអនុវត្តភ្លាម។

ប្រសិនបើជនជាប់ចោទដែលត្រូវបានតុលាការផ្តន្ទាទោសនោះត្រូវចាប់ខ្លួនជនជាប់ចោទនោះ ត្រូវបញ្ជូនខ្លួនក្នុងរយះពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់ព្រះរាជអាជ្ញា ឬរបស់ចៅក្រមពីមន្ទីរឃុំឃាំងខេត្តក្រុងសាមី មកមន្ទីឃុំឃាំងជិតមណ្ឌលឃុំខ្លួនដែលជិតជាងគេបំផុត នៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍។[42] រាល់ការផ្ទេរជនជាប់ឃុំពីពន្ធធនការមួយទៅពន្ធធនាគារមួយត្រូវមានការអនុញ្ញាតិពីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងរយះពេល ៣ ថ្ងៃយ៉ាងយូរ ទៅព្រះរាជអាជ្ញា ដែលមានសិទ្ធិដែនដីបញ្ជូន និងសិទ្ធិដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាកំពុងចាត់ការរឿងក្ដី ទៅតាមនីតិវិធីច្បាប់ ហើយការផ្ទេរនេះត្រូវភ្ជាប់នូវជាមួយទ្រព្យសម្បត្ត ដែលមានក្នុងសំណុំរឿង និងឯកសារពាក់ព័ន្ធនានារបស់ជនជាប់ឃុំទៅឲ្យមន្ទីរឃុំខ្លួន ឬពន្ធនាគារមានសមត្ថកិច្ច(មាត្រា៦២ នៃច្បាប់ពន្ធនាគារ) ។

សាលាឧទ្ធរណ៍នៅពេលទទួលការជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍ដោយជនជាប់ចោទ ពុំអាចដាក់បន្ថែមទំងន់ទោសលើជនត្រូវចោទឡើយប៉ុន្តែអាចបន្ធូរបន្ថយទំងន់ទោសបាន។

### ២.៤.ការឃុំខ្លួនជនជាប់ចោទក្នុងពេលជាប់បណ្ដឹងឧទ្ធរណ៍

នៅពេលដែលជនជាប់ចោទចូលខ្លួនជាលើកដំបូង ប្រសិនបើចៅក្រមស៊ើបសួរសម្រេចដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ហើយព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនេះ នាំឲ្យជនជាប់ចោទស្ថិតនៅក្នុងឃុំដដែល។[42]

[41] មាត្រា៤០៧ កថាខណ្ឌ ៨ និងមាត្រា២៤៣ នៃក្រមននីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[42] សៀវភៅក្បួននីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១៤៥-១៤៦

ប្រសិនបើភាគីផ្សេងទៀត ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចដាក់ឲ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរ នោះជនជាប់ចោទត្រូវស្ថិតនៅក្រៅឃុំដដែលដោយរង់ចាំលទ្ធផលសាលាឧទ្ធរណ៍។

កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះ សាលាឧទ្ធរណ៍ត្រូវបង្គាប់ឲ្យដោះលែងជនជាប់ចោទនោះភ្លាម។ [43]កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសម្រេចអនុញ្ញាតឲ្យជនជាប់ចោទនៅក្រៅឃុំ របស់ចៅក្រម ស៊ើបសួរសាលាឧទ្ធរណ៍ត្រូវបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ មកឃុំជាបណ្តោះអាសន្ន។ សាលាឧទ្ធរណ៍ចេញដីកាចាប់ខ្លួន ដោយផ្អែកតាម មាត្រា២០៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

ប្រសិនបើព្រះរាជអាជ្ញា ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ហើយជនជាប់ចោទ ស្ថិតក្នុងការឃុំជាប់ណ្តោះអាសន្ន នោះជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនដដែល។ ប្រសិនបើគ្មានការប្តឹងឧទ្ធរណ៍ព្រះរាជអាជ្ញានោះជនជាប់ចោទត្រូវទទួលការដោះលែង។[44] ជនជាប់ចោទជាប់ឃុំឃាំង ត្រូវនៅជាប់ឃុំឃាំងដដែល។

ប្រសិនបើសាលាឧទ្ធរណ៍បដិសេធលើដីកាលើកលែងចោទប្រកាន់ ប្រធានសាលាឧទ្ធរណ៍អាចចេញដីការកចាប់ខ្លួនជនជាប់ចោទជាថ្មី ដោយយកមកឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទជាថ្មីបាន កាលណាជនជាប់ចោទនៅក្រៅឃុំ។[45] ប៉ុន្តែបើតុលាការសម្រេចផ្តន្ទាទោស ហើយជនជប់ចោទកំពុងនៅជាប់ប្តឹងឧទ្ធរណ៍ ជនជាប់ចោទនោះត្រូវតែនៅជាប់ឃុំខ្លួនជាបណ្តោះអាសន្នដដែល។ ម្យ៉ាងទៀតបើជនជាប់ចោទនៅក្រៅឃុំការប្តឹងឧទ្ធរណ៍ត្រូវផ្អាកការអនុវត្តសាលក្រមសិន មានន័យថា ជនជាប់ចោទត្រូវនៅក្រៅឃុំដដែល លើកលែងករណីដែលតុលាការសម្រេចឲ្យចខ្លួន ជនជាប់ចោទត្រូវដោះលែង បើគ្មានបណ្តឹងឧទ្ធរណ៍។

នៅពេលដែលចៅក្រមសម្រេចដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន សេចក្តីសម្រេចនោះមានប្រសិទ្ធភាពអនុវត្តភ្លាមទោះជាមានការប្តឹងតវ៉ាក៏ដោយលើកលែងតែមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។

[43] មាត្រា៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[44] លើកលែងតែមានប្តឹងតវ៉ាពីព្រះរាជអាជ្ញាលើដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរនោះ

[45] មាត្រា៩១ នៃច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីក្រមព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០១

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយទៅលើប្រធានបទស្តីពី "**ការឃាត់ខ្លួន និងការឃុំខ្លួន**" យើងឃើញមានវិធានផ្សេងៗ ដែលត្រូវបានប្រើប្រាស់សំរាប់ទប់ស្កាត់ ឬរារាំងបទល្មើសគ្រប់ប្រភេទជាពិសេសបទល្មើសក្នុងរឿងព្រហ្មទណ្ឌកុំឲ្យកើតមានឡើងហើយវាគឺជាសិទ្ធិអំណាចតាមផ្លូវតុលាការរបស់ច្បាប់តបទៅនឹងបុគ្គលណាម្នាក់ ឬជនណាមួយ តាំងពីការចាប់ផ្តើម ក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរហូតដល់ដាក់ផ្តន្ទាទោសជននោះដោយពុំអាចរំលងហួសពីសមត្ថកិច្ចរបស់ស្ថាប័នតុលាការបានឡើយ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺមិនអាចគេចផុតពីនីតិវិធីនៃការឃាត់ខ្លួន និងការឃុំខ្លួននេះបានទេ ពោលគឺនីតិវិធីទាំងពីរនេះជានីតិវិធីសំខាន់ក្នុងការស្វែងរកយុត្តិធម៌ដ៏ត្រឹមត្រូវ។ ដូច្នេះរាល់បទល្មើសកើតមានឡើង មន្ត្រីនគរបាលយុត្តិធម៌ឬអាជ្ញាធរមានសមត្ថកិច្ចដែលច្បាប់ផ្តល់សិទ្ធិអំណាចឲ្យក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្នុងការបង្ក្រាបបទល្មើសឃាត់ខ្លួន ចាប់ខ្លួន និងឃុំខ្លួន ជនល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ ហើយចាត់វិធានការស៊ើបសួរ តាមរយះបញ្ជូនរឿងឲ្យទៅចៅក្រមស៊ើបសួរដោយដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីស្វែងរកការពិត (ដាក់បន្ទុក ឬដោះបន្ទុក) បន្ទាប់មកចៅក្រមស៊ើបសួរបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញាវិញ ដើម្បីឲ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងទៅប្រធានតុលាការ ដើម្បីចាត់តាំងចៅក្រមជំនុំជំរះ និងឈានរហូតដល់ការចេញសាលក្រម ដើម្បីកំណត់ ទោសទណ្ឌណាមួយ (ចៅក្រមមស៊ើបសួរមិនអាចក្លាយជាចៅក្រមជំនុំជម្រះបានទេ)។ កត្តាទាំងនេះសបញ្ជាក់ឲ្យឃើញថាការអនុវត្តច្បាប់រវាងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិ នៅក្នុងស្ថាប័នតុលាការ។

យើងដឹងហើយថា ប្រសិនបើគ្មានច្បាប់ចាប់បង្ខំឃុំខ្លួនជនល្មើសនោះទេ វាហាក់បីដូចជាអយុត្តិធម៌ក្នុងការប្រព្រឹត្តបទល្មើសព្រោះជនល្មើសមិនខ្លាចនៅតែប្រព្រឹត្តតទៅទៀត ធ្វើឲ្យមានអស្ថិរភាព ដល់សណ្តាប់ធ្នាប់សាធារណៈ ធ្វើឲ្យច្បាប់ទំលាប់បាត់បង់ភាពស័កសិទ្ធិ ដែលបានចែងទុកជាធរមាន ដែលប្រទេសយើងប្រកាន់យកនូវលទ្ធិប្រជាធិបតេយ្យយកគោរពច្បាប់ជាធំ។ ដូចនេះសង្គមយើងបច្ចុប្បន្នកើតមានបទល្មើសគ្រប់ប្រភេទ គ្រប់រូបភាពស្ទើរតែរាល់ថ្ងៃហើយការទប់ស្កាត់ ឬការរារាំងបទល្មើស ពុំទាន់គ្រប់គ្រាន់ក្នុងការទប់ស្កាត់បទល្មើសនៅឡើយទេទាល់តែប្រជាពលរដ្ឋគាត់យល់ដឹងពីច្បាប់ហើយគាត់គោរពច្បាប់ និងប្រតិបត្តិនោះទើបធ្វើឲ្យមានការកាត់បន្ថយនូវបទល្មើស។

ដើម្បីចូលរួម ក្នុងការកសាងសង្គមជាតិឲ្យបានរីកចម្រើនឆាប់រហ័ស ប្រជាពលរដ្ឋគ្រប់រូបត្រូវមានស្មារតីភ្ញាក់រលឹកខ្ពស់ក្នុងការចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ហើយលើកទឹកចិត្តដល់ស្នាដៃក្នុងការទប់ស្កាត់ ការរារាំងបទល្មើសក្នុងសង្គម ចាត់វិធានការតឹងរឹង ចំពោះអ្នករំលោភបំពានច្បាប់ និងធ្វើយ៉ាង

ណាឲ្យប្រជាពលមានជំនឿជឿជាក់លើស្ថាប័នអនុវត្តច្បាប់ និងលុបបំបាត់អំពើពុករលួយក្នុងសង្គម គ្រប់ជាន់ថ្នាក់ និងគ្រប់រូបភាព។ យើងខ្ញុំសង្ឃឹមថានៅពេលអនាគត ខាងមុខនេះ ដែលប្រទេសយើងកំពុងតែធ្វើច្បាប់ថ្មីៗជាច្រើនទៀតដែលមានចន្លោះប្រហោងធ្វើសង្គមប៉ះពាល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាពិសេសនោះគឺការដាក់ចេញនៅការអនុវត្តច្បាប់ថ្មីពាក់ព័ន្ធនឹងការទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ជាដើម បានធ្វើឲ្យប្រទេសកម្ពុជាយើងទទួលបានជោគជ័យក្នុងការទប់ស្កាត់បានល្អ នឹងមានមុខមាត់ក្នុងពិភពលោកកត្តាទាំងនេះហើយបានប្រទេសយើងមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សឆ្ពោះទៅរកការរីកចំរើនលើគ្រប់វិស័យ និងឈានទៅរកនីតិរដ្ឋ និងប្រែក្លាយជាប្រទេសកំពុងអភិវឌ្ឍន៍ ទៅជាប្រទេសអភិវឌ្ឍនៅពេលខាងមុខយ៉ាងឆាប់រហ័ស។

# អនុសាសន៍

ដើម្បីឲ្យអត្ថបទសារណាស្តីពីការឃាត់ខ្លួន និងការឃុំខ្លួននេះ ស្របទៅតាមការអនុវត្តជាក់ស្តែង និងប្រកបដោយមានខ្លឹមសារជាមួយគតិច្បាប់នោះ ដាច់ខាតត្រូវអនុវត្តតាមនីតិវិធីច្បាប់ឲ្យបានត្រឹមត្រូវ ដោយអនុវត្តភ្ជាប់ជាមួយជានិច្ចនូវវិធានការណ៍ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ រាល់ការឃាត់ខ្លួននិងការឃុំខ្លួនត្រូវធ្វើឡើងដោយអំណាចតុលាការ ឬភ្នាក់ងារក្រោមឱវាទ ក្នុងការអនុវត្តច្បាប់ដែលត្រូវបានប្រើប្រាស់អំណាចក្នុងទំហំច្បាប់កំណត់ស្តីពីការឃាត់ខ្លួននិងការឃុំខ្លួន ចំពោះបុគ្គលណាមួយនោះ ត្រូវប្រាប់ពីមូលហេតុច្បាស់លាស់ ប្រាប់នូវសិទ្ធិមួយចំនួនដែលជននោះមាន មានបញ្ជាក់ភស្តុងដាក់បន្ទុកគ្រប់គ្រាន់ ចែងក្នុងច្បាប់ជាធរមាន គោរពតាមច្បាប់ស្តីពីសិទ្ធិមនុស្ស ឬកតិកាសញ្ញាអនុសញ្ញាអន្តរជាតិពាក់ព័ន្ធផ្សេងៗព្រោះថាការឃាត់ខ្លួន និងការឃុំខ្លួន គឺត្រូវដកហូតសិទ្ធិសេរីភាពមនុស្ស ធ្វើការបំបិទសិទ្ធិមិនឲ្យធ្វើអ្វី តាមតែអំពើចិត្តដែលវាធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គលដែលបានឃាត់ខ្លួន ឬឃុំខ្លួន ដោយខុសច្បាប់ហើយធ្វើឲ្យបុគ្គលនោះទទួលហានីភ័យជាច្រើនយ៉ាងពីមជ្ឈដ្ឋានជុំវិញសង្គម មានការអាប់អួរ ក្នុងជីវិតរស់នៅរបស់គេជាក់ជាមិនខានឡើយ។ ម្យ៉ាងវិញទៀតការឃាត់ខ្លួន និងការឃុំខ្លួន អនុវត្តដោយតុលាការ និងស្ថាប័នអនុវត្តច្បាប់ ដើម្បីការពារជនរងគ្រោះដែលត្រូវគេបំពានសិទ្ធិ ព្រមទាំងផ្តន្ទាទោសជនល្មើសផងដែរ។ លើសពីនេះទៅទៀតការឃាត់ខ្លួននិងការឃុំខ្លួន គឺជានីតិវិធីរបស់តុលាការ ដែលមានតួនាទី និងភារកិច្ចបំរើឲ្យប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងលំហូរប្រព័ន្ធយុត្តិធម៌កម្ពុជា ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព ស្ថេរភាពដល់ជនរងគ្រោះ និងជនល្មើសគ្រប់ៗរូប ដោយសារថាជនល្មើសមានសិទ្ធិនិងមានអ្វីៗដូចគ្នានឹងជនរងគ្រោះទាំងអស់ដែរ ប៉ុន្តែខុសគ្នាត្រង់ជនល្មើសត្រូវបានបំបិទសេរីភាពក្នុងមួយរយៈពេលដែលតុលាការអនុវត្តទោសទៅលើជនល្មើសដែលធ្វើសកម្មភាពខុសច្បាប់ហួសទំហំ នៃសិទ្ធិ ប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

# ឯកសារយោង

**១.វចនានុក្រម និងសទ្ទានុក្រម**

- វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត របស់ពុទ្ធសាសនបណ្ឌិតឆ្នាំ១៩៦៧
- សទ្ទានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
- សទ្ទានុក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

**២.អត្ថបទមេរៀន**

- នីតិវិធីព្រហ្មទណ្ឌទូទៅ លោកសុខរឿន ឆ្នាំ២០១០-២០១២
- សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី៣០/០៨/១៩៩៩ និងមួយទៀតចុះថ្ងៃទី០១/០២/២០០៦
- សៀវភៅស្តីពីទោសព្រហ្មទណ្ឌសាស្រ្តាចារ្យ កៅ សីហា ឆ្នាំ២០១៣
- មេរៀននីតិវិធីព្រហ្មទណ្ឌទូទៅ លោក រុន ពន្ធណារិទ្ធិ ឆ្នាំ ២០១២-២០១៣
- សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ឆ្នា២០១២-២០១៤
- សេចក្តីពន្យល់មាត្រាទាំងឡាយនសក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងការឃុំខ្លួន
- គោលការណ៍ និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ២០១៣
- សិក្ខាសាលា ស្តីពីការលើកកម្ពស់កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារ និងកិច្ចការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌ នៅខែមិថុនា ឆ្នាំ២០១២

**៣.សៀវភៅច្បាប់**

- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ និងវិសោធនកម្ម នៃរដ្ឋធម្មនុញ្ញបន្តបន្ទាប់។
- ច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩២ និងវិសោធនកម្មនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងវិសោធនកម្មនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- ក្រមព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌអន្តរកាល ថ្ងៃទី១០ កញ្ញា ឆ្នាំ១៩៩២
- ច្បាប់ពន្ធនាគារ ឆ្នាំ២០១១
- បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រង់អ្នកទោស ឆ្នាំ១៩៩៥

**៤.សន្ធិសញ្ញា អនុសញ្ញាច្បាប់អន្តរជាតិ**

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
- វិធានបទដ្ឋានជាអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីវិធានការដាក់ឲ្យនៅក្រៅឃុំ
- វិធានរបស់អង្គការសហប្រជាជាតិ សម្រាប់ការពារ អនីតិជនត្រូវបានដកហូតសេរីភាព អនុម័តដោយសេចក្តីសម្រេចលេខៈ៤៥/១១៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ នៃមហាសន្និបាត

## ៥.ប្រកាស សរាចរ និងសេចក្តីណែនាំប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ លេខ២១៧ ប្រ.ក

- សារាចរ ស្តីពីការគ្រប់គ្រង់ និងត្រួតពិនិត្យពន្ធនាគារស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជាលេខ០០១
- ការណែនាំពីការងនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លេខ១២០ ក.យ.រប/១៤
- សេចក្តីណែនាំអំពីគោលការយុត្តិធម៌អនីតិជន លេខ០១ ក.យ.សណន/០៥

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌទួលគោក
[illegible]

**កំណត់ហេតុ**

ឆ្នាំពីរពាន់[illegible] ខែ [illegible] ថ្ងៃទី [illegible] វេលាម៉ោង [illegible]

បានទទួលការអនុញ្ញាតពីលោក ៖ [illegible]

សមាសភាពចូលរួមមាន ៖

១- លោក [illegible]
២- លោក [illegible]
៣- លោក [illegible]
៤- លោក
៥- លោក [illegible]
៦- លោក [illegible]

នៅ[illegible] បានធ្វើកំណត់ហេតុ [illegible]
ជូនទៅឈ្មោះ [redacted] ភេទ [illegible] អាយុ [illegible] ឆ្នាំ ជនជាតិ [illegible] សញ្ជាតិ [illegible]
ផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ក្រុមទី [redacted]/សង្កាត់ [redacted] ខណ្ឌ ទួលគោក រាជធានី ភ្នំពេញ។

នៅពេលចុះដល់ទីតាំងក្រុមការងារបាន [illegible]

[illegible]

កំណត់ហេតុបានបញ្ចប់នៅវេលាម៉ោង [illegible] ថ្ងៃខែឆ្នាំដដែល ហើយបានអានជូនសាមីខ្លួន ស្តាប់ថាពិតជាត្រឹមត្រូវទើបចុះហត្ថលេខា ផ្តិតមេដៃស្តាំទុកជាភស្តុតាងនៅខាងក្រោម ។

**មេដៃស្តាំសាមីខ្លួន** [redacted]

**ក្រុមធ្វើកំណត់ហេតុ**

[illegible]

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ***********

................................

********** **ដីកាទទួលយកមេធាវីឱ្យការពារក្ដី**

លេខៈ ................. **********

យើង............................................ តំណាងអយ្យការអមតុលាការខេត្ត-ក្រុង....................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ......................... ចុះថ្ងៃទី.............. ខែ............ ឆ្នាំ........................

បានឃើញនីតិវិធីចោទប្រកាន់លើឈ្មោះ.......................................... ភេទ .......... អាយុ ...........ឆ្នាំ ជាតិ...................... របររកស៊ី .......................... កើតនៅភូមិ ......................... ឃុំ-សង្កាត់...................... .... ស្រុក-ខណ្ឌ............................ខេត្ត-ក្រុង......................................ទីលំនៅបច្ចុប្បន្ននៅភូមិ................................. ឃុំ-សង្កាត់............................ស្រុក-ខណ្ឌ ..........................ខេត្ត-ក្រុង ......................... ទោសពីមុន ..........។ ឪពុកឈ្មោះ ...........................................................ម្ដាយឈ្មោះ................................................................... ប្រពន្ធឬប្ដីឈ្មោះ ...................................................មានកូន ...........នាក់ ឬនៅលីវ........................................។ ពីបទ........................................................................................................................................... ប្រព្រឹត្តនៅភូមិ ............................. ឃុំ-សង្កាត់ ................................. ស្រុក-ខណ្ឌ........................................ ខេត្ត-ក្រុង ......................................................កាលពីថ្ងៃទី................ ខែ.............. ឆ្នាំ ...............។ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ................ នៃច្បាប់............................................................................ ។

បានឃើញពាក្យសុំចុះថ្ងៃទី...................ខែ.....................ឆ្នាំ.............. របស់ឈ្មោះ................................ ជា ............................................. ដោយមានការយល់ព្រមពីលោក ................................................. ជាមេធាវី ចុះថ្ងៃទី................ខែ.....................ឆ្នាំ.................. ។

បានឃើញពាក្យសុំចុះថ្ងៃទី..............ខែ...............ឆ្នាំ.............. របស់ ....................................ជាមេធាវី

**ហេតុដូច្នេះសម្រេច**

១. ទទួលយកលោក .............................................. ជាមេធាវីការពារក្ដីឱ្យឈ្មោះ.................................. តាមច្បាប់តទៅ ។

២. មេធាវីមានសិទ្ធិចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិច្បាប់ ។

ធ្វើនៅ......................... ថ្ងៃទី.......... ខែ..................... ឆ្នាំ................

**ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌ២៧៨
ចុះថ្ងៃទី ១៣-០៣-២០១៩

# ដីកាកោះ

**យើង សៀង សុខ តំណាងអយ្យការអមសាលាដំបូង ខេត្តព្រះសីហនុ**

| | |
|---|---|
| អញ្ជើញឈ្មោះ : | [redacted] ([redacted]) |
| ទីលំនៅសព្វថ្ងៃ: | [redacted] ខេត្តព្រះសីហនុ |
| ឲ្យចូលទៅកាន់: | អយ្យការអមសាលាដំបូង ខេត្តព្រះសីហនុ |
| នៅថ្ងៃទី: | ២៩ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ៩ និង ០០ នាទី។ |
| ដើម្បី: | ឆ្លើយបំភ្លឺ។ |
| ពីដំណើររឿង: | ប្តឹងឈ្មោះ [redacted] ពីបទ: ធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។ |

សាមីខ្លួនត្រូវអញ្ជើញទៅទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ ចន្ទ ៥រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅខេត្តព្រះសីហនុ,ថ្ងៃទី ២៥ ខែ ០៣ ឆ្នាំ២០១៩

**ព្រះរាជអាជ្ញា**

សៀង សុខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

លេខ ១៩២ អ.យ.ជ

## ដីកាបញ្ជាឲ្យចូលខ្លួន[1]

យើង **ស៊ិត វណ្ណៈ** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- **បានឃើញ** មាត្រា ៣៧[2] មាត្រា ៩៤[3] និងមាត្រា ១១៤[4] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។
- **បានឃើញ**សំណុំរឿងព្រហ្មទណ្ឌលេខ ២៤៧៦ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

### បញ្ជា

-នាមត្រកូល-នាមខ្លួន [redacted] ភេទ ប្រុស អាយុ ៤២ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ២ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

ឲ្យចូលបង្ហាញខ្លួននៅ **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ឲ្យបានមុនថ្ងៃទី ១៩ ខែ សីហា ឆ្នាំ **២០២១** នៅរៀងរាល់ម៉ោងធ្វើការដើម្បីសាកសួរលើបណ្តឹងព្រហ្មទណ្ឌពីបទៈ **ឆបោក និងរំលោភលើទំនុកចិត្ត** តាមបណ្តឹងរបស់ឈ្មោះ ប្រាក់ ប្រាកដ ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ទុតិយាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២១

**ជ. ព្រះរាជអាជ្ញា**

**ស៊ិត-វណ្ណៈ**
**ព្រះរាជអាជ្ញារង**

---

[1] ដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន
[2] អំណាចរបស់ព្រះរាជអាជ្ញា
[3]ករណីស៊ើបអង្កេតជាក់ស្តែង
[4] ករណីស៊ើបអង្កេតបឋម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លាដំបូងខេត្តបាត់ដំបង

លេខ: ៤២២៥ ត.ព្រ

# ដីកាបង្គាប់ឲ្យចូលខ្លួន

**យើង រ័ត្ន ស៊ីថា ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបាត់ដំបង**

បានឃើញ មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦៦ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ៥១៥ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ដែលទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១០៧៥ ដស.បស ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ដែលបើកការប្រឆាំងនឹងជនត្រូវចោទឈ្មោះ [redacted] ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ពីបទ: ឆបោក ប្រព្រឹត្តនៅចំណុចភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីដើមឆ្នាំ២០១៥ រហូតដល់ចុងឆ្នាំ២០១៦ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**<u>បង្គាប់មក</u>**

ឈ្មោះ [redacted] ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកស៊ីលក់អចលនវត្ថុ កាន់អត្តសញ្ញាណប័ណ្ណខ្មែរ [redacted] ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ[redacted] ក្រុមទី៤២ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

ឲ្យចូលមកកាន់សាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ជាកំណត់ ។

ដើម្បី៖ សាកសួរពីដំណើររឿងពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

សាមីខ្លួនត្រូវចូលមកបង្ហាញខ្លួនឲ្យទាន់ពេលវេលាតាមការកំណត់ខាងលើ និងយកលិខិតផ្សេងៗដែលទាក់ទងនឹងសំណុំរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើទេ <u>*យើងនឹងចេញបញ្ជាឲ្យកម្លាំងសាធារណៈ បង្ខំសាមីខ្លួនឲ្យចូលមកបង្ហាញខ្លួន គឺយើងចេញដីកាបង្គាប់ឲ្យនាំខ្លួន*</u> ។

បាត់ដំបង, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧

**ចៅក្រមស៊ើបសួរ**

រ័ត្ន_ស៊ីថា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជី ដាក់ បញ្ជា
បន្ទប់ "ព១" ជាន់ទី៤

## ដីកាបង្គាប់ឲ្យនាំខ្លួន

លេខ: 1300 "ព១" ដ.ច.ខ

យើង ទ៊ាន់ រ៉ែសនថិសុទ្ធ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ១៨៩ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦៧០ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៣៥៨៥ អ.យ.ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ដែលចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ[redacted] និង[redacted] ផ្លូវជាតិលេខ៥ ភូមិកណ្ដោកខាងជើង សង្កាត់កណ្ដោក ខណ្ឌកំបូល រាជធានីភ្នំពេញ ។

-ពីបទ: **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ ដីកាបង្គាប់ឱ្យចូលខ្លួន (លើកទី១) លេខ: ៤៧០ "ព១" ព្រ.ទ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបង្គាប់ឱ្យចូលខ្លួន (លើកទី២) លេខ: ៥២៥ "ព១" ព្រ.ទ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

### យល់ឃើញថា:

-តាមដីកាបង្គាប់ឱ្យចូលខ្លួន (លើកទី១) លេខ: ៤៧០ "ព១" ព្រ.ទ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ។

-តាមដីកាបង្គាប់ឱ្យចូលខ្លួន (លើកទី២) លេខ: ៥២៥ "ព១" ព្រ.ទ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ជនត្រូវចោទពុំបានមកបង្ហាញខ្លួននៅចំពោះមុខតុលាការទាល់តែសោះ ហេតុដូច្នេះតុលាការគប្បីនាំខ្លួនជនត្រូវចោទឈ្មោះ **គោ សុផានិត** មកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

-ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញគប្បីសម្រេចនាំខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ សញ្ជាតិខ្មែរ មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីបំភ្លឺការពិត ។

### ហេតុដូច្នេះសម្រេច

១-ឱ្យនាំខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ សញ្ជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២-បង្គាប់មកកងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

ថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

ទ៊ាន់ រ៉ែសនថិសុទ្ធ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១៨៤... "ធ" ចបង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ចាម ដនវិច្ឆិកា

បន្ទប់ ៦ ជាន់ទី៥

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង **សេង លាង** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៨៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៦៩ អ.យ.ដ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៦។

បានឃើញ សំណុំរឿងស៊ើបសួរលេខ ២០៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦។

បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ ..៥២... "ធ" ព្រ.ទ ចុះថ្ងៃទី.០៦.ខែមីនា ឆ្នាំ ២០១៦។

*ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងស្រុងហើយ យល់ឃើញថា ៖*

-តាមត្រកូល [redacted] ហៅ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត ភូមិព្រែកប្រាយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ភូមិព្រែកប្រាយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" នៅរស់ ជាតិជន ទោសពីមុខគ្មាន។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ចំណុចមុខវត្តចំប៉ា ភូមិក្បាលកោះ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-យល់ឃើញថា: តំណាងអយ្យការបានផ្ដល់យោបល់ ឯកភាពលើការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ។

-យល់ឃើញថា: គប្បីតុលាការសម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ តាមនីតិវិធីច្បាប់ ។

## ហេតុដូច្នេះសម្រេច

១/បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ លន់ ផល្លា ហៅ ឡាយ ផល្លា ភេទប្រុស អាយុ ៣១ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើនេះ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត កំពង់ចាម

មន្ទីរស៊ើបសួរ ៥

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៣២/២៣.០៩.១៧

ស៊ើបសួរលេខ:..........................

លេខ៥៥៨

# ដីកាបង្គាប់ឱ្យឃុំខ្លួន

(មាត្រា ២១៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

**យើង ប៉ុក សុខណ្ណាមុនី ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត កំពង់ចាម**

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៨០៨ អ.យ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តកំពង់ចាម ។

បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹង ៖

-ឈ្មោះ: [redacted] ហៅសិម [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ មុខរបរ: កសិករ សញ្ជាតិខ្មែរ កើតថ្ងៃទី ...... ខែ...... ឆ្នាំ........ ទីកន្លែងកំណើតនៅភូមិត្បៀងព្រៃក្នុង ឃុំត្បៀងព្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងមានអាសយដ្ឋានបច្ចុប្បន្ននៅត្បៀងព្រៃក្នុង ឃុំត្បៀងព្រៃ ស្រុកកំពង់សៀម ខេត្ត កំពង់ចាម នីតិជន ប្រពន្ធឈ្មោះ[redacted] មានកូន០៥នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ..គ្មាន.... ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ: ហិង្សាដោយចេតនា ,គំរាមកំហែង និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅភូមិត្បៀងព្រៃក្នុង ឃុំត្បៀងព្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២១៧,មាត្រា២៣១ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

យោងលើមាត្រា ២០៣, មាត្រា ២០៤, មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យោងលើដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៣០៨ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ។

## ហេតុដូច្នេះសម្រេច

-បញ្ជាអោយភ្នាក់ងារសមត្ថកិច្ចនៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះខាងលើ ទៅពន្ធនាគារខេត្តកំពង់ចាម ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

-បង្គាប់មកប្រធានពន្ធនាគារ ខេត្តកំពង់ចាម ទទួល និងឃុំខ្លួនជននេះ លុះត្រាតែមានបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

ធ្វើនៅកំពង់ចាម ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧

**ចៅក្រមស៊ើបសួរ**

ប៉ុក សុខណ្ណាមុនី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តប៉ៃលិន**
បន្ទប់ស៊ើបសួរ "ង"
-សំណុំរឿងលេខ:៦១/២៩-៣-២១
-លេខស៊ើបសួរ:៤៣/២៩-៣-២១
-លេខ:...១៦៧....../២០២១

## ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង **ហោ តារាឡុង** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន
អមដោយលោក **ឃួន សំបូរ** ក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៦១ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២១ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៩ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២១ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរលេខ: ៤៣ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១ ។

បានឃើញ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តប៉ៃលិន ។

ក្រោយពីបាន សាកសួរចម្លើយជនត្រូវចោទ ចប់សព្វគ្រប់និងពិនិត្យពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ ។

### ហេតុដូច្នេះសម្រេច

-មិនឃុំខ្លួនឈ្មោះ [redacted] ហៅ អូន ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិកូនខ្លុង ឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិអូរប្រើស សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted]) មានកូន ០៣ នាក់ នីតិជន ទោសពីមុនគ្មាន។

ចោទប្រកាន់ពីបទ ធ្វើឱ្យខូចខាតដោយចេតនា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូរប្រើស សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២១ អំពើដែលមានចែងឱ្យផ្ដន្ទាទោសដោយមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

លេខ:.........................ម.យ
បានទទួលដំណឹង

ថ្ងៃ ចន្ទ ១ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៤
ប៉ៃលិន,ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២១

ថ្ងៃ...............ខែ............ឆ្នាំឆ្លូវ ទោស័ក ព.ស២៥៦៤
ថ្ងៃទី...........ខែ.............ឆ្នាំ២០២១
**ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជី**
ឃួន សំបូរ

**ចៅក្រមស៊ើបសួរ**
ហោ តារាឡុង



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ខ៩"
លេខ ១១១៥ ព្រ.១

**លិខិតជូនដំណឹង**
**ស្ដីពីការលើកលែងចោទប្រកាន់**

យើង **សេង រិទ្ធី** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ។

បានឃើញ ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៦០៤៩ (ខ៩) ជ.ជ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ។

**ជ្រាបមក**

ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦អា ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាជនត្រូវចោទ។

តាមសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ដែលមានជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ត្រូវចោទពីបទ **ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍** ប្រព្រឹត្តនៅខណ្ឌ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៩៤ និងមាត្រា **៤៩៥** នៃក្រមព្រហ្មទណ្ឌ នោះយើងបានស៊ើបសួរចប់សព្វគ្រប់តាមនីតិវិធីហើយ ។

យើងបានសម្រេច **លើកលែងចោទប្រកាន់** លើជនត្រូវចោទឈ្មោះ[redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ តាមដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៦០៤៩ (ខ៩) ជ.ជ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ សូមជ្រាបជាដំណឹង ។

ថ្ងៃសុក្រ ០៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

**សេង រិទ្ធី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តឧត្តរមានជ័យ

លេខ: ០២៩ /២១

# លិខិតជូនដំណឹង

យើង **មឿន ស្មី** ក្រឡាបញ្ជី នៃអយ្យការអម សាលាដំបូងខេត្តឧត្តរមានជ័យ។

ជម្រាបមកឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៨៥ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ជាដើមបណ្តឹងឱ្យបានជ្រាបថា៖

តាមរបាយការណ៍លេខ:០២ ផសណ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ផ្នែកសណ្តាប់ធ្នាប់សាធារណៈ អធិការដ្ឋាននគរបាលក្រុងសំរោង នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ បានបញ្ជូនរបាយការណ៍មកតំណាងអយ្យការពាក់ព័ន្ធនឹងករណី គ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ:០៥៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នោះ តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការតាមដីកាសម្រេចលេខ: ០២៨ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ រួចហើយ។

សាមីខ្លួនមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ចាប់ពីថ្ងៃបានទទួលដំណឹងពីដីកានេះ។

ថ្ងៃអង្គារ ០១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅឧត្តរមានជ័យ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

មឿន ស្មី

---

យើង [illegible] ជា [illegible] បានប្រគល់

លិខិតជូនដំណឹងនេះដល់ឈ្មោះ [illegible] ទីលំនៅសព្វថ្ងៃនៅភូមិ [illegible]

ឃុំ-សង្កាត់ [illegible] ស្រុក-ខណ្ឌ-ក្រុង [illegible] ខេត្ត-រាជធានី [illegible]

នៅថ្ងៃទី ០4 ខែ [illegible] ឆ្នាំ 2021 រួចហើយ។

អ្នកទទួល

អ្នកប្រគល់

[illegible]

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៣៧១
ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩
លេខ ៤៣០០...... អ.យ.ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង **ទែត សុធា** តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **៦៣៧១** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍លេខ ៨៥៥/១៩ រ.ប.ក.នបកក២ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃក្រសួងមហាផ្ទៃ ។

-បានឃើញលិខិតលេខ ១៨១៨ កយ រប/១៩ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ របស់ក្រសួងយុត្តិធម៌ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា:

ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កាន់លិខិតឆ្លងដែនលេខ [redacted] ទីកន្លែងកំណើតសង្កាត់លេខ២ ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន០៣នាក់ ជានីតិជន ។

**បានប្រព្រឹត្តដូចតទៅ**[1]៖ នាយប់ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ទណ្ឌិតឈ្មោះ [redacted] បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយលោក [redacted] នៃវិទ្យុអាស៊ីសេរី ដោយបានប្រមាថទៅលើអង្គព្រះមហាក្សត្រ ដែលមានខ្លឹមសារថា **"ព្រះមហាក្សត្ររបស់យើង គឺជាចំណាប់ខ្មាំងរបស់ ហ៊ុន សែន ដូច្នេះលោកអត់ហ៊ានធ្វើអីទេ លោកខ្លាច ហ៊ុន សែន លោកចង់តែរក្សារាជបល្ល័ង្កលោក ដូច្នេះយើងទុកព្រះអង្គមួយអន្លើទៅ យើងមិនអាចរំពឹងព្រះមហាក្សត្រដែលជាអាយ៉ងរបស់លោក ហ៊ុន សែន ដូចសព្វថ្ងៃទេបាទ"** ។ ពាក្យសម្តីរបស់ទណ្ឌិតឈ្មោះ [redacted] ដែលបានផ្សព្វផ្សាយជាសាធារណៈនេះ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ព្រះកិត្តិនាម **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដែលប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជាគោរពស្រឡាញ់ស្មើជីវិត ។

---

[1] សេចក្តីសង្ខេបអង្គហេតុ



អាសយដ្ឋាន: អគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ
Adress: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

អំពើខាងលើជាបទល្មើស: **ប្រមាថចំពោះអង្គព្រះមហាក្សត្រ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤៣៧ "ស្ទួន"** ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-**បានឃើញ** មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ។

## <u>សម្រេច</u>

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ:

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ[2]៖

ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៩ (ក្រៅឃុំ)

ពីបទ: **ប្រមាថចំពោះអង្គព្រះមហាក្សត្រ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤៣៧ "ស្ទួន"** ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

☐ ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3]......................................។

☑ ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[4] លើឈ្មោះខាងលើដើម្បីបង្ការ ឬបញ្ចប់បទល្មើសកុំឲ្យកើតឡើងជាថ្មី និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។

ថ្ងៃ សុក្រ ១៥ កើត ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩

**តំណាងអយ្យការ**

វីភឹម-គង្គា

[2] ឈ្មោះជនត្រូវចោទ
[3] កាតព្វកិច្ចណាមួយដែលមានចែងក្នុងមាត្រា ២២៣
[4] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងមាត្រា ២០៥

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង ********

លេខ....................

## ដីកាសន្និដ្ឋានចោទប្រកាន់ ជូនរឿងទៅជំនុំជម្រះភ្លាម[១]

***********

យើង ............................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង .................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ..................... ថ្ងៃទី............... ខែ..................... ឆ្នាំ ................. ។

បានឃើញមាត្រា ៦៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ២១ ក្រ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ១៩៩៣ ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថាៈ [២] .......................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

(១)- ដីកានេះ ប្រើសំរាប់ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានចោទប្រកាន់ ជូនរឿងទៅជំនុំជម្រះភ្លាម ឬបន្ទាន់ ចំពោះបទល្មើសមជ្ឈិមជាក់ស្តែង ហើយដែលមានជនល្មើសត្រូវបានចាប់ខ្លួនជាមុនតាមកំណត់ត្រឹមត្រូវនាំខ្លួនជូនទៅព្រះរាជអាជ្ញា ដោយមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។

(២)- រៀបរាប់អំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត ។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**********

**អយ្យការអម**
តុលាការខេត្ត-ក្រុង
..........................
**********
លេខ......................

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បទល្មើសថ្មីបន្ថែម

********

យើង.................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ...................................... ។
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ......................... ចុះថ្ងៃទី................ ខែ................. ឆ្នាំ...............
បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ......................... ចុះថ្ងៃទី............... ខែ....................... ឆ្នាំ.................... និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភ័ស្តុតាងនានា ។
បានឃើញដីកាសម្រេចសុំចោទប្រកាន់បទល្មើសថ្មីបន្ថែមលេខ.................. ចុះថ្ងៃទី............. ខែ................. ឆ្នាំ......................... របស់ចៅក្រមស៊ើបអង្កេត ។
យល់ឃើញថា :.........................................................................................................................
...............................................................................................................................................
...............................................................................................................................................
...............................................................................................................................................
...............................................................................................................................................
...............................................................................................................................................
សម្រេចផ្ដើមចោទប្រកាន់ឈ្មោះ ..................................ភេទ............ អាយុ ..........ឆ្នាំ ជាតិ.................. របររកស៊ី....................................... ទីលំនៅបច្ចុប្បន្ននៅភូមិ.........................ឃុំ-សង្កាត់................................. ស្រុក-ខណ្ឌ.............................................ខេត្ត-ក្រុង.....................................ទោសពីមុន ......................... និងគូកន ។ ឪពុកឈ្មោះ.............................................. "រ-ស" ម្ដាយឈ្មោះ ....................................... "រ-ស" ប្ដីឬប្រពន្ធឈ្មោះ..................................................."រ-ស"មានកូន ឬនៅលីវ .............................................នាក់ បន្ថែមពីបទ................................................................................ ប្រព្រឹត្តនៅភូមិ............................................ ឃុំ-សង្កាត់............................ ស្រុក-ខណ្ឌ................................ ខេត្ត-ក្រុង..........................................កាលពី ថ្ងៃទី ......... ខែ ................ ឆ្នាំ ................... តាមមាត្រា.................................................................. នៃច្បាប់ ................................................................................................................................................ ។
បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន, គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... .......................................... ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ ....................................................................... ។

ធ្វើនៅ.............................. ថ្ងៃទី............. ខែ............ ឆ្នាំ.............

***ព្រះរាជអាជ្ញា***

---

*កំណត់សំគាល់:* ក្នុងករណីព្រះរាជអាជ្ញាមិនសុំឱ្យចៅក្រមស៊ើបអង្កេតចាប់ឃុំខ្លួនជនល្មើសទេ ត្រូវឆូតលុបពាក្យ "និងសុំចាប់ឃុំខ្លួនជនល្មើសជាបណ្ដោះអាសន្ន" ខាងលើចោល ។